# ការសិក្សាអង្កេតស្ដីពីការគ្រប់គ្រងទំនាស់ នៅក្នុងភូមិកម្ពុជា

## ការសិក្សាឯកសារនានា
## និងការផ្ដល់យោបល់សំរាប់ការស្រាវជ្រាវក្នុងពេលអនាគត

ខារ៉ូឡាញ ហ៊ូជ
Caroline Hughes

មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ការអង្កេតស្តីពីការគ្រប់គ្រងទំនាស់ នៅក្នុងភូមិកម្ពុជា

**ការសិក្សាលើឯកសារនានា និង**
**ការផ្តល់យោបល់សំរាប់ការស្រាវជ្រាវក្នុងពេលអនាគត**

**Caroline Hughes**

**មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍**
**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
**ភ្នំពេញ ខែឧសភា ឆ្នាំ២០០២**

© រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឡើយ ។

**ការអង្កេតស្តីពីការគ្រប់គ្រងទំនាស់នៅក្នុងភូមិកម្ពុជាៈ *ការសិក្សាលើឯកសារនានា និង ការផ្តល់យោបល់សំរាប់ការស្រាវជ្រាវក្នុងពេលអនាគត***

**ខែឧសភា ឆ្នាំ២០០២**

***Caroline Hughes***

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះ បណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍/ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤
**អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh**

បកប្រែដោយ: យូ សិទ្ធីរិទ្ធ
កែសម្រួល និងរចនាដោយ: អ៊ុំ ចាន់ថា និង ឱក សេរីសោភក្តិ
បោះពុម្ពនៅប្រទេសកម្ពុជាដោយរោងពុម្ពពន្លឺពេជ្រ ផ្ទះលេខ៨៧$E_0$ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

# មាតិកា

សម្រង់អត្ថបទ ........ ១

**ក. ការកំណត់និយមន័យទំនាស់ និងការគ្រប់គ្រងទំនាស់** ........ ៣

១. ការគ្រប់គ្រងទំនាស់ ........ ៣

២. ទំនាស់ ........ ៥

**ខ. ភូមិគឺជាកន្លែងសំរាប់ធ្វើការគ្រប់គ្រងទំនាស់** ........ ៦

១. ការស្វែងយល់ពីសហគមន៍ ........ ៦

២. ចរិតភូមិនៅកម្ពុជា ........ ៧

៣. វិធីសាស្ត្រគ្រប់គ្រងទំនាស់នៅក្នុងភូមិ ........ ៩

៤. ស្តង់ដា រចនាសម្ព័ន្ធ និងស្ថាប័ន នៅក្នុងទំនាក់ទំនងនៅក្នុងសហគមន៍ ........ ១៥

**គ. ភូមិនៅក្នុងពិភពលោក** ........ ១៩

១. រូបភាពនៃឥទ្ធិពលខាងក្រៅ ........ ១៩

២. ឥទ្ធិពលសង្គ្រាម ........ ២៣

៣. ផលប៉ះពាល់នៃផ្សារសេរី ........ ២៥

៤. ផលប៉ះពាល់នៃកំណែទំរង់ខាងនយោបាយ ........ ២៨

៥. ផលប៉ះពាល់នៃប្រព័ន្ធផ្សព្វផ្សាយ ........ ២៩

**ឃ. សេចក្តីសន្និដ្ឋាន** ........ ២៩

ឯកសារយោង ........ ៣៣

# សម្រង់អត្ថបទ

ការសិក្សាស្រាវជ្រាវនូវឯកសារផ្សេងៗនេះ ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃគោលគំនិតដ៏ជាក់លាក់មួយ ដើម្បីសិក្សាអង្កេតពីការគ្រប់គ្រងទំនាស់នៅក្នុងភូមិកម្ពុជា និងផ្តល់មតិសំរាប់ការស្រាវជ្រាវបន្ថែមទៀត ។ ការសិក្សាពីទំនាស់ និងការគ្រប់គ្រងទំនាស់ បានអនុវត្តឡើងនៅក្នុងក្របខ័ណ្ឌនៃគោលគំនិតផ្សេងៗខាង "វប្បធម៌សន្តិភាព" និងបានរើកញែកថា ការងារនេះទាមទារឱ្យពិនិត្យទាំងនីតិវិធីសកម្ម (ស្ថាប័ន) និងបរិបទ (រចនាសម្ព័ន្ធ) នៅក្នុងការឆ្លើយតបនឹងទំនាស់ ។

ការស្វែងយល់ពីតួនាទីជាប្រវត្តិសាស្ត្រនៃភូមិកម្ពុជាក្នុងការដោះស្រាយទំនាស់ បានជួបឧបសគ្គនៃកង្វះទិន្នន័យខាងមនុស្សសាស្ត្រ (anthropological data) សំរាប់សម័យមុនសង្គ្រាម ។ លើសពីនេះទៀត ការសិក្សាតែមួយដែលបានធ្វើកន្លងមកស្តីពីការដោះស្រាយទំនាស់នៅក្នុងភូមិកម្ពុជា បានផ្តោតទៅលើបុគ្គល និងស្ថាប័ននានា ហើយបានអធិប្បាយបន្តិចបន្តួចអំពីរចនាសម្ព័ន្ធសំរាប់គ្រប់គ្រងទំនាស់ ។ ឯកសារនេះ បានគូសបញ្ជាក់ពីតំរូវការស្វែងយល់ពីលំនាំធំៗនៃទំនាក់ទំនងដែលអាចអូសទាញសហគមន៍ទៅកាន់រូបភាពណាមួយនៃទំនាស់ និងស្តង់ដាផ្សេងៗខាងវប្បធម៌ដែលមានឥទ្ធិពលទៅលើទំនាស់ និងការគ្រប់គ្រងទំនាស់ ។ ការប្រកាន់យកគោលគំនិតទូលាយបែបនេះ បានបំផុសនូវវិធីសាស្ត្រសិក្សាពីការគ្រប់គ្រងទំនាស់មួយដែលមិនគ្រាន់តែផ្តោតលើសកម្មភាពនានាសំរាប់ដោះស្រាយទំនាស់ដោយចំហប៉ុណ្ណោះទេ ប៉ុន្តែនឹងពិនិត្យផងដែរពីសកម្មភាពផ្សេងៗដែលកំណត់ចេញនូវទំនាក់ទំនងរវាងអ្នកភូមិផងគ្នា និងដែលធ្វើឱ្យដំណើរការគ្រប់គ្រងទំនាស់វាមានកំលាំងអនុវត្តន៍ និងមានលក្ខណៈពេញច្បាប់នៅក្នុងចិត្តគំនិតរបស់ពួកអ្នកភូមិ ។

វិធីសាស្ត្រនេះទាមទារការពិនិត្យពីបែបបទដែលអ្នកភូមិមើលឃើញពីស្ថានភាពរបស់ខ្លួននៅក្នុងភូមិ និងពីទំនាក់ទំនងរវាងខ្លួនគេ និងអ្នកភូមិផ្សេងៗទៀត ។ ទំលាប់ផ្សេងៗ និងប្រពៃណី វាកំណត់ចេញនូវការយល់ឃើញរបស់មនុស្សម្នាក់ៗអំពីឥរិយាបថដែលសមស្របចំពោះអ្នកដទៃនៅក្នុងភូមិ ទំនាក់ទំនងសំខាន់ៗដែលត្រូវថែរក្សា ប្រភពអំណាចដែលត្រូវគោរព និងបន្ទាត់ព្រំដែនរវាងអ្វីដែលអាច ឬមិនអាចអត់អោនបានសំរាប់បុគ្គល ឬសំរាប់ក្រុម ។ នេះហើយគឺជាក្របខ័ណ្ឌខាងគោលគំនិតដែលក្នុងនេះ បុគ្គលនឹងចាត់ចែងទំនាស់ផ្សេងៗជាមួយនឹងអ្នកដទៃ ហើយសហគមន៍នឹងធ្វើការគ្រប់គ្រងទំនាស់ ។

ទំនាក់ទំនងរវាងអ្នកភូមិ អាចស្វែងយល់បាននៅក្នុងក្របខ័ណ្ឌនៃរចនាសម្ព័ន្ធទំនាក់ទំនងខាងវណ្ណៈ និងតួនាទីបុរស-ស្ត្រីដែលក្នុងនេះបុគ្គលអនុវត្តយុទ្ធសាស្ត្រផ្សេងៗដើម្បីកសាងសុខុមាលភាពរបស់ខ្លួន ។ យុទ្ធសាស្ត្រទាំងនេះអាចជាការវិនិយោគក្នុងទុនខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងទុនជានិមិត្តរូប (ដែលមានជាគោលការណ៍ ឬរូបភាព តែគ្មានដំណើរការជាក់ស្តែង) ។ ឯចរិត និងរបាយវិនិយោគ គឺត្រូវកំណត់ឡើងដោយកត្តានានាខាងវប្បធម៌ ដូចជា ទស្សនៈស្តីពីអ្វីដែលត្រឹមត្រូវ និងអ្វីដែលមានសិទ្ធិអំណាចពេញច្បាប់ជាដើម ។

ការសិក្សាពីវិនិយោគរបស់បុគ្គល និងរបស់ក្រុម នៅក្នុងប្រភេទផ្សេងៗនៃទុន នឹងជួយបង្កើនការយល់ដឹងពីវប្បធម៌សន្តិភាព ព្រមទាំងជួយបំភ្លឺផងដែរពីបញ្ហារចនាសម្ព័ន្ធ និងស្ថាប័ន ។

តាមរបៀបរបបជាប្រពៃណីនៅក្នុងសហគមន៍តូចៗ សុខុមាលភាពរបស់បុគ្គល វាពឹងផ្អែកទៅលើទំនាក់ទំនងផ្ទាល់ខ្លួននៃឋានៈ និងទំនុកចិត្តនៅក្នុងភូមិ ជាជាងទៅលើទំនាក់ទំនងទីផ្សារដែលមានលក្ខណៈអបុគ្គល ។ ដូច្នេះការអង្កេតពីទំនាក់ទំនងនៅក្នុងសហគមន៍ ដោយប្រើក្របខ័ណ្ឌនៃទស្សនៈដូចបានបញ្ជាក់រួចមកហើយ នឹងផ្តោតលើយុទ្ធសាស្ត្រផ្សេងៗរបស់បុគ្គលនៅក្នុងបរិបទនៃស្តង់ដានានារបស់សហគមន៍ដែលចាត់ចែងអំពីការផ្តល់ឋានៈ និងការគោរពរាប់អាន ។ គោលការណ៍នេះវាត្រឹមត្រូវទាំងចំពោះភាគីក្នុងទំនាស់ និងអ្នកគ្រប់គ្រងទំនាស់ ហើយវានឹងផ្តល់ឱ្យអ្នកទាំងនេះនូវធនធានពិសេសៗសំរាប់យកមកចំណាយ ឬធ្វើវិនិយោគនៅក្នុងពេលមានទំនាស់ ។

"ភាពទន់ភ្លន់អាចបត់បែនបាន" នៃរចនាសម្ព័ន្ធខាងសិទ្ធិអំណាចដែលផ្អែកលើលក្ខណៈសម្បត្តិ និងអត្តសញ្ញាណផ្ទាល់ខ្លួន (មិនមែនលើស្ថាប័នផ្សេងៗដែលមានមូលដ្ឋានសំភារៈ និងគោលការណ៍កំណត់ជាក់លាក់) វាមានផលប៉ះពាល់ទៅលើវិធីសាស្ត្រនានាដែលភូមិធ្វើការគ្រប់គ្រងទំនាស់ ។ វិធីត្រួតពិនិត្យរបស់សង្គមដែលមានលក្ខណៈអបុគ្គល និងមានប្រភពពីខាងក្រៅ ដូចជារបបនីតិរដ្ឋជាដើម មិនទាន់មានការលូតលាស់នៅឡើយទេនៅក្នុងសង្គមកម្ពុជា ហើយភូមិកម្ពុជានានាក៏កំពុងប្រែប្រួលជាបន្តទៀតនៅក្រោមឥទ្ធិពលសង្គ្រាម ការកសាងប្រទេស ការជ្រៀតចូលនៃរបបមូលធននិយម ប្រជាធិបតេយ្យភាវូបនីយកម្ម និងការរីកដុះដាលប្រព័ន្ធផ្សព្វផ្សាយពត៌មានជាតិ និងអន្តជាតិ ។ ការរីកចំរើនទាំងនេះប្រហែលជានឹងនាំមកនូវការកែតំរូវរចនាសម្ព័ន្ធសង្គមកិច្ច និងជានិមិត្តរូបនៃភូមិនៅជនបទជាច្រើនថែមទៀត ។ ម្យ៉ាងទៀត នៅកម្ពុជាសព្វថ្ងៃ មានការប្រឹងប្រែង ដោយយកចិត្តទុកដាក់ដើម្បីកំណត់ឡើងវិញនូវទស្សនៈស្តីពីសិទ្ធិ ដោយផ្អែកលើឱវាទរបស់ព្រះពុទ្ធ និងតំលៃផ្សេងៗរបស់បស្ចឹមប្រទេស ដូចជាសិទ្ធិមនុស្សជាដើម ។ នេះជាចំណែកមួយនៃចលនាកសាងមូលដ្ឋានខាងសីលធម៌របស់សង្គមកម្ពុជាឡើងវិញ ។

ការវាយតំលៃពីរបៀបរបបដែលភូមិស្រូបយកការប្រែប្រួលផ្សេងៗ អាចជាកត្តាគន្លឹះសំរាប់ពន្យល់ពីមូលហេតុនៃទំនាស់ក្នុងពេលសព្វថ្ងៃ និងជោគជ័យ ឬបរាជ័យនៃការងារគ្រប់គ្រងទំនាស់ដែលគេបានអនុវត្តនៅតាមមូលដ្ឋាន ។

# ការអង្កេតស្ដីពីការគ្រប់គ្រងទំនាស់
# នៅក្នុងភូមិកម្ពុជា

ការសិក្សាអង្កេតស្ដីពីការគ្រប់គ្រងទំនាស់នៅក្នុងភូមិកម្ពុជា បានជួបបញ្ហាចោទខាងទស្សនៈមួយចំនួន ។ ទី១ ប្រភេទនៃចម្លើយ និងជំហរ ចំពោះទំនាស់ដែលគេអាចចាត់ទុកដោយសមរម្យបានថាជា "ការគ្រប់គ្រងទំនាស់" ត្រូវតែកំនត់ឡើងដោយឡែកគេត្រូវមាននិយមន័យអាចប្រើការបានមួយនៃពាក្យ "ទំនាស់" ។ ទី២ ការសិក្សាអង្កេតពីការគ្រប់គ្រងទំនាស់នៅកំរិតនេះបានឈរលើការសន្មតថា ភូមិគឺជាកន្លែងដ៏សំខាន់សំរាប់ការគ្រប់គ្រងទំនាស់ ហើយអ្នកភូមិក៏បានយល់ឃើញដូច្នេះដែរ ។ ការសន្មតជាមុនបែបនេះត្រូវតែមានការពិនិត្យ និងការកំណត់ឡើងវិញនូវខ្លឹមសាររបស់វា ដោយត្រូវធ្វើការពិចារណានៅក្នុងបរិបទនៃការប្រែប្រួលផ្សេងៗដែលកំពុងជះឥទ្ធិពលមកលើសង្គមកម្ពុជា ។

## ក. ការកំណត់និយមន័យទំនាស់ និងការគ្រប់គ្រងទំនាស់

### *១. ការគ្រប់គ្រងទំនាស់*

ឯកសារនេះសិក្សាអង្កេតពីការគ្រប់គ្រងទំនាស់ដើម្បីជួយបំភ្លឺដល់ទស្សនៈជាមូលដ្ឋានរបស់ UNESCO ស្ដីពី "វប្បធម៌សន្តិភាព" ដែលអាចស្ដែងចេញពិតៗតាមភូមិនៅកម្ពុជា ។ ក្នុងគោលដៅនេះ និយមន័យ "ការគ្រប់គ្រងទំនាស់" ត្រូវមានទិដ្ឋភាពពីរ ។ ទី១ ត្រូវមានរួមបញ្ចូលការអនុវត្តន៍ដំណើរការសកម្មនានា ដើម្បីកាត់ក្ដីលើទំនាស់ដែលជាញឹកញយគឺមានស្ថាប័នឬទីភ្នាក់ងាររបស់រដ្ឋជាអ្នកអនុវត្ត ។ ទី២ ចំណុចដ៏សំខាន់មួយគឺត្រូវមានរួមបញ្ចូលនូវដំណើរការនៃស្ដង់ដាផ្សេងៗខាងវប្បធម៌ក្នុងការគ្រប់គ្រងទំនាស់ និងការដោះស្រាយទំនាស់ ។ ដូច្នេះហើយ សៀវភៅក្បួនស្ដីពីការដោះស្រាយទំនាស់ដែលចងក្រងឡើងដោយការិយាល័យឧត្ដមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើងថា:

> *ដំណើរការគ្រប់គ្រងវិវាទ មិនមែនគ្រាន់តែជា "ផលិតផល" ដែលគេអាចយកចេញពីក្នុងទូ មកប្រើបានយ៉ាងស្រួលនៅគ្រប់កន្លែងតាមការចាំបាច់នោះទេ ។ វិវាទ និងដំណើរការគ្រប់គ្រងវិវាទ ត្រូវតែសំគាល់ថា មានចំណងទាក់ទងនឹងគ្នាយ៉ាងខ្លាំង និងឆ្លុះបញ្ចាំងពីចរិតនៃអន្តរកម្មខាងសង្គមកិច្ចនៅក្នុងវិវាទ ជាពិសេសទាក់ទិននឹងទំនាក់ទំនងខាងសិទ្ធិអំណាចរវាងអ្នកចូលរួមផ្សេងៗ*[១] ។

---

១ Cambodian Field Office of the United Nations Centre for Human Rights (undated), *Mediating Public Issue Disputes: Managing Land Disputes in Cambodia, Resource Notes in English and Khmer* (Phnom Penh: UNCHR) p. 16

ទិដ្ឋភាពទី២ នៃការគ្រប់គ្រងទំនាស់ បានបង្កើតបញ្ហាច្រើនទៀតចំពោះអ្នកស្រាវជ្រាវ ។ ការប្រព្រឹត្តិទៅនៃដំណើរការសកម្មភាពនានា ជាពិសេសរបស់រដ្ឋ គេអាចមើលឃើញយ៉ាងច្បាស់ និងពន្យល់បានយ៉ាងងាយ ។ ប៉ុន្តែស្តង់ដាផ្សេងៗខាងវប្បធម៌ដែលទ្រទ្រង់ដល់ដំណើរការនេះ គឺពិបាករកមើល និងធ្វើការពិពណ៌នា ពីព្រោះជាញឹកញាប់ពួកអ្នកដែលរស់នៅជាមួយវា និងប្រើប្រាស់វារាល់ថ្ងៃ បានចាត់ទុកវាជារឿងធម្មតា និងជាចំណែកមួយនៃបរិស្ថានធម្មជាតិ ។ ការសិក្សាអង្កេតអំពីកិច្ចដំណើរការនូវរូបភាពផ្សេងៗនៃការគ្រប់គ្រងទំនាស់ ទាមទារការញែកឱ្យដាច់ឆ្ការវាងរចនាសម្ព័ន្ធ និងទីភ្នាក់ងារនៅក្នុងបរិបទកម្ពុជា ។

ការផ្សារភ្ជាប់ការគ្រប់គ្រងទំនាស់ ទៅនឹងការកសាង "វប្បធម៌សន្តិភាព" ក៏បានផ្តល់គំនិតដែរថា ដំណើរការគ្រប់គ្រងទំនាស់នឹងផ្តល់លទ្ធផលមានស្ថិរភាព ដែលធ្វើឱ្យសហគមន៍មានភាពចុះសំរុងគ្នា ។ ទាក់ទិននឹងលទ្ធផល គេឃើញមាន ៤រូបភាពនៃការគ្រប់គ្រងទំនាស់ដែលមានល្បាយខុសៗគ្នានៃការឆ្លើយតបដោយសកម្ម និងការឆ្លើយតបដោយអសកម្ម:

- *ការឈានឡើងនៃទំនាស់:* ក្នុងនេះទំនាស់កាន់តែប្រឈមមុខគ្នាខ្លាំងឡើង ហើយអាចនឹងមានកំនើនអំពើហិង្សាទៀតផង
- *ការចៀសវាងទំនាស់:* ក្នុងនេះមូលហេតុនៃទំនាស់នៅមានដដែល ហើយអាចកំពុងរាលដាលទៀតផង ប៉ុន្តែភាគីម្ខាង ឬទាំងសងខាងមិនចង់មានការប្រឈមមុខគ្នាទេ
- *ការរំសាយទំនាស់:* ក្នុងនេះភាគីម្ខាង ឬទាំងសងខាង មិនចង់មានការប្រឈមមុខគ្នា ហើយយូរទៅ ទំនាស់ក៏កាន់តែមើលឃើញថាមិនសូវសំខាន់ ពីព្រោះមានការប្រែប្រួលក្នុងទិដ្ឋភាពផ្សេងទៀតនៃទំនាក់ទំនងរវាងគូភាគី ឬការប្រែប្រួលនៅក្នុងបរិបទ
- *ការដោះស្រាយទំនាស់:* ក្នុងនេះវិធានការសកម្មមួយខ្សែត្រូវបានអនុវត្ត ដើម្បីស្វែងរកដំណោះស្រាយមួយដែលទាំងសងខាងអាចទទួលយកបាន និងលទ្ធផលមួយដែលគ្មាននរណាម្នាក់អាចតវ៉ាប្រឆាំងបាន ។

ការឈានឡើងនៃទំនាស់ គឺជារូបភាពមួយនៃការឆ្លើយតបនឹងទំនាស់ ដែលមិនអំណោយផលចំពោះសន្តិភាព និងការចុះសំរុងគ្នាទេ ដូច្នេះហើយគេចាត់ទុកវាជាបរាជ័យមួយនៃការគ្រប់គ្រងទំនាស់ ។ ការដោះស្រាយទំនាស់គឺជាជោគជ័យមួយដែលអាចមើលឃើញបានយ៉ាងងាយ ។ ទិដ្ឋភាពអកម្មផ្សេងៗនៃការរំសាយទំនាស់ ជាពិសេសការចៀសវាងទំនាស់ គឺពិបាកធ្វើការស្រាវជ្រាវជាង ពីព្រោះវាជាលទ្ធផលនៃអសកម្មភាព មិនមែនជាលទ្ធផលសកម្មភាពទេ ។

រឿងសំខាន់មួយទៀតគឺត្រូវញែកឱ្យដាច់ពីគ្នារវាងការរំសាយទំនាស់ និងការចៀសវាងទំនាស់ ពីព្រោះការរំសាយទំនាស់គឺជារូបភាពមួយនៃការគ្រប់គ្រងទំនាស់ដែលមានជោគជ័យ រីឯការចៀសវាងទំនាស់គឺមិនមែនដូច្នេះទេ ។ ការចៀសវាងជាសាធារណៈជាញឹកញាប់តែងមានអមផងដែរដោយអ្វីដែលលោក James Scott បានហៅថា "ទំលាប់ដដែលៗ" ឬ "ការរឹងរូសជានិមិត្តរូប" ។ ការសិក្សារបស់លោក Scott ក្នុងភូមិមួយនៅម៉ាឡេស៊ី បានកត់ត្រានូវ "ការរឹងរូសតាមទំលាប់ដដែលៗ" នៅក្នុងទំនាក់ទំនងរវាងអ្នកមាន និងអ្នកក្រ នៅក្នុងរយៈពេលមួយដែលមានការប្រែប្រួលសេដ្ឋកិច្ច ។

រូបភាពនៃការរឹងរូសទាំងនេះ គេពិបាកនឹងមើលឃើញ ។ លោក Scott បានចង្អុលបង្ហាញថា ចរិតនៃទំនាក់ទំនងខាងសិទ្ធិអំណាចរវាងអ្នកមាន និងអ្នកក្រ បានបង្ខំឱ្យអ្នកក្រត្រូវលាក់ទុកការរឹងរូសរបស់ខ្លួននៅក្នុងស្ថានការណ៍ភាគច្រើន ។ គាត់បានអធិប្បាយថា:

*រឿងដែលអ្នកក្រត្រូវលាក់អារម្មណ៍របស់ខ្លួនគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ។ ការលាក់អារម្មណ៍គឺជាជំហរជាទូទៅ និងជាចាំបាច់របស់របស់វណ្ណៈក្រោមបង្គាប់នៅគ្រប់កន្លែង គ្រប់ពេល (នេះជារឿងពិតមួយដែលធ្វើឱ្យលេចឱកាសដ៏*

*កម្រខ្លាំងថែមទៀត និងមានគ្រោះថ្នាក់នានាដែលអ្នកក្របានបោះបង់ជំហរនេះចោល) ។ ក្នុងការអធិប្បាយល្អិតល្អន់ពីជីវិតរបស់វណ្ណៈក្រោមបង្អាប់ គេមិនអាចរំលងការញែកចេញពីគ្នានូវអ្វីដែលគេនិយាយ "ពីក្រោយខ្នង" និងអ្វីដែលគេអាចនិយាយដោយចំហចោលបានទេ*[២] ។

មតិរបស់លោក Scott បានជំរុញពួកអ្នកស្រាវជ្រាវពីទំនាស់ ឱ្យធ្វើការពិចារណាជាយុទ្ធសាស្ត្រឡើងវិញ ។ ទំនាក់ទំនងខាងសិទ្ធិអំណាចរវាងគូភាគីក្នុងទំនាស់ វាមានចំណែកយ៉ាងធំនៅក្នុងការកសាងចម្លើយតបទៅនឹងទំនាស់ណាមួយ ។ ដោយឡែកភាគីដែលទន់ខ្សោយ ប្រហែលនឹងខិតខំចៀសវាងការបញ្ចេញអារម្មណ៍របស់ខ្លួនជាសាធារណៈ ។ ការសិក្សារបស់លោក Scott បានផ្តល់នូវគំរូដ៏មានប្រយោជន៍សំរាប់ការស្រាវជ្រាវរូបភាពបង្កប់ផ្សេងៗនៃការរឹងរូស ទោះបីជាការស្រាវជ្រាវរបស់គាត់ ត្រូវបានធ្វើឡើងនៅក្នុងភូមិមួយដែលកន្លងមកមិនដែលឃើញមានកើតទំនាស់ ឬលក្ខណៈខុសគ្នាខ្លាំងនៅក្នុងទំនាក់ទំនងសិទ្ធិអំណាចដូចដែលគេតែងពិនិត្យឃើញនៅក្នុងបណ្តាភូមិកម្ពុជា នៅក្នុងពេលថ្មីៗនេះក៏ដោយ ។ ក្នុងករណីនៃប្រទេសកម្ពុជា កំលាំងគ្របសង្កត់របស់អ្នកមានអំណាច នៅក្នុងកំណត់ត្រាជាសាធារណៈនៃទំនាស់ វារិតតែលេចធ្លោខ្លាំងឡើងថែមទៀត ។

## *២. ទំនាស់*

គេបានផ្តល់មតិថា ជាជាងការខិតខំកសាងនិយមន័យតែមួយគត់នៃទំនាស់ យើងគួរធ្វើការស្រាវជ្រាវថែមទៀត ដើម្បីស្វែងរកប្រភេទផ្សេងៗនៃទំនាស់ដែលគួរយកចិត្តទុកដាក់ ជាពិសេសទំនាស់ដែលជាប់ទាក់ទងនឹងរូបភាពផ្សេងៗនៃការគ្រប់គ្រងទំនាស់ដូចបានបញ្ជាក់នៅខាងលើ ។ ការកំណត់ប្រភេទនៃទំនាស់ដោយច្បោលៗមានដូចតទៅ:

- *ទោសកម្ម:* ករណីនៃឥរិយាបថរបស់បុគ្គលណាមួយ ដែលមានលក្ខណៈប្រឆាំងនឹងសង្គម ដែលហាក់ដូចជាចេញមកពីភាគីតែម្ខាង ហើយប្រមាថ ឬបង្កការខូចខាតដល់សង្គមនៅក្នុងភូមិ (ដូចជា ការស្រវឹងស្រា ឬការវាយប្រហារខ្លាំង)[៣]
- *វិវាទ:* ការខ្វែងគំនិតគ្នាពីអ្វីមួយរវាងភាគីពីរ ឬច្រើន (ដូចជា វិវាទក្នុងគ្រួសារ ឬវិវាទដីធ្លី)
- *ទំនាស់ផលប្រយោជន៍:* ការខ្វែងគំនិតជាប់បន្តរវាងភាគីពីរ ឬច្រើន ក្នុងនេះលទ្ធផលបែបណាមួយនឹងមានផលប៉ះពាល់យ៉ាងច្បាស់លាស់ទៅលើផលប្រយោជន៍ខាងសំភារៈរបស់ភាគីមួយ ឬច្រើន (ឧ. ការប្រើប្រាស់ប្រភពទឹករួមផ្សំគ្នា)
- *ទំនាស់អត្តសញ្ញាណ:* សភាពការណ៍កំពុងបន្តទៅមុខ ដោយក្នុងនេះភាគីមួយឬច្រើន បានចាត់ទុកវត្តមានរបស់ភាគីមួយទៀតថា ជាការប្រមាថ ឬជាការគំរាមកំហែង (ឧ. ទំនាស់រវាងអ្នកដើរតាមគណបក្សនយោបាយ ឬរវាង សមាជិកក្រុមជនជាតិភាគតិចខុសៗគ្នា)
- *ទំនាស់បក្សពួក:* ទំនាស់រវាងក្រុមពីរ ឬច្រើន ដែលប្រជែងដណ្តើមអំណាច (ទំនាស់រវាងអ្នកដើរតាមបេក្ខជនខុសៗ គ្នាក្នុងពេលបោះឆ្នោត)

---

២ James Scott (1985), *Weapons of the Weak, the Everyday Forms of Peasant Resistance,* (New Haven: Yale UP) p.284

៣ លោក Peter Swift បានកត់សំគាល់ថា នៅកម្ពុជា ចំពោះឥរិយាបថគឃ្លើន ឬប្រឆាំងនឹងសង្គម (aggressive or anti-social behaviour) គេច្រើនប្រើពាក្យហិង្សា គឺដូចគ្នានឹងហិង្សា ដែលស្មើនឹងពាក្យ violence ក្នុងភាសាអង់គ្លេសដែរ ។ Peter Swift (1999), "Violence in Cambodian Villages", unpublished paper (Phnom Penh: Local Capacities for Non-Violence Project, American Friends Service Committee).

- *ទំនាក់ទំនងគ្របសង្កត់:* សភាពការណ៍ទាក់ទិននឹងភាគីពីរ ឬច្រើន ដែលក្នុងនេះ ភាគីនានាបានទទួលស្គាល់ថា ភាគី មួយមានអំណាចដាក់បង្ខំបំណងរបស់ខ្លួនទៅលើភាគីឯទៀត ដោយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ភាគី ដែលទន់ខ្សោយ (ឧទាហរណ៍ ម្ចាស់ដីដាក់បង្ខំការតំលើងថ្លៃឈ្នួលដី ទៅលើអ្នកក្រីក្រដែលជួលដី) ។

ទំនាក់ទំនងគ្របសង្កត់ ដែលជាចំណុចក្រោមគេនៅក្នុងបញ្ជីខាងលើ គឺជាប្រភេទទំនាស់ដែលលោក Scott បានសិក្សាអង្កេតនៅក្នុងឯកសារ អាវុធរបស់អ្នកក្រ (Weapons of the Weak) របស់គាត់ ។ ប្រភេទទាំង៦ នៅខាងលើ គឺជាប្រភេទទំនាស់ដែលមានលក្ខណ:បើកចំហតិចឬច្រើន (នៅពេលទំនាក់ទំនងខាងសិទ្ធិអំណាចវាកាន់តែស្មើភាពកាលណា ទំនាស់ក៏កាន់តែបើកចំហកាលនោះដែរ) ។ លោក Scott បានបញ្ជាក់ទៀតថា ទំនាស់គ្រប់ប្រភេទ ដែលត្រូវសិក្សាអង្កេត គេបានទទួលស្គាល់វាជាលក្ខណ:ឯកជន ទោះបីគេមិនបានធ្វើការតស៊ូជាសាធារណ:ក៏ដោយ ។

## ២. ភូមិគឺជាកន្លែងសំរាប់ធ្វើការគ្រប់គ្រងទំនាស់

### *១. ការស្វែងយល់ពីសហគមន៍*

គំរូនៃការគ្រប់គ្រងទំនាស់មួយដែលមានបញ្ចូលទាំងនីតិវិធីសកម្ម (ទីភ្នាក់ងារ) និងបរិបទវប្បធម៌ (រចនាសម្ព័ន្ធ) បានតំរូវឱ្យពិនិត្យមើលពីបែបបទដែលអ្នកភូមិបានឃើញពីស្ថានភាពរបស់ខ្លួននៅក្នុងភូមិ និងទំនាក់ទំនងជាមួយអ្នកភូមិផ្សេងទៀត ។

អ្នកស្រាវជ្រាវខាងមនុស្សសាស្ត្រ បានជជែកដេញដោលគ្នាយ៉ាងយូរពីបញ្ហាថា តើគួរចាត់ទុកភូមិកម្ពុជាជាសហគមន៍មួយដែលតភ្ជាប់ដោយខ្សែចំណងសាមគ្គីភាព ឬក៏ជាការប្រមូលផ្តុំនូវបុគ្គលឯកជនម្នាក់ៗមកជាក្រុមមួយ ដើម្បីមានការងាយស្រួលក្នុងកិច្ចដំណើរការជាក់ស្តែង?[៤] អ្នកស្រាវជ្រាវម្នាក់ដែលជាអ្នកចងក្រងអត្ថបទសិក្សាស្រាវជ្រាវអំពីឯកសារជាភាសាបារាំងស្តីពីសហគមន៍ក្នុងភូមិកម្ពុជា) បានសន្និដ្ឋានថា "ការសិក្សានានាបាននិយាយស្របគ្នាជាឯកឆន្ទថា "គ្មានចំណងសាមគ្គីភាពរវាងអ្នកភូមិទេ: មូលដ្ឋាននៃរចនាសម្ព័ន្ធសង្គមគឺ គ្រួសារ"[៥] ។ អ្នកស្រាវជ្រាវផ្សេងៗទៀតមានទស្សនៈខុសពីនេះ ។ លោក Paul Davenport et al. បានសរសេរថា "ទោះបីភក្តីភាពវាសំខាន់បំផុតនៅក្នុងគ្រួសារក៏ដោយ ក៏គេឃើញមានលំនាំផ្សេងទៀតនៃមិត្តភាព និងកាតព្វកិច្ចផងដែរ"[៦] ។

ការសង្កត់ធ្ងន់ពីអត្តសញ្ញាណរួមគ្នារបស់អ្នកភូមិ និងពីព្រំប្រទល់ភូមិ វាមានប្រយោជន៍ក្នុងការពិចារណាពីបែបបទដែលអ្នកភូមិអាចជួយទ្រទ្រង់ដល់រចនាសម្ព័ន្ធនានាសំរាប់ការគ្រប់គ្រងទំនាស់ ។ លោកស្រី Jacqueline Scherer មានមតិថា:

> *ការពិភាក្សាពីសហគមន៍បាននាំដល់ការពិចារណាពីអត្តសញ្ញាណ ការប្តេជ្ញាចិត្ត និងដំណើរការធ្វើអន្តរកម្មផ្សេងៗ ដូចជា ការប្រាស្រ័យទាក់ទង ការចាត់ចែងទំនាស់ និងពីភាពតានតឹងរវាងបុគ្គល និងសង្គមធំទាំងមូល*[៧] ។

ទំលាប់ និងទំនៀមទំលាប់ ក្នុងរឿងអត្តសញ្ញាណ ការប្តេជ្ញាចិត្ត និងអន្តរកម្មផ្សេងៗ វាមានសារ:សំខាន់សំរាប់ការកសាងរចនាសម្ព័ន្ធគ្រប់គ្រងទំនាស់នៅក្នុងភូមិ ។ ទំលាប់ និងទំនៀមទំលាប់ វាកំណត់នូវទស្សនៈរបស់បុគ្គលអំពីឥរិយាបថសមស្របចំពោះអ្នកឯទៀតនៅក្នុងភូមិ ទំនាក់ទំនងសំខាន់ៗដែលត្រូវរក្សាការពារ ប្រភពអំណាចដែលត្រូវគោរព និងបន្ទាត់ព្រំដែនរវាងអ្វីដែលអាច ឬមិនអាចអត់អោនបានដោយបុគ្គល ឬដោយក្រុម ។ នេះហើយជាក្របខ័ណ្ឌខាងទស្សនៈដែលក្នុងនេះបុគ្គល

---

៤ For a review of this literature see the report on The Meaning of Community in Cambodia: Literature Reviews, Khmer, French and English Languages (Phnom Penh: Working Group on Social Organization in Cambodia, May 1999)

៥ Ellie Brown, “The Meaning of Community in Cambodia, French Literature Review”, The Meaning of Community, op. cit., p.11

៦ Paul Davenport et al. (1995), *Vulnerable in the Village, A Study of Returneesin Battambang Province, Cambodia, with a Focuson Strategies for the Landless* (Phnom Penh: LWS, UNHCR and JSRC) p.63

៧ Jacqueline Scherer (1972), Comtemporary Community: Sociological Illusion or Reality (London: Tavistock) p.3

នឹងចាត់ចែងទំនាស់ជាមួយអ្នកឯទៀត ហើយសហគមន៍នឹងត្រូវធ្វើការគ្រប់គ្រងទំនាស់ ។

## ២. ចរិតភូមិនៅកម្ពុជា

តាំងពីយូរមកហើយ ភូមិគឺជាអង្គភាពរដ្ឋបាលគន្លឹះក្នុងសង្គមកម្ពុជា ។ លោក William Collins បានលើកមតិថា ភូមិត្រូវបានចាត់ទុកជាដែនមានអារ្យធម៌នៃការប្រឹងប្រែងរបស់មនុស្សជាតិ គឺផ្ទុយពីពិភពដែលគ្មានអារ្យធម៌នៃ "តំបន់ព្រៃ" ។ រឿងនេះបានធ្វើឱ្យគេយល់ឃើញទៀតថា ភូមិជាអង្គភាពមួយយ៉ាងសំខាន់ដែលផ្តល់អារម្មណ៍មានសន្តិសុខដល់សមាជិករបស់ខ្លួន[៨] ។

ដោយសារហេតុផលដូចខាងលើ ភូមិគឺជាកន្លែងមួយយ៉ាងសំខាន់សំរាប់ចាត់ចែងដោះស្រាយទំនាស់ ។ នៅក្នុងភូមិមានធនធានជាច្រើន (ដែលពុំមាននៅកំរិតគ្រួសារទេ) ដូចជា អ្នកចាស់ទុំដែលអ្នកផងគោរពមន្ត្រីចាត់តាំងរបស់រដ្ឋ អាចារ្យ គ្រូហ្ម និង សូយត្រាណ... ។ ប៉ុន្តែការគ្រប់គ្រងទំនាស់នៅកំរិតនេះ វានៅទាបជាងកំរិតជាផ្លូវការនៃការអនុវត្តន៍តាមច្បាប់រដ្ឋនៅឡើយ ។

"ភាពអាចបត់បែនបាន" នៃរចនាសម្ព័ន្ធអំណាចដែលផ្អែកលើការយល់ដឹងអន្តរបុគ្គលអំពីឋានៈ និងអត្តសញ្ញាណ (មិនមែនផ្អែកលើស្ថាប័នដែលមានមូលដ្ឋានសំភារៈ និងច្បាប់រៀបចំច្បាស់លាស់) វាមានផលប៉ះពាល់ទៅលើវិធីផ្សេងៗ ដែលភូមិធ្វើការគ្រប់គ្រងទំនាស់ ។ ក្នុងបរិបទនៃអង្គការសង្គមក្រៅផ្លូវការ តាំងពីដើមរៀងមកគេចូលចិត្តប្រើមធ្យោបាយក្រៅផ្លូវការនៃការគ្រប់គ្រងទំនាស់ ។ លោក David Chandler បានធ្វើការកត់សំគាល់ពីជីវិតក្នុងភូមិកម្ពុជាក្នុងទសវត្សរ៍១៨៣០ ដូចខាងក្រោម:

> *ជំលោះក្នុងភូមិ ឬរវាងអ្នកជិតខាង ត្រូវបានដោះស្រាយតាមការសំរុះសំរួលគ្នា ជាជាងតាមគោលការណ៍កំណត់ក្នុងច្បាប់ ហើយជាញឹកញាប់ទំនាស់នៅតែរ៉ាំរ៉ៃជាច្រើនឆ្នាំបន្តមកទៀត ។ តាមធម្មតា ដើម្បីបំរើគោលដៅបុណ្យទាន និងការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់លើ ភូមិតែងស្ថិតនៅក្រោមការគ្រប់គ្រងគ្រួតត្រាពីសំណាក់បុរសជាចាស់ទុំដែលត្រូវបានជ្រើសយកដោយសារមានជំនាញខាងកសិកម្ម ចេះអក្សរ និងមានស្មារតីស្អាតស្អំ[៩] ។*

ទស្សនៈស្តីពីភូមិកម្ពុជានៅពេលនោះ វាស៊ីគ្នានឹងការពិពណ៌នាផ្សេងៗនាសម័យក្រោយបានឯករាជ្យ នៅក្នុងរូបភាពមួយចំនួន ។ កង្វះស្ថាប័នរដ្ឋអំណាចជាផ្លូវការនានា និងសារៈសំខាន់ស្នូលនៃពិធីផ្សេងៗនៅក្នុងជីវភាពសហគមន៍ នៅតែជាចំណុចមួយដែលលេចធ្លោដដែល ។

លោកស្រី May Ebihara បានរៀបរាប់ពីរចនាសម្ព័ន្ធដឹកនាំភូមិ និងរូបភាពស្តង់ដានៃអំណាចនៅក្នុងភូមិកម្ពុជានៅក្នុងទសវត្សរ៍១៩៥០ ដូចតទៅ:

> *ភូមិ "សប្បាយ" មានស្វ័យភាពនយោបាយមួយកំរិត ដោយសារប្រព័ន្ធក្រៅផ្លូវការនៃអំណាចក្នុងភូមិ បានផ្តល់អំណាចមួយកំរិតឱ្យ "អ្នកធំ" ពីរនាក់ ដើម្បីគ្រប់គ្រងការងារផ្សេងៗរបស់ភូមិ ។*

លោកស្រី Ebihara បានពិពណ៌នា "អ្នកធំ" ទាំងពីរថា "មានចរិយាល្អវិសេស ការវិនិច្ឆ័យត្រឹមត្រូវ បុគ្គលរឹងប៉ឹង" ហើយ "ត្រូវបានផ្តល់នូវកិត្យានុភាពពិសេស និងសិទ្ធិអំណាចមួយចំនួនសំរាប់ការងារនៅក្នុងភូមិ"[១០] ។ ភូមិសប្បាយ មានប្រធានជ្រើសតាំងតាមការបោះឆ្នោតម្នាក់ ហើយភូមិនេះជាចំណែកនៃឃុំមួយ[១១] ដែលមានមេឃុំជ្រើសតាំងតាមការបោះឆ្នោតដូចគ្នា ។ Ebihara បានរាយការណ៍ថា អ្នកភូមិតែងទៅពិគ្រោះយោបល់ជាមួយមេឃុំ

---

៨ William Collins (undated), Dynamics of Dispute Resolution and Administration of Justice for Cambodian Villagers (Phnim Penh: USAID)

៩ David Chandler (1993), *A History of Cambodia*, 2nd edn. (Chiang Mai: Silkworm) p.104

១០ Ebihara (1971) "Intervillage, Intertown and Village-City Relations in Cambodia" *Annals of the New York Academy of Sciences*, pp. 360/1

១១ សព្វថ្ងៃ ឃុំត្រូវបានបកប្រែជាទូទៅជាពាក្យអង់គ្លេស commune ។

*សំរាប់ការងារខាងរដ្ឋបាលជាច្រើនៈ ដើម្បីរាយការណ៍ពីកំនើត និងមរណភាព ដើម្បីសុំសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្រលែងលះ ដើម្បីសុំលិខិតបញ្ជាក់ការលក់ទ្រព្យសម្បត្តិធំៗ ដើម្បីសុំការកាត់ក្តីលើវិវាទធ្ងន់ធ្ងរ...*[១២]

ក្រៅពីរដ្ឋបាលកំរិតនេះ Ebihara រាយការណ៍ថា "រចនាសម្ព័ន្ធនយោបាយជាផ្លូវការ មានសកម្មភាពតិចតួចណាស់ក្នុងការជំរុញឱ្យមានទំនាក់ទំនងទៅក្រៅភូមិ" ។ ថ្នាក់បន្ទាប់នៃរដ្ឋបាលក្នុងស្រុក គឺអាជ្ញាធរថ្នាក់ស្រុក ដែលអ្នកភូមិទៅជួបទាក់ទង "មិនញឹកញាប់ទេ" ។ Ebihara សរសេរថាៈ

*រឿងនេះមួយចំណែក គឺដោយសារភាគច្រើននៃការងារទាក់ទិននឹងអ្នកភូមិ គឺត្រូវបានមេឃុំចាត់ចែង ដោះស្រាយ និងមួយចំណែកទៀតដោយសារអភិបាលស្រុក និងជំនួយការនានារបស់គាត់ (មន្ត្រីការិយាល័យវិជ្ជាជីវៈដែលរដ្ឋាភិបាលមជ្ឈិមបានតែងតាំងក្នុងមុខតំណែង) ត្រូវបានប្រជាជនសំគាល់ថា គ្មានមនោសញ្ចេតនា នៅដាច់តែឯង មានឋានៈសង្គមខ្ពស់ជាងគេ ដែលធ្វើឱ្យប្រជាជនរារែកមិនចង់ទៅជិតទេ ។ ផ្ទុយទៅវិញ មេឃុំគឺជាកសិករដែលអ្នកភូមិខ្លួនឯងបានបោះឆ្នោតឱ្យធ្វើមេឃុំ*[១៣] ។

ប្រជាជនចាត់ទុក អភិបាលស្រុកជា "អ្នកធំដែលគេត្រូវគោរព និងមិនអាចស្និទ្ធស្នាលបាន[១៤] ។ ដូច្នេះហើយ គេទៅទាក់ទងសាលាស្រុក តែកាលណាមិនអាចដោះស្រាយបាននៅថ្នាក់ឃុំ គឺដូចគ្នានឹងការិយាល័យនានានៃរដ្ឋាភិបាលមជ្ឈិមនៅភ្នំពេញ ដែលគេទៅទាក់ទងជាចុងក្រោយបំផុត បើសិនជាមានបញ្ហាធ្ងន់ធ្ងរខ្លាំង"[១៥] ។

របាយការណ៍នេះឆ្លុះបញ្ចាំងពីការលូតលាស់នៅក្នុងសម័យអាណានិគមនៃរបបរដ្ឋផ្អែកលើសំភារៈនិយម ក្នុងនេះមានស្ថាប័នជាច្រើនតាមឋានានុក្រម ដែលគេអាចទាក់ទងសុំការជួយឧបត្ថម្ភនៅក្នុងការដោះស្រាយទំនាស់ ។ នីតិវិធីប្តឹងតវ៉ាសំរាប់វិវាទធ្ងន់ធ្ងរដែលមិនអាចដោះស្រាយនៅមូលដ្ឋានបាន គឺមានហូរហែររហូតទៅដល់ថ្នាក់ជាតិនៅភ្នំពេញ ។ ប៉ុន្តែ លោកស្រី Ebihara បានគូសបញ្ជាក់ថា នីតិវិធីផ្លូវការបែបនេះ គេប្រើប្រាស់តែក្នុងករណីពិសេសៗបំផុតប៉ុណ្ណោះ ។ លោកស្រីសង្កត់ធ្ងន់ពីសារៈសំខាន់នៃភូមិ ក្នុងការដោះស្រាយទំនាស់ក្រៅផ្លូវការ គឺមានការផ្តល់ធនធានខាងសិទ្ធិអំណាច (គឺអ្នកធំដែលគេគោរព) និងជាពិសេស ស្តង់ដានៃឥរិយាបថដែលត្រូវបានកសាងឡើង នឹងផ្សព្វផ្សាយចេញតាមរយៈសកម្មភាពជាក់ស្តែងផ្សេងៗក្នុងសង្គម ដូចជា ការនិយាយចចាមអារាម និងការផាត់ចេញពីសង្គម ។

*លើសពីនេះទៀត យន្តការក្រៅផ្លូវការផ្សេងៗនៃការត្រួតត្រារបស់សង្គម ដូចជា ពាក្យខ្សឹបខ្សៀវ និងការផាត់ចេញជាដើម វាអាចជួយទប់ទល់អោយប្រជាជនស្ថិតនៅក្នុងគន្លងសីលធម៌ បានប្រសើរជាងការប្រើប្រាស់កំលាំងប៉ូលីស ឬតុលាការទៅទៀត (ជាក់ស្តែងប្រជាជនច្រើនចៀសវាងការឡើងតុលាការ)*[១៦] ។

លោក ប៊ិត សៀងលីម បានសរសេរដូចខាងក្រោម អំពីសារៈសំខាន់នៃពាក្យខ្សឹបខ្សៀវ និងការផាត់ចេញក្នុងលក្ខណៈជាការដាក់ទណ្ឌកម្មរបស់សង្គមក្នុងភូមិៈ

*បើសិនជាឥរិយាបថវាឃ្លាតចេញពីលំនាំដែលគេអាចទទួលយកបាន, សមាជិកឯទៀតក្នុងសង្គម កំរនឹងត្រូវការធ្វើសកម្មភាពដោយផ្ទាល់ណាស់ ។ ពាក្យខ្សឹបខ្សៀវ និងពាក្យចចាមអារាម ត្រូវបានគេប្រើប្រាស់ក្នុងសង្គមធ្វើជា*

---

១២ Ebihara, *op. cit.,* p. 364
១៣ Ibid., p.366
១៤ Ebihara (1968), *Svay, a Khmer Village in Cambodia*, Doctoral thesis (Columbia University) p. 512
១៥ Ebihara "Intervillage," *op. cit.,* p. 366
១៦ Ibid., p.370

*មធ្យោបាយដ៏សក្តិសិទ្ធិ ឬជួនកាលដ៏មានគ្រោះថ្នាក់ ដើម្បីបង្ហាញការមិនពេញចិត្តចំពោះបុគ្គលណាមួយ ហើយនេះជាលក្ខណៈទូទៅមួយ (ដែលអាចរីករាលដាលខ្លាំង) នៅក្នុងសង្គម ទាំងនៅទីក្រុង និងនៅជនបទ ។ អន្តរកម្មក្រៅផ្លូវការក្នុងសង្គម អាចដកចេញវិញបាន លុះណាតែបុគ្គលជាមុខសញ្ញាអាចទប់ខ្លួនមិនបន្តប្រកាន់ឥរិយាបថប្រមាថបំពាន ឬអាចបង្ហាញបានថា នឹងកែ/ជួសជុលកំហុសវិញ*[១៧] ។

សំរាប់អ្នកស្រែដែលមានកម្មសិទ្ធិ ឬមានសិទ្ធិត្រួតត្រាដីធ្លីរបស់ខ្លួន កំហិតផ្សេងៗលើសកម្មភាពរបស់ពួកគេ គឺមានតិចតួចបំផុត ។ លោក Vickery បានលើកឡើងថា នៅកម្ពុជា ប្រព័ន្ធក្នុងភូមិ ឬប្រព័ន្ធគ្រួសារ មានលក្ខណៈទន់ខ្សោយខ្លាំងណាស់ បើធៀបនឹងប្រទេសចិន វៀតណាម ឬឥណ្ឌា ។ ដូច្នេះហើយៈ

*វិន័យរួមដាក់លើបុគ្គល ដោយក្រុមគ្រួសារធំ ឬប្រព័ន្ធក្នុងភូមិ មានលក្ខណៈទន់ខ្សោយ ហើយនៅពេលដែលបុគ្គលបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះរដ្ឋ ដូចជាពន្ធដារ ឬកំនែនរួចហើយ គឺមានកំហិតតិចតួចណាស់ចំពោះសកម្មភាពរបស់បុគ្គលនោះ ។ ដូច្នេះអាចមានស្ថានការណ៍ដ៏ចំរូងចំរាស់មួយ គឺវត្តមាននៃសេរីភាពបែបអនាធិបតេយ្យរបស់បុគ្គលនៅក្នុងសង្គមមួយដែលគ្មានសេរីភាពតាមផ្លូវការសោះ*[១៨] ។

ជាក់ស្តែង គេឃើញមានចំណុចខុសគ្នារវាងរបាយការណ៍នានាស្តីពីជីវភាពក្នុងសម័យមុនសង្គ្រាម ។ របាយការណ៍ខ្លះទៀត បានលើកសំនួរអំពីកំរិតត្រួតត្រារបស់សង្គមទៅលើឥរិយាបថបុគ្គលនៅក្នុងភូមិ និងរបៀបរបបអនុវត្តការត្រួតត្រានេះ ព្រមទាំងបានផ្តល់មតិថា ប្រភពអំណាចនៅក្នុងគ្រួសារ និងក្នុងសង្គមជាតិ មិនមែនជាសេចក្តីគោរពដែលគេបានផ្តល់ឱ្យដោយសេរីនោះទេ ប៉ុន្តែគឺការភ័យខ្លាច ។ លោក ប៊ិត សៀងលីម បានសរសេរថាៈ

*ការភ័យខ្លាចគឺជាកំលាំងទាញថយក្រោយមួយយ៉ាងខ្លាំងនៅក្នុងវប្បធម៌កម្ពុជា ពីព្រោះវារាំងខ្ទប់គំនិតផ្តួចផ្តើមផ្សេងៗដើម្បីធ្វើការច្នៃប្រឌិតថ្មីក្នុងវប្បធម៌ ហើយវាបានដំនើរការជាមធ្យោបាយដ៏សំខាន់នៃការត្រួតត្រាសង្គម ។ តំរូវការចៀសវាងគ្រោះថ្នាក់ដល់ខ្លួនឯង បាននាំឱ្យមានជំហរចៀសវាងទំនាស់ នៅក្នុងការដោះស្រាយចំណុចខ្វែងមតិគ្នា*[១៩] ។

ចំណុចគួរកត់សំគាល់គឺ ក្នុងអត្ថបទនេះ លោក ប៊ិត សៀងលីម មិនបានផ្តល់មតិថា ការភ័យខ្លាចវាបានកើតមានពាសពេញប្រទេសកម្ពុជាដោយសារតែសង្គ្រាមនោះទេ ។ ផ្ទុយទៅវិញគាត់មានយោបល់ថា ការភ័យខ្លាចគឺជាទិដ្ឋភាពមួយនៃអ្វីដែលគាត់ហៅថា បែបផែនចិត្តសាស្ត្រកម្ពុជា ។ ការរុញរាមិនចង់សារភាព និងដោះស្រាយទំនាស់ដោយសន្តិភាពដែលជាផលវិបាកមួយនៃការភ័យខ្លាចបាននាំឱ្យមាន "ការប្រើអំនាច" ឬ "ការបែកផ្លូវទៅទិសផ្សេង ឬការបង្កើតសម្ព័ន្ធភាពថ្មី" នៅក្នុងស្ថានការណ៍មានទំនាស់ (នេះជាយុទ្ធវិធីដែលបាននាំដល់ការបែកខ្ញែកជាបក្សពួកក្នុងសង្គម និងការប្រើហិង្សា) ។

## *៣. វិធីសាស្ត្រគ្រប់គ្រងទំនាស់នៅក្នុងភូមិ*

ការសិក្សាស្តីពីការដោះស្រាយវិវាទក្នុងភូមិ (ទើបមានតែមួយគត់រហូតមកទល់សព្វថ្ងៃ) ដែលធ្វើឡើងដោយលោក William Collins បានផ្តោតលើសារៈសំខាន់នៃប្រធានភូមិក្នុងឋានៈជាអ្នកសំរបសំរួល រវាងអ្នកភូមិដែលមានទំនាស់ និងរដ្ឋអំនាចថ្នាក់ក្រោមៗ ។ Collins បានរាយការណ៍ថា អ្នកភូមិក៏ដូចជាប្រធានភូមិ គឺចង់ឱ្យការដោះស្រាយទំនាស់ស្ថិតនៅត្រឹមកំរិតភូមិខ្លាំងណាស់ ហើយគាត់បានលើកមតិថា ភូមិគឺជាកំរិតដ៏សំខាន់មួយ សំរាប់ធ្វើវិភាគអំពីការយល់ដឹងរបស់អ្នកភូមិចំពោះសហគមន៍ខ្លួនផ្ទាល់ ។

---

១៧ Bit Seanglim (1991), The Warrior Heritage, a Psychological Perspective of Cambodian Trauma, (El Cerrito: Bit Seanglim) p. 73

១៨ Michael Vickery (1984), *Cambodia 1975-1982* (Boston: Southend Press) p. 13

១៩ Bit, *op. cit.,* p.33

ការសិក្សារបស់លោក Collins ស្តីពីការដោះស្រាយទំនាស់ និងការសិក្សារបស់លោកស្រី Carmen-Maria Lopez Vasquez ដែលផ្តោតតែលើការដោះស្រាយទំនាស់នៅមុនពេលកាត់ក្តី[២០] បានផ្តល់ពត៌មានពីដំណើរការផ្សេងៗ ដែលត្រូវបានអនុវត្តជាសំខាន់ដោយអាជ្ញាធរភូមិ និងឃុំ ។Collins បានលើកមតិថា ដំនើរការដែលប្រធានភូមិប្រើប្រាស់ក្នុងការខិតខំផ្សះផ្សារទំនាស់ គឺប្រជាជនបានដឹង-បានយល់ជាទូទៅ នៅក្នុងភូមិដែល Collins បានចុះសិក្សា ។

អ្នកសិក្សាស្រាវជ្រាវផ្សេងៗទៀតបានលើកមតិថា "ពុំមានប្រពៃណីវប្បធម៌សំរាប់ផ្សះផ្សារមតិដែលផ្ទុយគ្នា (ឬសំរាប់ទទួលស្គាល់នូវវត្តមាននៃមតិផ្ទុយគ្នា) ឬក្រឹត្យក្រមស្តីពីឥរិយាបថ សំរាប់ដោះស្រាយទំនាស់ដែលសង្គមបានទទួលស្គាល់នោះទេ"[២១] ។ លោក ប៊ិត សៀងលឹម លើកមតិថា "ក្នុងវប្បធម៌កម្ពុជា គេឃើញមានរូបភាពផ្សេងៗនៃដំណើរការដោះស្រាយទំនាស់តិចតួចណាស់"[២២] ។

ការច្របូកច្របល់នេះ មួយចំណែកអាចផុសចេញពីនិយមន័យខុសៗគ្នានៃទំនាស់ ។ វាក៏អាចឆ្លុះបញ្ចាំងពីរបៀបរបបអនុវត្តផ្សេងៗគ្នានៅតាមភូមិ និងតាមសម័យឬតំបន់ខុសៗគ្នានៃប្រទេសកម្ពុជា ។ លើសពីនេះទៀត វាអាចឆ្លុះបញ្ចាំងពីការយល់ដឹងខុសៗគ្នាពីអ្វីដែលហៅថា "ដំណើរការ" ។ ការយល់ដឹងពីដំណើរការថា វាមានរួមបញ្ចូលនូវបែបបទផ្សេងៗក្នុងកិរិតណាមួយ ឬក៏ត្រូវធ្វើអ្វីមួយជាលាយលក្ខណ៏អក្សរ, វាអាចជាឫសគល់នៃការយល់ឃើញខុសៗគ្នានេះ ។

ដើម្បីស្វែងយល់ពីគ្រប់រូបភាពនៃវិធីសាស្ត្រសំរាប់គ្រប់គ្រងទំនាស់ គេគួរប្រើពាក្យ "ដំនើរការ" នៅក្នុងន័យយ៉ាងទូលាយបំផុត ។ ដូច្នេះដំណើរការនានាដែលបានសិក្សា អាចមានតាំងពីសំពាធស្រាលៗជាប្រយោល (លើបុគ្គល) ដែលផុសចេញពីដំណើរការនិយាយខ្សឹបខ្សៀវក្នុងសង្គម និងការថ្កោលទោស ទៅដល់ការដាក់បណ្តឹងជាផ្លូវការទៅតុលាការ និងការប្រើហិង្សា ។

William Collins បានប្រើទស្សនៈនៃ "សង្គមស៊ីវិលក្នុងភូមិ" ធ្វើជាមធ្យោបាយដើម្បីស្រាវជ្រាវពីដំណើរការគ្រប់គ្រងទំនាស់ក្នុងពេលសព្វថ្ងៃ នៅក្នុងភូមិកម្ពុជានានា ។ គាត់បានឱ្យនិយមន័យ សង្គមក្នុងភូមិថាជា "ចំណែកមួយនៃសង្គមដែលស្ថិតនៅត្រង់ប្រឡោះកណ្តាលរវាងតុលាការ និងវត្ត"[២៣] ។ ការសិក្សារបស់គាត់ពីការគ្រប់គ្រងទំនាស់នៅក្នុងប្រឡោះនេះបានបង្ហាញនូវនីតិវិធីជាច្រើនដែលប្រភពធនធានចំបងៗ (គឺប្រធានភូមិនិងវត្ត) បានប្រើប្រាស់ដើម្បីគ្រប់គ្រងទំនាស់នៅក្នុងភូមិ[២៤] ។

ក្នុងការប្រើប្រាស់គំរូនេះ Collins បានផ្តោតលើបុគ្គល និងស្ថាប័នជាច្រើន ប៉ុន្តែគាត់បាននិយាយពីរចនាសម្ព័ន្ធសំរាប់គ្រប់គ្រងទំនាស់តិចតួចទេ ។ គាត់បានរៀបរាប់ពីនីតិវិធីនានាដែលអ្នកគ្រប់គ្រងទំនាស់បានប្រើប្រាស់ និងមានរួមបញ្ចូលនូវគំនូសយ័ន្ត និងពិធីផ្សេងៗ និងការលើកពីស្តង់ដានានារបស់សហគមន៏ ដើម្បីធ្វើអោយគូភាគីសុខចិត្តប្រណិប័តន៏តាម ប៉ុន្តែគាត់បានយកចិត្តទុកដាក់ជាសំខាន់លើការដោះស្រាយទំនាស់បែបសកម្ម ជាជាងលើ "វប្បធម៌សន្តិភាព" ដែលមានន័យយ៉ាងទូលំទូលាយនោះ ។ ទស្សនៈរបស់លោក Collins ស្តីពីភូមិ និងធនធានសំរាប់គ្រប់គ្រងទំនាស់ក្នុងភូមិ អាចបង្ហាញជាក្រាហ្វិកដូចខាងក្រោម:

---

២០ Carmen-Maria Lopez Vasquez (1996), *Pre-Trial Dispute Resolution Processes,* (Phnom Penh: Court Training Project)

២១ Jan Ovesen, Ing-Britt Trankell & Joakim Ojendal (1996), *Where Every Household is an Island: Social Organization and Power Structures in Rural Cambodia,* Uppsala Research Reports in Cultural Anthropology No. 15 (Uppsala: University of Uppsala Dept. of Cultural Anthropology) p. 42

២២ Bit, *op. cit.*, p. 33

២៣ Collins, *op. ciy.*, p. 6

២៤ Ibid

*ក្រាហ្វិកបង្ហាញពី គំរូរបស់លោក Collins ស្តីពីសង្គមស៊ីវិលក្នុងភូមិ*




ការប្រកាន់យកទស្សនៈទូលាយ បាននាំដល់វិធីសាស្ត្រសិក្សាពីការគ្រប់គ្រងទំនាស់មួយដែលមិនគ្រាន់តែផ្តោតលើសកម្មភាពចំហនានាសំដៅដោះស្រាយវិវាទប៉ុណ្ណោះទេ ប៉ុន្តែពិនិត្យផងដែរពីសកម្មភាពផ្សេងៗដែលមានដំណើរការយ៉ាងទូលំទូលាយ ដើម្បីជួយកសាងទំនាក់ទំនងរវាងអ្នកភូមិ ហើយការសិក្សានេះបានផ្តល់ឱ្យដំណើរការគ្រប់គ្រងទំនាស់នូវកំលាំង និងលក្ខណៈពេញច្បាប់នៅក្នុងចិត្តគំនិតរបស់ប្រជាជន ។ តួនាទីរបស់បុគ្គលឯទៀតៗក្រៅពីប្រធានភូមិ ក៏អាចមានសារៈសំខាន់ក្នុងរឿងនេះ ហើយ Collins បានលើកថា អាចារ្យអាចជួយបានខ្លះដែរ ក្នុងករណីមានទំនាស់ គឺមិនមែនតាមការប្រឹងប្រែងដោះស្រាយផ្ទាល់ទេ ប៉ុន្តែតាមការខិតខំប្រើឥទ្ធិពលទៅលើឥរិយាបថនៃគូភាគីក្នុងទំនាស់ និងលើកកំពស់ជំហរអហិង្សា ការអាណិតអាសូរ និងអត់ឱន ។

តួអង្គឯទៀតៗដែលមានតួនាទីពិសេសៗនៅក្នុងភូមិ ក៏អាចមានឥទ្ធិពលទៅលើបែបបទដែលបុគ្គលនានាមានចំណាប់អារម្មណ៍អំពីទំនាក់ទំនងរបស់ខ្លួនជាមួយនឹងមនុស្សឯទៀតក្នុងក្រុមដែរ ។ តួអង្គទាំងនេះមានជាអាទិ៍ មេខ្យល់ (អ្នកដឹកនាំគំរោងបណ្តោះអាសន្នដែលជាញឹកញយច្រើនជាប់ទាក់ទិននឹងគណៈកម្មការវត្ត) និងគ្រូខ្មែរ ឬគ្រូពេទ្យបុរាណ ។ ការសិក្សាមួយបានកត់សំគាល់ថា ក្នុងបរិបទនៃវិជ្ជាពេទ្យបុរាណៈ

> *ដោយលក្ខណៈតាមបែបវប្បធម៌នៃការពន្យល់ពីមូលហេតុជំងឺ ជាញឹកញយការពន្យល់នេះ មានន័យសឹងតែដូចគ្នានឹងការបដិសេធ ការភ័យខ្លាច ការផាត់ចេញ និងការខ្មាសអៀន ហើយសំខាន់ជាងគេគឺ "កម្មអាក្រក់" ។ រឿងនេះធ្វើឱ្យពេទ្យបុរាណ ឬ "គ្រូ" មានជំហររឹងមាំក្នុងសង្គម ពីព្រោះពួកគាត់មានអំនាច "បញ្ចូល" អ្នករងគ្រោះទៅក្នុងសង្គមវិញ... ។ សកម្មភាពព្យាបាលមានលក្ខណៈជានិមិត្តរូប ហើយបានអនុវត្តដោយចំហជាសាធារណៈ"*[២៥] ។

ការប្រើវិជ្ជាពេទ្យបុរាណ ជាមធ្យោបាយសំរាប់កែតំរូវទំនាក់ទំនង រវាងបុគ្គល និងសហគមន៍ បានផ្តល់គំនិតថា ការអនុវត្តន៍បែបនេះក៏អាចមានឥទ្ធិពលទៅលើឥរិយាបថចំពោះទំនាស់ និងការគ្រប់គ្រងទំនាស់ផងដែរ ។

ទោះបីគំរូរបស់ Collins វាមានប្រយោជន៍នៅក្នុងបរិបទនៃការសិក្សាពីដំបូងៗ ប៉ុន្តែវាមិនសមស្របទេ សំរាប់ការពិនិត្យមើលយ៉ាងទូលំទូលាយពីដំណើរការគ្រប់គ្រងទំនាស់ ពីព្រោះទស្សនៈនៃ "សង្គមស៊ីវិល" ត្រូវបានប្រើប្រាស់តាមវិធីមួយដែលយកចិត្តទុកដាក់តែបន្តិចបន្តួចអំពីចំណុចខុសគ្នាផ្សេងៗដែលផុសចេញពីរឿងវណ្ណៈ តួនាទីបុរសស្ត្រី ឬឋានៈក្នុងភូមិ ។

២៥ Brown, *op. cit.*, p. 10

ការសិក្សាដ៏មានឥទ្ធិពលរបស់លោក Scott អំពីទំនាក់ទំនងអំណាចនៅក្នុងសហគមន៍តាមភូមិ ដែលមានចំណងជើងថា Weapon of the Weak (អាវុធរបស់អ្នកទន់ខ្សោយ) បានយកចិត្តទុកដាក់ពន្យល់យ៉ាងល្អិតល្អន់នូវភាពតានតឹងបង្កប់ ដែលកើតមានឡើងរវាងវណ្ណៈនានានៅក្នុងភូមិមួយដែលកំពុងឆ្លងកាត់ការផ្លាស់ប្តូរខាងសេដ្ឋកិច្ច ។ ការសិក្សារបស់ Scott ផ្អែកទៅលើភូមិមួយ (នៅម៉ាឡេស៊ី) ដែលកំរមានទំនាស់ជាចំហាណាស់ ទោះបីជាមានការប្រែប្រួលយ៉ាងលឿននៅក្នុងរបៀបរបបធ្វើកសិកម្ម បានធ្វើឱ្យមានការឱ្យផ្លាស់ប្តូរគួរឱ្យកត់សំគាល់ក្នុងទំនាក់ទំនងរវាងអ្នកមាន និងអ្នកក្រនៅក្នុងភូមិក៏ដោយ ។ ក្នុងការស្រាវជ្រាវថាហេតុអ្វីបានជាគ្មានការផ្ទុះចេញនូវទំនាស់ចំហ លោក Scott បានពិនិត្យពីបែបបទរបស់អ្នកក្រ ដែលជាអ្នកចាញ់គេនៅក្នុងដំណើរការផ្លាស់ប្តូរនេះ ត្រូវបានរារាំងមិនឱ្យប្រឆាំងជាចំហចំពោះរបៀបរបបក្នុងភូមិ ។ Scott បានរកឃើញថា កត្តាដ៏សំខាន់បំផុតមួយដែលជំរុញឱ្យមានការចៀសវាងទំនាស់ គឺបណ្តាញទំនាក់ទំនងខាងផ្លូវសីលធម៌រវាងអ្នកមាន និងអ្នកក្រក្នុងភូមិ ។ ការងាររបស់ Scott និងការងាររបស់ Pierre Bourdieu នៅប្រទេសអាល់ហ្សេរី បានផ្តល់គំនិតថា តំរូវការខាងសីលធម៌បានបន្ធូរបង្អាក់ទំនាស់ ពីព្រោះសុខុមាលភាពខាងសេដ្ឋកិច្ចរបស់បុគ្គលនៅក្នុងសហគមន៍ដ៏តូចមួយ វាពឹងផ្អែកក្នុងកំរិតទាបទេទៅលើទំនាក់ទំនងទីផ្សារដែលមានលក្ខណៈអបុគ្គល ប៉ុន្តែវាពឹងផ្អែកច្រើនជាងទៅលើទំនាក់ទំនងខាងឋានៈ និងការទុកចិត្តគ្នារវាងបុគ្គលនៅក្នុងភូមិ ។

ឧទាហរណ៍នានាដែលស្រង់ចេញពីឯកសារស្តីពីកម្ពុជា វាមានប្រយោជន៍សំរាប់ការស្វែងយល់ពីទស្សនៈនៃអំណាច និងទំនាក់ទំនងក្នុងសហគមន៍ ។ ក្នុងការសិក្សារបស់ Collins ភូមិដែលត្រូវបានគេលើកយកមកពិនិត្យ ហាក់ដូចជាវានៅដាច់ដោយឡែកពីពិភពខាងក្រៅ ។ គេមើលឃើញពិភពលោកខាងក្រៅថាគួរឱ្យភ័យខ្លាច ហើយសមត្ថភាពចាត់ចែងជាមួយពិភពខាងក្រៅត្រូវបានសំគាល់ថា មានសារៈសំខាន់ជានិមិត្តរូប មិនមែនមានផលប្រយោជន៍ជាក់ស្តែងទេ ។ គាត់មើលឃើញថា ការជ្រៀតចូលរបស់ពិភពខាងក្រៅ ជាពិសេសការច្រៀតចូលរបស់រដ្ឋ បានផ្តល់អំណាចជានិមិត្តរូបមួយដល់អ្នកដឹកនាំភូមិក្នុងកិច្ចប្រឹងប្រែងដោះស្រាយវិវាទរបស់ពួកគេ ។

> *ការបានដឹងពីបែបបទប្រកាន់តំរិយាបថឱ្យបានសមស្របនៅក្នុងមជ្ឈដ្ឋាននានានៅជុំវិញសង្គមស៊ីវិលក្នុងភូមិ នឹងធ្វើឱ្យគេមានឥទ្ធិពលនៅក្នុងសហគមន៍ ។ ដូច្នេះហើយ អ្នកដែលមានការយល់ដឹងពីរបៀបរបបប្រកាន់តំរិយាបថ ត្រឹមត្រូវដើម្បីឆ្លងកាត់ព្រំប្រទល់នៃវប្បធម៌នានា ក៏អាចបំពេញតួនាទីជាអ្នកសំរុះសំរួលបានដែរ*[២៦] ។

លោក Collins បានអះអាងថា អំណាចដែលបានផ្តល់ឱ្យ គឺជារូបភាពមួយនៃអំណាចដែលមានលក្ខណៈជានិមិត្តរូប ឬ "វេទមន្ត" ហើយផុសចេញពីឋានៈ និងសេចក្តីគោរពដែលគេបានប្រគល់ដល់អ្នកណាដែលសហគមន៍យល់ថា អាចផ្តល់ចំណេះធ្វើ (know-how) សំរាប់ជួយការពារ និងជួយសំរួលដល់សហគមន៍នៅក្នុងទំនាក់ទំនងការងារផ្សេងៗជាមួយនឹងអង្គការចាត់តាំងដ៏គួរឱ្យខ្លាចរបស់រដ្ឋ ។ Collins បានរៀបរាប់ពីរឿងមួយដែលក្នុងនោះ មេឃុំបានតំរូវឱ្យជនពាលម្នាក់ធ្វើកិច្ចសន្យាមួយថានឹងកែប្រែខ្លួន ។ Collins បញ្ជាក់ថា:

> *កិច្ចសន្យាហាក់ដូចជាមានតួនាទីដាស់ស្មារតីសហគមន៍ទាំងមូលថា រឿងរ៉ាវវាកាន់តែធ្ងន់ធ្ងរឡើងហើយ ព្រមទាំងកេណ្ឌសហគមន៍ ឱ្យគាបសង្កត់លើជនល្មើសឱ្យកែប្រែតំរិយាបថ ។ ឯកសារជាលាយលក្ខណ៍អក្សរដែលតំណាងឱ្យនីតិវិធីជាផ្លូវការជាក់ស្តែង គឺត្រូវបានប្រើប្រាស់ ដូចជាការធ្វើមន្តអាគមន៍ គំរាមឱ្យបុគ្គលកែប្រែតំរិយាបថរបស់ខ្លួន និងប្រកូកប្រកាសឱ្យសហគមន៍ជួយជ្រោមជ្រែងក្នុងរឿងនេះផង បើមិនដូច្នោះទេ ប្រជាជនរួមភូមិម្នាក់ នឹង*

២៦ Colliins, *op. cit.*, p. 8

*ត្រូវខ្ចាតចេញពីតំបន់គ្រប់គ្រងរបស់ភូមិ ចូលទៅក្នុងអាណាចក្រដ៏គ្រោះថ្នាក់នៃប៉ូលីស និងតុលាការ*[២៧] ។

ក្នុងឧទាហរណ៍នេះ Collins បានពិពណ៌នាពីអន្តរកម្មរវាងដំណើរការបីខុសៗគ្នានៃការគ្រប់គ្រងទំនាស់ដែលមានបែបបទខុសៗគ្នា គឺមានការគាបសង្កត់របស់សហគមន៍ កិច្ចសន្យាធ្វើនៅសាលាឃុំ និងកិច្ចដំណើរការរបស់តុលាការ ។ ចំណុចសំខាន់មួយគឺថាក្នុងករណីនេះ កំលាំងគាបសង្កត់របស់សហគមន៍ត្រូវការនូវចំណុចផ្តោតមួយ (ដែលត្រូវបានផ្តល់ឱ្យតាមរយៈការធ្វើពិធីចុះកិច្ចសន្យា) និងការគំរាមកំហែងក្នុងរូបភាពជាលទ្ធភាពអាចត្រូវចាប់ខ្លួន. ដើម្បីជំរុញឱ្យបុគ្គលប្រព្រឹត្តិខ្លួនឱ្យបានដូចគេដូចឯង ។ អំណាចរបស់មេឃុំ ក្នុងការដាក់ការគាបសង្កត់ទាំងបីរូបភាពទៅលើជនល្មើស ត្រូវបាន Collins សំគាល់ថា ជាភស្តុតាងបង្ហាញពីឋានៈដ៏ពិសេសរបស់មេឃុំដែលមានការយល់ដឹងពីកិច្ចការខាងក្រៅនានា ។ នៅក្នុងការសិក្សាប្រហាក់ប្រហែលគ្នាស្តីពីទំនាក់ទំនងអំណាចនៅក្នុងសហគមន៍អាល់ហ្សេរី (និងនៅសាកលវិទ្យាល័យបារាំងនានា) Pierre Bourdieu បានចាត់ទុកចំណេះធ្វើ (know-how) ដែលនាំឱ្យមានការផ្តល់ឋានៈគួរឱ្យកត់សំគាល់បែបនេះថាជា "ទុនវប្បធម៌"[២៨] ។

លោក Collins បានលើកឡើងថា នៅក្នុងភូមិ បុគ្គលដែលមានទុនវប្បធម៌ដូចខាងលើ គឺមានតិចនាក់ណាស់ ។ ប៉ុន្តែទំនាក់ទំនងជានិមិត្តរូបនៃឋានៈ និងសេចក្តីគោរព ក៏សំខាន់ដែរសំរាប់ការរស់រានមានជីវិតនៅក្នុងសហគមន៍ក្នុងភូមិ ពីព្រោះវាកំណត់នូវបែបបទទាក់ទងគ្នាចុះឡើងរវាងអ្នកភូមិខ្លួនឯង ។ រឿងនេះត្រូវបានលើកបង្ហាញនៅក្នុងរបាយការណ៍របស់ Davenport et al ស្តីពីបញ្ហានានាដែលប្រជាជនក្រីក្របំផុតនៅក្នុងភូមិ និងជនមាតុភូមិនិវត្តន៍មកពីជំរំជនភៀសខ្លួន ត្រូវប្រឈមមុខ ។ ដោយសារអវត្តមានដំយូរ ជនមាតុភូមិនិវត្តន៍ខ្វះខាតកេរ្តិ៍ឈ្មោះមាំទាំដែលត្រូវមាន ដើម្បីអាចទាញយកផលប្រយោជន៍បានពីទំនាក់ទំនងជួយគ្នាទៅវិញទៅមក និងចំណងសាមគ្គីភាពនៅក្នុងភូមិ ។

ការសិក្សាពីបទពិសោធន៍របស់ជនមាតុភូមិនិវត្តន៍បានរកឃើញថា អ្នកដែលបានទទួលការទ្រទ្រង់ពីក្រុមគ្រួសារច្រើនតែអាចធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញបានជោគជ័យ ពីព្រោះពួកគេមានលទ្ធភាពច្រើនជាង ក្នុងការប្រើប្រាស់ "បណ្តាញសង្គម" ផ្សេងៗ មានជាអាទិ៍ ការផ្តល់ពតិមាន និងជំនួយជាក់ស្តែង ដូចជាការប្រវាស់ដៃជាដើម ។ ក្នុងការអធិប្បាយពីការចាត់ទុកជាបន្ទាប់បន្សំនូវជនទើបធ្វើមាតុភូមិនិវត្តន៍ថ្មី Davenport et al បានពិភាក្សាពីបញ្ហា "ទុន" ដោយបានពិពណ៌នាពីគ្រួសារក្រីក្របំផុតនៅក្នុងភូមិដែលត្រូវ "រកមួយថ្ងៃហូបមួយថ្ងៃ ដោយមានទ្រព្យសម្បត្តិតិចតួចបំផុត" ។ សមាជិកគ្រួសារក្នុងបន្ទុកមានចំនួនច្រើនជាងអ្នកដែលអាចធ្វើការងារបាន គឺពួកគេខ្វះទាំង "ទ្រព្យធនជាពលករមានកាយសម្បទា" ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចចូលរួមក្នុងការងារជួយគ្នាទៅវិញទៅមក ជាមួយនឹងអ្នកជិតខាង ។ កង្វះទ្រព្យជាសំភារៈនាំឱ្យការចរចាខ្ចីប្រាក់ត្រូវជួបបញ្ហា ដូច្នេះ គឺគ្មានជំរើសអ្វីផ្សេងក្រៅពីដាក់បញ្ចាំទ្រព្យទេ ។

ការពិភាក្សាវែកញែកបានបន្តពិនិត្យពីសារៈសំខាន់នៃវិនិយោគលើទ្រព្យសកម្មអរូបី ដើម្បីសំរួលដល់លទ្ធភាពអាចប្រើប្រាស់បណ្តាញផ្សេងៗក្នុងសង្គមបាន ។ Davenport et al បានរាយការណ៍ថា គ្រួសារក្រីក្រប្រហែលពុំមានសាច់ញាតិ ឬមិត្តភ័ក្តិដែលមានតួនាទីល្អទេ (ដូចជាប្រធានភូមិ ឬអ្នកណាមួយដែលមានអំនាចអាចជួយពួកគេបាន) ។ ការខ្មាស់អៀនដោយសារខ្លួនពុំមានជោគជ័យក្នុងជីវិត បានរារាំងសមាជិកគ្រួសារទាំងនេះ មិនឱ្យចូលរួមក្នុងជីវភាពក្នុងភូមិ ទោះបីការចូលរួមនេះអនុញ្ញាតឱ្យពួកគេប្រមូលបានពតិមានដែលអាចបំផុសនូវគំនិតល្អៗសំរាប់កែលំអជីវភាពក៏ដោយ ។ ប្រព័ន្ធជួយគ្នាទៅវិញទៅមកជាច្រើនដែលជាមូលដ្ឋាននៃការធានាសុខុមាលភាពនៅក្នុងភូមិកម្ពុជា គឺជា "ការដោះដូរទំនិញ និងសេវាដោយផ្អែកលើការទុកចិត្ត" ។ គ្រួសារថ្មីៗ ឬគ្រួសារមានកេរ្តិ៍ឈ្មោះមិនល្អក្នុងភូមិ ប្រហែលត្រូវផាត់ចេញពីប្រព័ន្ធទាំងនេះហើយ[២៩] ។

---

២៧ Collins, *op. cit.*, p. 17

២៨ Pierre Bourdieu (1994), "Structures, Habitus, Power: Basis for a Theory of Symbolic Power," in Nicholas B. Dirks, Geoff Eley & Sherry B. Ortner (eds.), *Culture/Power/History, A Reader in Contemporary Social History* (Princeton: Princeton UP).

២៩ Davenport et al., *op. cit.*, p. 67

តាមមូលហេតុដូចខាងលើ ទុនពីរប្រភេទទៀតមានសារៈសំខាន់សំរាប់ការសិក្សាពីទំនាក់ទំនងសង្គមនៅក្នុងភូមិ ។ "ទុនសង្គមកិច្ច" គឺជាវិនិយោគធ្វើឡើងដោយសហគមន៍ទាំងមូលក្នុងការកសាងចំណងទាក់ទង និងរបៀបរបបធ្វើសហប្រតិបត្តិការដែលនឹងអាចជួយធានាដល់សន្តិសុខ និងផលិតភាព សំរាប់គ្រប់ៗគ្នា ។ "ទុននិមិត្តរូប" គឺជាវិនិយោគធ្វើឡើងដោយ បុគ្គល ឬគ្រួសារ ក្នុងការកសាងកេរ្តិ៍ឈ្មោះដែលនឹងផ្តល់លទ្ធភាពឱ្យប្រើប្រាស់បណ្តាញទុនសង្គមកិច្ចបាន ។

ចំណងទាក់ទងជាមួយក្រុមគ្រួសារ និងមិត្តភ័ក្តិ លទ្ធភាពទទួលបានពតិមាន និងកេរ្តិ៍ឈ្មោះដែលអនុញ្ញាតឱ្យទទួលបាននូវអត្ថប្រយោជន៍ពីប្រព័ន្ធជួយគ្នាទៅវិញទៅមក អាចចាត់ទុកជាទុនបានក្នុងន័យនេះ ។ ការយោងដល់រចនាសម្ព័ន្ធក្រៅផ្លូវការទាំងនេះ អាចជួយពន្យល់ពីសេចក្តីសន្និដ្ឋាន (បង្ហាញនៅខាងក្រោម) នៃការសិក្សាមួយស្តីពីស្ថានភាពទាហានរំសាយដែលត្រឡប់ទៅភូមិវិញ ។ អ្នកភូមិនៅកន្លែងតាំងលំនៅរបស់ជនមាតុភូមិនិវត្តន៍នៅខេត្តបាត់ដំបង និងសៀមរាប បានប្រាប់អ្នកស្រាវជ្រាវថា:

> *ចំណុចខុសគ្នាជាគន្លឹះគឺថា តើទាហានគឺជាប្រជាជនចេញពីភូមិនេះទៅ ឬក៏មិនមែន ។ បើសិនគេជាប្រជាជនចេញពីភូមិនេះ ការត្រឡប់មកវិញមិនចោទបញ្ហាអ្វីទេ ពីព្រោះគាត់មានផ្ទះ និងសាច់ញាតិជួយថែទាំគាត់ ។ ទោះបីគាត់គ្មានដីធ្លីក៏ដោយ ក៏គាត់អាចធ្វើការជាមួយគ្រួសារផ្សេងទៀតដែលធ្លាប់ស្គាល់គ្រួសារគាត់ ។ ប៉ុន្តែចំពោះទាហានដែលចេញពីភូមិផ្សេង គឺមិនគួរមកភូមិនេះទេ ពីព្រោះគ្មានដីធ្លី គ្មានការងារ និងគ្មានអ្នកណាសំរាប់ពឹងពាក់សោះ*[៣០] ។

ក្នុងករណីនេះ ទុនអរូបីដែលជាកេរ្តិ៍ឈ្មោះល្អរបស់ក្រុមគ្រួសារ នឹងជួយទាហានដែលវិលត្រឡប់មកភូមិវិញឱ្យរកការងារធ្វើបាន ។ រចនាសម្ព័ន្ធក្រៅផ្លូវការនៃទុនបែបនេះ គឺជាទិដ្ឋភាពមួយយ៉ាងសំខាន់នៃទំនាក់ទំនងដែលមានដំណើរការជាក់ស្តែងនៅក្នុងភូមិ ។

សរុបមក ប្រភេទផ្សេងៗនៃទុន អាចចាត់ទុកថាមានសារៈសំខាន់ជាសារវន្តសំរាប់ការរស់រានមានជីវិត នៅក្នុងសហគមន៍ក្នុងភូមិ ។ ចំពោះទុនប្រភេទខុសៗគ្នាទាំងនេះ គេអាចកំណត់និយមន័យដូចខាងក្រោម:

*ទុនសេដ្ឋកិច្ច:* ធនធានសេដ្ឋកិច្ចជាទ្រព្យដូចជា ដីធ្លី និងប្រាក់កាស ជាដើម ។

*ទុនសង្គមកិច្ច:* ទុននេះមិនមែនជាផលិតផលរបស់បុគ្គលណាម្នាក់ទេ ប៉ុន្តែជារបស់ក្រុមទាំងមូល ព្រោះវាជាការវិនិយោគរួមគ្នានៅក្នុងសកម្មភាព និងជំហរធ្វើសហប្រតិបត្តិការនៅក្នុងសហគមន៍ណាមួយ ។ ទុនសង្គមកិច្ចតំណាងឱ្យទ្រព្យសកម្មមួយប្រភេទដែលជួយបង្កើនផលិតភាពជាទូទៅរបស់សហគមន៍ ។ លោក Krishnamurthy បានញែកចេញពីគ្នារវាងទិដ្ឋភាព "រចនាសម្ព័ន្ធ" និង "គំរិតយល់ដឹង" នៃទុនសង្គមកិច្ច ។ ទិដ្ឋភាព *រចនាសម្ព័ន្ធ* អាចឱ្យយើងពិនិត្យទុនសង្គមកិច្ចក្នុងរូបភាពដែលអាចមើលឃើញជាក់ស្តែង ដូចជា ព្រឹត្តិការណ៍ ទំនាក់ទំនង បណ្តាញ សមាគម... ។ ទិដ្ឋភាពគំរិត *យល់ដឹង* មានរួមបញ្ចូលនូវតំលៃជាវិជ្ជមាននានា ដូចជា ការបញ្ចោខ្លួនឯង សហប្រតិបត្តិការ បដិការ (reciprocity), ការពឹងផ្អែកគ្នាទៅវិញទៅមក ការសំរបសំរួល សប្បុរសធម៌ បរត្ថភាព (altruism) "អំពើល្អ" ការអត់ធ្មត់ ទំនុកចិត្ត ភក្តីភាព...[៣១] ។

*ទុនជានិមិត្តរូប:* ទុននេះសំដៅដល់ "កិត្យានុភាព និងកេរ្តិ៍ឈ្មោះដែលផ្សារភ្ជាប់នឹងគ្រួសារ ឬឈ្មោះណាមួយ" ។ Bourdieu បានកត់សំគាល់ថា ទុនបែបនេះអាច "ប្រែក្លាយភ្លាមៗបានជាទុនសេដ្ឋកិច្ច" ពីព្រោះទំនាក់ទំនងល្អជាមួយអ្នកដទៃមានសារៈសំខាន់ណាស់សំរាប់ជោគជ័យខាងសេដ្ឋកិច្ច ។ Bourdieu បានចាត់ទុកទុននិមិត្តរូបជា "រូបភាពមួយដ៏មានតំលៃបំផុតនៃទុនសន្សំទុកនៅក្នុងសង្គមមួយ ដែលក្នុងនោះធាតុអាកាសដ៏យ៉ាប់យ៉ឺន... និងធនធានមិនគ្រប់គ្រាន់ទាមទារឱ្យ

៣០ Prum Sam Ol et al.., *op. cit.*, p. 25

៣១ Veena Krishnamurthy (1999), The Impact of Armed Conflict on Social Capital, a Study of Two Villages in Cambodia (Phnom Penh: Social Services of Cambodia) p.2

មានការធ្វើពលកម្មរួមគ្នា" [៣២] ។

Davenport et al. បានរៀបរាប់ពីការលំបាករបស់អ្នកស្រាវជ្រាវក្នុងការប្រមូលពត៌មានស្តីពីរចនាសម្ព័ន្ធបែបនេះ :

*"អាជ្ញាធរ" ភូមិ មានទស្សនៈមិនសូវល្អទេចំពោះរចនាសម្ព័ន្ធក្រៅផ្លូវការ ពីព្រោះវាស្ថិតនៅក្រៅប្រព័ន្ធផ្លូវការ... ។ ប្រជាជនមិនសូវចង់និយាយពីរឿងនេះទេ ។ បើអ្នកមិនបានស្នាក់នៅក្នុងភូមិ អ្នកមិនអាចរកឃើញរចនាសម្ព័ន្ធនេះឡើយ ។ ប៉ុន្តែពួកអ្នកធ្លាប់ស្នាក់នៅតាមភូមិបានបញ្ជាក់ថា រចនាសម្ព័ន្ធទាំងនេះកំពុងតែរីកដុះដាលយ៉ាងជាក់ស្តែង* [៣៣] ។

របាយការណ៍ អំពីសារៈសំខាន់នៃរចនាសម្ព័ន្ធក្រៅផ្លូវការនៃការជួយគ្នាទៅវិញទៅមក ដោយសារការមានទុនអរូបី គឺមានប្រយោជន៏ច្រើនសំរាប់ការសិក្សាពីទំនាស់ និងការដោះស្រាយទំនាស់ ។ បុគ្គលដែលយកចិត្តទុកដាក់ធ្វើវិនិយោគលើទុននិមិត្តរូប នឹងពិនិត្យឃើញថា ការយកចិត្តទុកដាក់បែបនេះ វារារាំងដល់ការប្រកាន់ឥរិយាបថនៅក្នុងស្ថានការណ៏មានទំនាស់ និងការងារគ្រប់គ្រងទំនាស់របស់ពួកគេ ។ ការវិភាគនេះ គឺជួយបំភ្លឺពីសារៈសំខាន់នៃ "ការនិយាយខ្សឹបខ្សៀវ" "ការផាត់ចេញ" និង "ពាក្យចចាមអារាម" ក្នុងលក្ខណៈជាមធ្យោបាយត្រួតពិនិត្យខាងសង្គមកិច្ច ដូចដែលលោកស្រី Ebihara និងលោក Bit បានរៀបរាប់ ។ ការនិយាយខ្សឹបខ្សៀវ ការផាត់ចេញ និងពាក្យចចាមអារាម វាមានប្រយោជន៏សំរាប់ការកំណត់ពីកិរិតនៃទុននិមិត្តរូបដែលបុគ្គលណាមួយមានជាក់ស្តែង ។ Scott បានចង្អុលបង្ហាញថា ប្រភេទទុននិមិត្តរូបដែលគេវិនិយោគ វាប្រែប្រួលទៅតាមវណ្ណៈ និងភេទ ។ សំរាប់អ្នកក្រ ការរក្សាកេរ្តិ៍ឈ្មោះល្អអំពីជំហរខិតខំធ្វើការងារ ភក្តីភាព និងភាពទៀងត្រង់ វាមានសារៈសំខាន់ជាសារវន្តសំរាប់ការពារប្រភពមានការងារធ្វើ និងជំនួយឧបត្ថម្ភផ្សេងៗ [៣៤] ។

សំរាប់អ្នកដឹកនាំភូមិ ការរក្សាកេរ្តិ៍ឈ្មោះល្អមានសារៈសំខាន់ជាសារវន្តសំរាប់ការអនុវត្តន៏សិទ្ធិអំណាច ។ Ebihara បានលើកថា ឥទ្ធិពលរបស់ "អ្នកធំ" ផុសចេញពីការដែលអ្នកផងយល់ថា អ្នកនោះមាន "ចរិយាល្អវិសេស" ការវិនិច្ឆ័យត្រឹមត្រូវ និងមានបុគ្គលិកលក្ខណៈរឹងប៉ឹង ដូច្នេះហើយក៏ផ្តល់ឱ្យបុគ្គលនោះនូវ "កិត្យានុភាពវិសេស និងសិទ្ធិអំណាចមួយចំនួននៅលើការងារក្នុងភូមិ" [៣៥] ។ ដើម្បីរក្សាតំណែងនេះ គេត្រូវប្រឹងប្រែងជាប្រចាំធ្វើវិនិយោគលើកេរ្តិ៍ឈ្មោះ ហើយលទ្ធភាពរបស់អ្នកភូមិដើម្បីដកការគោរពរាប់អានចេញវិញតាមរយៈការនិយាយខ្សឹបខ្សៀវ ការផាត់ចេញ និងពាក្យចចាមអារាមតៗគ្នា គឺជាកំហិតមួយចំពោះអំណាចរបស់អ្នកដឹកនាំភូមិ (នេះជាសំលេង "ប្រជាធិបតេយ្យមួយប្រភេទនៅក្នុងបរិបទមួយដែលអំណាច និងការបង្ក្រាបជាយថាហេតុ បានធ្វើឱ្យអំពើខ្វះការគោរពកោតខ្លាចផ្សេងៗអាចជួបគ្រោះថ្នាក់") [៣៦] ។ រឿងនេះគឺជាបញ្ហាមួយយ៉ាងសំខាន់សំរាប់ស្វែងយល់ពីទំនាក់ទំនងក្នុងភូមិ ហើយអាចជាប់ទាក់ទិនយ៉ាងខ្លាំងទៅនឹងការយល់ដឹងពីរបៀបរបបដែលបុគ្គលម្នាក់ៗក្នុងភូមិ សុខចិត្តដើរតាមគោលការណ៏គ្រប់គ្រងទំនាស់ និងពីបែបបទដែលទំនាស់ត្រូវបានបន្ត ។

## *៤. ស្តង់ដា រចនាសម្ព័ន្ធ និងស្ថាប័ន នៅក្នុងទំនាក់ទំនងក្នុងសហគមន៏*

ការសិក្សាពីវិនិយោគរបស់បុគ្គល និងក្រុមនៅក្នុងទុនប្រភេទផ្សេងៗ វាជួយបង្កើនការយល់ដឹងពីវប្បធម៌សន្តិភាព ដោយឆ្លើយនឹងសំនួរស្តីពីរចនាសម្ព័ន្ធ និងស្ថាប័ន ។ នៅក្នុងរយៈពេលមានទំនាស់ គេអាចពិនិត្យឃើញពីយុទ្ធសាស្ត្ររបស់បុគ្គលក្នុងការវិនិយោគលើទុនទាំងនេះ និងអាចស្រាវជ្រាវពីប្រតិកម្មរបស់បុគ្គលនៅក្នុងកាលៈទេសៈដ៏ជាក់លាក់មួយ ។ បើសិនចរិតទុនដែលត្រូវបានវិនិយោគ វាអំណោយផលដល់សន្តិភាព វប្បធម៌សន្តិភាព គឺងាយនឹងកើតមានឡើង ហើយរបបរួមនៃការត្រួត

---

៣២ Bourdieu, *op. cit.,* p. 174

៣៣ Davenport et al., *op. cit.,* p. 60

៣៤ Scott discusses this at length in his *Weapons of the Weak, op. cit.,* p. 241-303

៣៥ Ebihara (1971), "Intervillage, Intertown and Village-City Relations in Cambodia" *Annals of the New York Academy of Sciences* p. 360/1

៣៦ Scott, Weapons of the Weak, op. cit., p. 282

គ្រារបស់សង្គម ក៏ប្រហែលមានប្រសិទ្ធិភាពក្នុងការចៀសវាងអំពើហិង្សា ។ ឧទាហរណ៍ បើសិនកេរ្តិ៍ឈ្មោះពីការអត់ឱន ជួយឱ្យមានឥទ្ធិពល និងឋានៈ ដូច្នេះវិនិយោគលើកេរ្តិ៍ឈ្មោះបែបនេះដោយគូភាគីក្នុងទំនាស់ ប្រហែលជួយឱ្យការសំរុះសំរួលទំនាស់បានទទួលជោគជ័យ ។ ប៉ុន្តែបើសិនជាគេឱ្យតំលៃខ្ពស់ដល់កេរ្តិ៍ឈ្មោះខាងជំហររឹងវិញ ដូច្នេះការប្រឹងប្រែងវិនិយោគក្នុងកេរ្តិ៍ឈ្មោះបែបនេះ អាចធ្វើឱ្យទំនាស់កាន់តែធ្ងន់ធ្ងរឡើង ព្រមទាំងកាត់បន្ថយជំរើសក្នុងការគ្រប់គ្រងទំនាស់ផង ។ ក្នុងភូមិនិមួយៗប្រហែលមានទស្សនៈច្រើនបែបយ៉ាងនៅលាយឡំគ្នាក្នុងពេលតែមួយ ឧទាហរណ៍ អាចមានបុគ្គលម្នាក់ត្រូវបានគេគោរពដោយសារកំលាំងរបស់គាត់ ហើយមានម្នាក់ទៀតបានទទួលការគោរពដោយសារការអត់ឱន និងជំហរសន្តិភាពរបស់គាត់ ។ គុណសម្បត្តិខុសៗគ្នាដែលគេគោរពនៅក្នុងបុគ្គលប្រភេទខុសៗគ្នា គឺមានសារៈសំខាន់ណាស់ក្នុងការកំណត់ថា តើទំនាក់ទំនងរវាងបុគ្គលអាចជួយយ៉ាងដូចម្ដេចខ្លះដល់យុទ្ធសាស្ត្រសំរាប់តាមដាន និងគ្រប់គ្រងទំនាស់ ។

វប្បធម៌កម្ពុជាមានប្រពៃណីមួយចំនួនដែលបង្កើតស្តង់ដានានានៃឥរិយាបថសមស្របបាន ។ ស្តង់ដាទាំងនេះមានជាអាទិ៍ច្បាប់ ទំនៀមទំលាប់ អ្វីដែលធ្លាប់មានពីមុននៅក្នុងមូលដ្ឋាន ស្វ័យសត្យខាងវប្បធម៌ (cultural axioms) ទំនៀមទំលាប់អ្នកស្រុក (folklore) គម្ពីរសាសនា និងសិទ្ធិមនុស្ស (ដែលប្រហែលកាន់តែសំខាន់ឡើងហើយ) ។ កម្ពុជាសំបូរដោយឯកសារអក្សរសាស្ត្រប្រៀនប្រដៅតាមបែបប្រពៃណី សុភាសិត និងរឿងល្បើកអប់រំស្មារតីផ្សេងៗដែលគេអាចដកស្រង់មកប្រើបាន[៣៧] ។ ជាញឹកញយគេតែងអះអាងថា ក្បួនច្បាប់ទាំងនេះមានសារៈសំខាន់សំរាប់ការបកស្រាយទំនាស់ និងការតំរែតំរង់ឥរិយាបថ ហើយករណីសិក្សាស្រាវជ្រាវពីរឿងទំនាស់ដែលកំពុងកើតមាន អាចជួយបង្ហាញពីរបៀបរបបដែលការជជែកវែកញែកពីស្តង់ដានានា ត្រូវបានយកមកប្រើប្រាស់ដើម្បីបកស្រាយទំនាស់ និងតំរង់ទិសសំរាប់គ្រប់គ្រងទំនាស់ ។

នៅលាយឡំជំពាក់ជំពិនជាមួយអក្សរសាស្ត្រខ្មែរ គឺប្រពៃណីខាងពុទ្ធសាសនា ដែលផ្តល់ការណែនាំដូចគ្នាខាងផ្លូវចិត្តឥរិយាបថ បទពិសោធន៍ត្រឹមត្រូវសំរាប់ធ្វើសកម្មភាព និងរឿងនិទានដាស់តឿនផ្សេងៗ ។ គេបានកត់សំគាល់ថា ប្រពៃណីខាងពុទ្ធសាសនាបានផ្តល់កម្មវិធីជាសំខាន់មួយសំរាប់តំរង់ទិសឡើងវិញនូវប្រតិកម្មរបស់បុគ្គល ចំពោះទំនាស់ គឺមិនមែនសេចក្តីណែនាំជាក់លាក់សំរាប់ចាត់ចែងដោះស្រាយជាមួយអ្នកឯទៀតនោះទេ ។ កេរ្តិ៍ឈ្មោះអំពីជីវភាពរស់នៅស្របតាមសីលធម៌ និងរបៀបរបបខាងពុទ្ធសាសនា ប្រហែលជានឹងជួយបង្កើនស្តុកទុននិមិត្តរូបរបស់បុគ្គលនៅក្នុងភូមិ ។ រឿងនេះមានសារៈសំខាន់ដើម្បីស្វែងរកអ្នកមានសក្តានុពលក្នុងការងារគ្រប់គ្រងទំនាស់ក្នុងចំណោមអ្នកភូមិ ។

ព្រះភិក្ខុ ហេង មុនីចិន្តា បានរកឃើញគុណសម្បត្តិ ១០យ៉ាងដែលចាំបាច់សំរាប់អ្នកសំរុះសំរួលវិវាទតាមប្រពៃណីពុទ្ធសាសនា: វ័យរៀមច្បង/បទពិសោធន៍ ខ្លួនឯងមានវិន័យល្អ/សីលធម៌ ការអប់រំ ចំណេះដឹងពីច្បាប់ គតិបណ្ឌិត/ជំនាញក្នុងការដោះស្រាយវិវាទ ចិត្តស្រឡាញ់ធម៌ ចំណេះដឹងនិងសច្ចភាព ការអត់ឱន ការប្រុងប្រយ័ត្ន ស្ថិរភាពខាងផ្លូវចិត្ត/ស្មារតី ប្រមូលផ្តុំចិត្តបរិសុទ្ធគ្មានលំអៀងដោយលោភៈ ។ លោកបានអធិប្បាយថា:

> *អ្នកឯណាដែលមានសច្ចធម៌ មានធម៌ គ្មានហិង្សា គ្រប់គ្រងខ្លួនឯងបាន វ័យឆ្លាត និងមានជំហរស្មោះត្រង់ គឺអាចជ្រើសតាំងជាអ្នកសំរុះសំរួលបាន*[៣៨] ។

៣៧ See Karen Fisher-Nguyen (1994), "Khmer Proverbs: Images and Rules in Cambodian Culture Since 1975," in May Ebihara, Carole Mortland & Judy Ledgerwood (eds.), *Cambodian Culture Since 1975: Homeland and Exile*, (London: Cornell UP)

៣៨ Ven. Heng Monychenda (1997), "Non-Violence and Conflict Resolution: Buddhism and Conflict Resolution in the Community," in Eva Mysliwiec & Catherine Morris (eds.), *Dispute Resolution in Cambodia: a Road to Peace and Reconciliation,* (Phnom Penh: University of Victoria Institute for Dispute Resolution and CDRI), p.48. See also Om Kem (1998), "Disputes and Dispute Resolution from a Buddhist Perspective," in Alex Grzybowski et al., (eds.), *Building Democratic Institutions and Practices in Cambodia, Proceedings from the Cambodian Commission on Human Rights Capacity Building Project,* (Phnom Penh: Pacific Resolutions and University of Victoria Institute for Dispute Resolution), p.7. It is interesting that similar lists of characteristics were put forward by some interviewees surveyed for their views on the kinds of people who should staff the national and local election committees for the commune election. See Caroline Hughes and Real Sopheap (1999), *The Nature and Causes of Conflict Escalation in the 1998 Election,* (Phnom Penh: CDRI), p.34.

លក្ខណៈសម្បត្តិរបស់បុគ្គលត្រូវបានប្រើប្រាស់ជាសំខាន់សំរាប់ពន្យល់ពីទំនាស់ និងជួយបំភ្លឺដល់ការគ្រប់គ្រងទំនាស់ ។ ព្រះមហាឃោសានន្ទ មានសង្ឃដីកាថា:

*អ្វីៗគ្រប់យ៉ាង គឺមានមូលហេតុ និងលក្ខខណ្ឌរបស់វា ។ មូលហេតុនៃការប្រយុទ្ធ និងសង្គ្រាម គឺលោភៈ ទោសៈ ការស្អប់ និងមោហៈ ។ មូលហេតុនៃសន្តិភាពគឺ សីលធម៌ ស្មារតីប្រមូលផ្តុំ និងគតិបណ្ឌិត ព្រមទាំងសច្ចធម៌ និងកតវេទិតាផងដែរ ។ នៅពេលយើងមានសច្ចធម៌ គឺគ្មានលោភៈទៀតទេ ។ នៅពេលមានករុណាធម៌ គឺគ្មានទោសៈទៀតទេ ។ នៅពេលមានគតិបណ្ឌិត នោះគ្មានមោហៈទៀតទេ ។ ដូច្នេះគ្មានការប្រយុទ្ធទៀតឡើយ ។ យើងត្រូវរក្សាសីលធម៌*[៣៩] ។

ចំណុចគួរកត់សំគាល់មួយ គឺជំហរនេះត្រូវបានលើកឡើងផងដែរដោយសកម្មជនខាងសិទ្ធិមនុស្សម្នាក់ដែលធ្វើការក្នុងអង្គការចាមមួយ ហើយគាត់មានយោបល់ថា ជំហរបែបនេះចំពោះទំនាស់វាជាលក្ខណៈពិសេសមួយរបស់កម្ពុជា មិនមែនជាប់ទាក់ទិនជាពិសេសអ្វីទៅនឹងពុទ្ធសាសនា ឬជនជាតិខ្មែរនោះទេ:

*គឺដូចតែគ្នាទេ - ពុទ្ធសាសានា អ៊ីស្លាមសាសានា សិទ្ធិមនុស្ស - ពីព្រោះសុទ្ធតែធ្វើឱ្យមនុស្សលែងមានហិង្សា ។ មានចាមម្នាក់រស់នៅក្នុងសហគមន៍ចាម - គាត់នោះគឃ្លើនណាស់ និងប្រើសំដីអាសអាភាសជាមួយអ្នកជិតខាង... ។ គាត់ជាចាម ប៉ុន្តែគាត់មិនយល់ថាចាមជាអ្វីទេ ។ ប្រធានអង្គការបានយកគាត់ទៅវិហារ ហើយមួយខែក្រោយមកអ្វីៗ បានប្រែប្រួលអស់ គឺគាត់... បានក្លាយជាមនុស្សល្អម្នាក់នៅក្នុងសហគមន៍... មនុស្សយើងត្រូវរស់នៅដោយសន្តិភាព និងមិនត្រូវគឃ្លើនដាក់គ្នាទេ*[៤០] ។

មតិទាំងនេះបានបង្ហាញថា របៀបរបបអនុវត្តរបស់ប្រជាជនដើម ឬរបៀបរបបជាប្រពៃណីនៃការគ្រប់គ្រងទំនាស់ដរាបណាវាឆ្លុះបញ្ចាំងពីប្រពៃណីនេះ វាប្រហែលជាដើរតាមគំនិតរបស់បុគ្គល មិនមែនតាមការងាយស្រួលសំរេចលទ្ធផលនោះទេ ហើយវាផ្តោតលើចរិតរបស់បុគ្គលក្នុងទំនាស់ មិនមែនលើចរិតនៃទំនាស់ទេ ។

ជាទូទៅគេមើលឃើញថា ប្រពៃណីខាងពុទ្ធសាសនាគឺជាមូលដ្ឋានមួយដ៏មានប្រយោជន៍សំរាប់ការបង្កើត និងផ្សព្វផ្សាយវិធីសាស្ត្រថ្មីៗសំរាប់ការគ្រប់គ្រងទំនាស់នៅកម្ពុជា ។ វគ្គសិក្សា ការសំរុះសំរួលប្រកបដោយសតិ ផ្តល់ដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ វគ្គសំរុះសំរួលផ្តល់ដោយមជ្ឈមណ្ឌលវិបស្សនា គំនិតផ្តួចផ្តើមនៃពុទ្ធសាសនាដើម្បីការអភិវឌ្ឍន៍នៅខេត្តបាត់ដំបង និងកម្មវិធីផ្សេងៗសំរាប់បណ្តុះបណ្តាលព្រះសង្ឃស្តីពីស្តង់ដាខាងសិទ្ធិមនុស្ស គឺបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់សាជាថ្មី ដើម្បីយកឱវាទរបស់ព្រះពុទ្ធមកប្រើប្រាស់ក្នុងគោលដៅខាងសង្គមកិច្ច ។

អ្នកឆ្លើយសំភាសន៍ម្នាក់ដែលធ្វើការខាងគ្រប់គ្រងទំនាស់នៅស្រុកបន្ទាយមានជ័យ ហើយបានប្រើប្រាស់សិក្ខាបទទាំងប្រាំរបស់ព្រះពុទ្ធ ធ្វើជាមូលលដ្ឋានសំរាប់គ្រប់គ្រងទំនាស់បានផ្តល់មតិថា:

*កាលពីមុនប្រជាជនបានឮពីសិក្ខាបទទាំងប្រាំជាភាសាបាលី ប៉ុន្តែពួកគេមិនអាចយល់បាន ហើយក៏មិនដឹងថាត្រូវយកមកប្រើយ៉ាងដូចម្តេចនៅក្នុងជីវភាពប្រចាំថ្ងៃ ។ យើងបានបកប្រែសិក្ខាបទទាំងប្រាំជាភាសាខ្មែរ ហើយពួកគេក៏បានយល់*[៤១] ។

ការប្រឹងប្រែងយកធម៌ព្រះពុទ្ធមកប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ គឺជាការសាកល្បងយកស្តង់ដាផ្សេងៗរបស់វត្តអារាម

---

៣៩ The Ven. Mahaghosananda, personal interview, Phnom Penh, May 1996, quoted in Caroline Hughes (1998), "Human Rights in Cambodia: International Intervention and the National Response," PhD dissertation (University of Hull)

៤០ Human rights activist, personal interview, Phnom Penh, March 1996, quoted in *Ibid.*

៤១ Van Sivon, personal interview, Phnom Penh, July 2000

មកបញ្ចូលនៅក្នុងជីវភាពរបស់គ្រហស្ថនៅក្នុងភូមិ ហើយក៏បានធ្វើឱ្យប្រែប្រួលដល់ការយល់ឃើញរបស់អ្នកភូមិអំពីតំលៃ និងឥរិយាបថផ្សេងៗដែលសមស្រប ។ ការសង្កត់ធ្ងន់លើទិដ្ឋភាពសន្តិភាពនៃឱវាទរបស់ព្រះពុទ្ធ បានលើកទឹកចិត្តពួកអ្នកភូមិឱ្យគោរពកាន់តែខ្លាំងថែមទៀតដល់ស្តង់ដាទាំងនេះ និងបន្ថយការគោរពដល់បុគ្គលដែលប្រើហិង្សា ឬការគំរាមកំហែង ។ ការវាយតំលៃពីផលប៉ះពាល់នៃសកម្មភាពបែបនេះ ទៅលើការយល់ដឹងពីទំនាស់ និងការគ្រប់គ្រងទំនាស់អាចជួយច្រើនណាស់ដល់ការស្វែងយល់ថា តើការប្រឹងប្រែងទាំងនេះបានធ្វើឱ្យប្រែប្រួលឬទេ ដល់ធាតុផ្សំផ្សេងៗនៃទុននិមិត្តរូបនៅតាមភូមិកម្ពុជា ។

ទន្ទឹមនឹងការប្រើប្រាស់ឱវាទរបស់ព្រះពុទ្ធតាមបែបថ្មីនៅក្នុងទសវត្សរ៍១៩៩០នេះ មានផុសចេញនូវការជជែកវែកញែកពីលក្ខណៈសមស្របនៃទស្សនៈផ្សេងៗដែលផ្សារភ្ជាប់នឹងមនោគមវិជ្ជាបែបសេរីរបស់បស្ចឹមប្រទេស សំរាប់ការដាក់អនុវត្តន៏នៅក្នុងសង្គមកម្ពុជា ។ ឧទាហរណ៍ នៅក្នុងការបោះពុម្ពផ្សាយថ្មីៗរបស់វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) គេឃើញមានជាអាទិ៍ ការពិចារណាតាមបែបទស្សនវិជ្ជាអំពីការដាក់អនុវត្តន៏ទស្សនៈផ្សេងៗដូចជា "ការអត់ឱន" "ប្រជាធិបតេយ្យ" "ការដឹកនាំ" និង "ការកសាងទំនុកចិត្តរួមគ្នា" ចំពោះសង្គមកម្ពុជា[៤២] ។

កំណើនយ៉ាងលឿននៃសកម្មភាពផ្សព្វផ្សាយជំរុញសិទ្ធិមនុស្ស គឺជាឧទាហរណ៍មួយទៀតក្នុងរឿងនេះ ។ ឯសំនួរថាតើការជជែកវែកញែកពីសិទ្ធិមនុស្ស បានជួយប៉ុណ្ណាដល់ស្តង់ដានានាសំរាប់អ្នកភូមិ គឺត្រូវមានការស្រាវជ្រាវថែមទៀត ។

ពាក្យសិទ្ធិមនុស្ស ត្រូវបានលើកឡើងកាន់តែញឹកញាប់ ហើយអ្នកផងយល់ថាវាមានអំណាចដោយឡែកមួយ ជាពិសេសអំណាចអន្តរជាតិ ប៉ុន្តែគេមិនច្បាស់ទេថា តើការលើកពាក្យនេះឡើង គេមានបង្កប់ន័យចង់និយាយដែរឬទេទៅដល់វិធីសាស្ត្រផ្អែកលើសិទ្ធិថ្មីមួយសំរាប់ការយល់ដឹងពីទំនាស់ និងការគ្រប់គ្រងទំនាស់ក្នុងភូមិ ។

ការសិក្សារបស់លោកស្រី Judy Ledgerwood ពីទំនាស់មួយក្នុងចំណោមខ្មែរ-អាមេរិកាំង នៅឯសហរដ្ឋអាមេរិកបានបង្ហាញថា លទ្ធភាពប្រើភាសាផ្លូវការរបស់រដ្ឋ និងការយល់ដឹងច្រើនពីស្តង់ដាផ្សេងៗដែលទ្រទ្រង់ដល់គំនិតវែកញែករបស់រដ្ឋអាមេរិកស្តីពីបញ្ហាមានទំនាស់ វាមានសារៈសំខាន់ជាពិសេស ក្នុងការផ្តល់សិទ្ធិអំណាចដល់ភាគីមួយឱ្យមានប្រៀបទៅលើអ្នកឯទៀត[៤៣] ។ ការពិនិត្យពីភាពងាយស្រួលរបស់គូភាគីវិវាទនានា ក្នុងការច្នៃប្រើប្រាស់ ហើយលើកយកស្តង់ដា និងប្រពៃណីផ្សេងៗ មកសំអាងអាចផ្តល់ការយល់ដឹងយ៉ាងសំខាន់ពីវិធីដែលបុគ្គលកសាងកេរ្តិ៍ឈ្មោះដើម្បីមានសិទ្ធិអំណាចខាងផ្លូវស្មារតីដែលនឹង ផ្តល់ភាពពេញច្បាប់ដល់ឥរិយាបថរបស់ពួកគេនៅក្នុងសង្គមកម្ពុជា ។ បែបបទដែលចំណាប់អារម្មណ៏ចំពោះទំនាស់ វាកើតពីការ ដាក់អនុវត្តន៏ពាក្យទំនឹមទំនៀម និងគោលការណ៏ផ្សេងៗលើស្ថានការណ៏ជាក់លាក់ណាមួយ គឺមានសារៈសំខាន់ណាស់ ពីព្រោះវា កំនត់ថាតើដំណើរការគ្រប់គ្រងទំនាស់ប្រភេទណាដែលសក្តិសិទ្ធិ ។ ប៉ុន្តែចំពោះកំលាំងអំណាចនៃការវែកញែកពីស្តង់ដាផ្សេងៗក្នុងការដាក់វិន័យឱ្យបុគ្គលរឹងរូស សុខចិត្តទទួលយកការសំរុះសំរួល ឬចុះចាញ់ គឺជាប្រធានបទមួយដែលត្រូវស្រាវជ្រាវ ។

សរុបមក ប្រពៃណីទាំងអស់នេះបង្កើតបានជាកំរងគោលការណ៏ដ៏ខ្លាំងមួយ សំរាប់ការធ្វើសកម្មភាព ។ ពិតមែនហើយ អំណាច ឬកំលាំងនៃទស្សនៈដែលគូភាគីក្នុងទំនាស់គេទទួលបានថា តើត្រូវប្រកាន់ឥរិយាបថយ៉ាងដូចម្តេច (គឺខុសពីរបៀបបទដែលគេប្រកាន់ឥរិយាបថជាក់ស្តែង) គឺជាហេតុផលមួយដែលនាំឱ្យវិធីសាស្ត្រធ្វើករណីសិក្សាពីទំនាស់ (ដែលមានប្រើការសង្កេតរបស់អ្នកចូលរួមក្នុងកិរិតមួយយ៉ាងធំ) វាផ្តល់ឱកាសឱ្យគេក្តាប់ពតិមានលំអិតបានប្រសើរជាង ការវាស់វែងជំហរ ឬការធ្វើ

---

៤២ Chhay Yiheang (1999), *The Necessity of Utilizing a Concept of "Tolerance" in Cambodia,* (Phnom Penh: Cambodian Institute for Co-operation and Peace); Kao Kim Hourn (with Samraing Kamsang) (1999), *Grassroots Democracy in Cambodia, Opportunities, Challenges and Prospects,* (Phnom Penh: Cambodian Institute for Co-operation and Peace and Forum Syd); (1999) *Shared Leadership and Trust Building in Cambodia: Learning from the Past, Sharing Experiences, Views and Visions, and Drawing Lessons for the Future* (Phnom Penh: Cambodian Institute of Co-operation and Peace)

៤៣ Judy Ledgerwood (1999), "Portrait of a Conflict: Exploring Changing Khmer-American Social and Political Relationships," *Journal of Refugee Studies,* 3.2, p. 135-154

សំភាសន៍ស្រាវជ្រាវមួយខ្សែទៀត ។ នៅក្នុងការរាយរ៉ាប់ជាបន្ទាប់បន្សំ អ្នកឆ្លើយសំភាសន៍ច្រើនមាននិន្នាការខិតខំបំភ្លៃបទពិសោធន៍ និងការសង្កេតរបស់ខ្លួនអំពីទំនាស់ ដើម្បីឱ្យវាស៊ីគ្នាទៅនឹងការបកស្រាយ ឬក្របខ័ណ្ឌខាងស្មារតីដែលមានស្រាប់ ។

*ការលើកឡើងពីស្តង់ដានៅក្នុងស្ថានការណ៍មានទំនាស់មានទិដ្ឋភាពពីរ:* ការលើកពីស្តង់ដាដោយភាគីក្នុងទំនាស់ ដើម្បីបញ្ជាក់ថា ជំហររបស់ខ្លួនត្រឹមត្រូវ និងការលើកពីស្តង់ដាដោយភាគីទីបីដើម្បីបង្ហាញពីលក្ខណៈពេញច្បាប់នៃដំណោះស្រាយ ។ ពាក្យ "ភាគីទីបី" នៅទីនេះអាចជាមតិរបស់ភូមិទាំងមូល ឬសំដៅដល់អ្នកធ្វើអន្តរាគមន៍ជាក់លាក់ណាមួយដូចជាអាចារ្យ ឬមន្ត្រីមូលដ្ឋាន ។ ដូចគ្នាដែរ ទុននិមិត្តរូបរបស់បុគ្គល អាចយកមកចំណាយដើម្បីយកប្រៀបនៅក្នុងទំនាស់អ្វីមួយ ឬផ្តល់ភាពពេញច្បាប់ដល់បុគ្គលនោះ ដើម្បីដើរតួជាអ្នកគ្រប់គ្រងទំនាស់រវាងភាគីឯទៀតៗ ។

ការស៊ើបអង្កេតពីទំនាក់ទំនងសហគមន៍ដោយប្រើក្របខ័ណ្ឌទស្សនៈដូចបានលើកឡើង នឹងផ្តោតលើយុទ្ធសាស្ត្ររបស់បុគ្គលនៅក្នុងបរិបទនៃស្តង់ដានានា (របស់សហគមន៍) ដែលគ្រប់គ្រងការផ្តល់ឋានៈ និងការគោរព ។ ស្តង់ដាទាំងនេះអនុវត្តទាំងលើភាគីក្នុងទំនាស់ និងអ្នកគ្រប់គ្រងទំនាស់ ដោយផ្តល់ធនធានពិសេសសំរាប់ចំណាយឱ្យពួកគេ ឬធ្វើវិនិយោគក្នុងពេលមានទំនាស់ ។ សំខាន់ត្រូវកត់សំគាល់ថា ប្រភេទនៃស្តង់ដាដែលគ្រប់គ្រងសកម្មភាព ប្រហែលប្រែប្រួលខុសគ្នាទៅតាមលក្ខណៈខុសគ្នាខាងវណ្ណៈ និងភេទ ហើយប្រហែលមានដំណើរការតាមវិធីជាក់លាក់អ្វីមួយ ដើម្បីជួសជុល និងផ្តល់ភាពពេញច្បាប់ដល់ទំនាក់ទំនងគ្របសង្កត់រវាងអ្នកមាននិងអ្នកក្រ រវាងបុរស និងស្ត្រី ។

## គ. ភូមិនៅក្នុងពិភពលោក

### *១. រូបភាពនៃឥទ្ធិពលខាងក្រៅ*

រហូតមកទល់ពេលនេះ ការវិភាគបានសន្មតថា ភូមិគឺជាអង្គភាពដាច់ដោយឡែកមួយ ដែលជាទូទៅធ្វើការគ្រប់គ្រងកិច្ចការរបស់ខ្លួនផ្ទាល់ ដោយនៅឯកោពីពិភពខាងក្រៅ ។ ប៉ុន្តែតាមពិត រឿងរ៉ាវមិនមែនដូច្នេះទេ ។ មធ្យោបាយដែលពិភពខាងក្រៅធ្វើការជ្រៀតចូលមកក្នុងជីវភាពភូមិ វាមានសារៈសំខាន់ក្នុងរឿងពីរធំៗ ។ ទី១ វាបង្កើនប្រភេទទុនដែលមាន ។ អ្នកភូមិទាំងអស់ប្រហែលធ្លាប់បានជួបកំណើនជំរើសខ្លះៗហើយ ប៉ុន្តែសំរាប់អ្នកភូមិមួយចំនួន កំណើននេះវាមានកំរិតធំជាងកំណើនរបស់អ្នកឯទៀត ។ ទី២ វាផ្តល់នូវស្តង់ដាវប្បធម៌ខុសៗគ្នា (ដែលអាចជំទាស់នឹងគំនិតថា ទស្សនៈជាក់លាក់មួយចំនួនស្តីពីអ្វីដែលល្អ និងដែលត្រូវ វាសាមញ្ញ អាចមើលយល់ដោយខ្លួនឯង) គឺវាធ្វើឱ្យចុះខ្សោយដល់ក្របខ័ណ្ឌដែលសហគមន៍ក្នុងភូមិទាំងមូលធ្វើការវិនិច្ឆ័យទៅលើសកម្មភាពផ្សេងៗ ។ ការប្រែប្រួលទាំងនេះប្រហែលជានឹងប៉ះពាល់គួរឱ្យកត់សំគាល់ដល់សមត្ថភាពរបស់ភូមិ ក្នុងការគ្រប់គ្រងទំនាស់ ពីព្រោះរចនាសម្ព័ន្ធ និងទំនាក់ទំនងដែលទន់ភ្លន់ជាងមុន បានអនុញ្ញាតឱ្យភាគីនានាក្នុងទំនាស់ អាចប្រើប្រាស់យុទ្ធសាស្ត្រច្រើនបែបយ៉ាងថែមទៀតបាន ។

លោក Paul Stirling បានផ្តល់មតិពីកំលាំងមូលធននិយមពីក្រៅ ដែលបានជ្រៀតចូលកាន់តែខ្លាំងឡើង ទៅក្នុងភូមិនានានៅប្រទេសទួរគី:

> *ដោយបានបង្កើនទំនាក់ទំនងក្នុងសង្គមយ៉ាងច្រើន ទោះបីជាប្រជាជនក្រីក្រក៏មានទំនាក់ទំនងជាមួយអ្នកនៅខាងក្រៅភូមិដែរ ប៉ុន្តែរឿងនេះបានកាត់បន្ថយសាមគ្គីភាពក្នុងភូមិ និងធ្វើឱ្យចុះខ្សោយដល់កំលាំងត្រួតត្រារបស់សង្គមដែលជាមូលដ្ឋាននៃរបបអភិរក្សនៅក្នុងភូមិ ។ អ្នកភូមិលែងត្រូវពឹងផ្អែកជាចាំបាច់ទៅលើពួកអ្នកដឹកនាំរបស់ខ្លួនទៀតហើយ ។ ក្នុងពេលជាមួយគ្នា អ្នកភូមិត្រូវពឹងផ្អែកលើសមានចិត្តរបស់មនុស្សជាច្រើននៅខាងក្រៅភូមិដែលមានការសន្មត និងគំនិតខុសៗគ្នា ។ សហគមន៍ក្នុងភូមិត្រូវប្រទាញប្រទង់ទៅគ្រប់ទិស ដោយសារការបង្កើន*

*ទំនាក់ទំនងផ្សេងៗរវាងសមាជិកខ្លួន និងពិភពខាងក្រៅ*[៤៤] ។

ដូចគ្នាដែរ Andrew Pearse បានលើកថា "កំលាំងកសាងជាក្រុម... បានដាក់បង្ហាញ... នូវជំរើសតិរិយាបថមួយចំនួន ដែលកសិករអាចយកមកប្រើបាន" ដូច្នេះហើយក៏បានធ្វើឱ្យ "អ្នកដឹកនាំនៅមូលដ្ឋានថមថយកិត្យានុភាព និងប្រសិទ្ធិភាព "[៤៥] ។

គេឃើញមានប្រភពច្រើនខុសៗគ្នានៃការជ្រៀតចូលពីក្រៅមកក្នុងភូមិកម្ពុជា ។ នៅក្នុងការសិក្សារបស់គាត់ ស្តីពីការដោះស្រាយវិវាទ Collins បានពិនិត្យពីការជ្រៀតចូលនៃពិភពខាងក្រៅទៅក្នុងភូមិតាមរូបភាពជារដ្ឋ និងវត្ត ។ គាត់បានសន្និតជាទូទៅថា ការជ្រៀតចូលពីក្រៅត្រូវបានជួយសំរួលតាមរយៈបុគ្គលអ្នកគ្រប់គ្រងទំនាស់ (តាមធម្មតាគឺ ប្រធានភូមិ) និងត្រូវបានប្រើប្រាស់ជាការគំរាមដាក់ទណ្ឌកម្ម និងជាប្រភពនៃទុនវប្បធម៌ ដោយផ្តល់សិទ្ធិអំណាចឱ្យប្រធានភូមិសំរាប់ការប្រឹងប្រែងរបស់គាត់ដើម្បីដោះស្រាយវិវាទ ។

លោក Collins មិនបានចាត់ទុកពិភពលោកខាងក្រៅជាប្រភពធនធានសំភារៈនៃអំណាច (ដូចជា អាវុធ ប្រាក់ ការជួយការពារ) ឬធនធានខាងមនោគមវិជ្ជាអំណាច (ដូចជា គំនិតយល់ឃើញពីសិទ្ធិ ច្បាប់) ដែលអាចប៉ះពាល់ដល់រចនាសម្ព័ន្ធ ការត្រួតត្រានៃសង្គម (ឬវប្បធម៌សន្តិភាព) របស់សហគមន៍មូលដ្ឋានទេ ។ ដោយឡែក គាត់បានសន្និតថា ប្រធានភូមិមានជំហរអព្យាក្រឹត្យចំពោះភាគីនានាក្នុងទំនាស់ និងជាទូទៅ គឺជាអ្នកតំណាងឱ្យភូមិ នៅក្នុងការចរចាចាត់ចែងផ្សេងៗជាមួយពិភពខាងក្រៅ ។ Collins បានបញ្ជាក់ថា ប្រធានឃុំទទួលខុសត្រូវបំពេញកូតាកំណែនកងទ័ពនៅក្នុងទសវត្សរ៍១៩៨០ និងជាកម្មវត្ថុនៃការចោទប្រកាន់ថា គាត់មានការឃុបឃិតនៅក្នុងការរឹបអូសដីធ្លីក្នុងទសវត្សរ៍១៩៩០ ។ Collins មិនបានពិនិត្យពីផលប៉ះពាល់នៃសកម្មភាពអប្រជាប្រិយទាំងនេះលំអិតទេ ចំពោះសមត្ថភាពគ្រប់គ្រងទំនាស់នៅក្នុងភូមិ ។

លោក Davenport *et al.* បានពិពណ៌នាលំអិតថែមទៀតពីតួនាទីរបស់ប្រធានភូមិ:

*ភូមិនានាត្រូវបានតភ្ជាប់នឹងរចនាសម្ព័ន្ធរដ្ឋបាលខេត្តតាមរយៈប្រធានភូមិ ដែលជាអ្នកបានទទួលការតែងតាំងតាមផ្លូវនយោបាយ ។ ជាញឹកញយ មនុស្សតែម្នាក់បានកាន់តំណែងនេះតាំងពីឆ្នាំ១៩៧៩ ។ ប្រធានភូមិមានភារកិច្ចរកមនុស្សសំរាប់បំពេញកំណែនកងទ័ព និងធ្វើការងារសាធារណៈ ។ គាត់ចែកកាំភ្លើង (២០-៣០ដើមក្នុងមួយភូមិ) ទៅឱ្យអ្នកដែលគាត់ទុកចិត្តដើម្បីការពារភូមិទប់ទល់នឹងគ្រោះថ្នាក់ផ្សេងៗ ។ គាត់ត្រួតត្រាដីភូមិ (បើសិនជាមាន) ដើម្បីទុកសំរាប់ចែកឱ្យអ្នករៀបការថ្មី ទាហានរំសាយ និងអ្នកឯទៀតដែលមានតំរូវការពិសេស ឬត្រូវបានទទួលការឧបត្ថម្ភជាពិសេស*[៤៦] ។

ការពិពណ៌នានេះ ជួយឱ្យគេអាចវាយតំលៃច្បាស់ថែមទៀតពី អំណាចអារកាត់ដែលត្រូវបានប្រគល់ឱ្យប្រធានភូមិ និងលទ្ធភាពដែលការផ្ទេរអំណាចពីរដ្ឋទៅឱ្យមន្ត្រីតែងតាំង វាអាចបង្កើតទំនាក់ទំនងគ្រុបសង្កត់នៅក្នុងភូមិ ។

ប៉ុន្តែ ៤០ឆ្នាំក្រោយពីការសិក្សារបស់ Ebihara, លោក Conway បានលើកឡើងថា ក្នុងឋានៈជាអ្នកកាន់អំណាចនៅមូលដ្ឋានដែលរស់នៅក្នុងភូមិ ប្រធានភូមិត្រូវធ្វើវិនិយោគដើម្បីឱ្យមានការគាំទ្រជាប់បន្តពីអ្នកភូមិ ។ Collins បានលើកថា ពិតមែនតែប្រធានភូមិត្រូវបានតែងតាំងដោយថ្នាក់លើរបស់គាត់ និងត្រូវធ្វើអ្វីៗទៅតាមរបៀបរបបរបស់រដ្ឋកម្ពុជា ប៉ុន្តែ

*គាត់រស់នៅជាមួយប្រជាជនរបស់គាត់ គឺមិនដូចមន្ត្រីឃុំ ស្រុក និងខេត្តទេ ។ ប្រធានភូមិអាចចង់ទាញផល*

៤៤ Paul Stirling (1971), “A Turkish Village,” in Teodor Shanin (ed.) *Peasants and Peasant Societies, Selected Readings* (Harmondsworth: Penguin) p. 47

៤៥ Andrew Pearse (1971), “Metropolis and Peasant, The Expansion of the Urban-Industrial Complex and the Changing Rural Structure,” in Shanin (ed.), *op. cit.*, p. 76

៤៦ Davenport et al., *op. cit.*, p. 65

*ប្រយោជន៍ឱ្យបានច្រើនតាមអ្វីដែលអាចធ្វើទៅបានពីអ្នកភូមិ ពីព្រោះជាញឹកញាប់គឺមានការទាមទារពីមន្ត្រីថ្នាក់លើ ប៉ុន្តែបំណងនេះក៏ត្រូវតែថ្លឹងថ្លែងជាមួយការភ័យខ្លាចមានការសងសឹកផងដែរ*[៤៧] ។

ឈរលើការស្រាវជ្រាវរបស់ Collins និង Conway, គេគួរពិនិត្យដោយជំហរទិតៀន និងទន់ភ្លន់ថែមទៀត ពីតួនាទីរបស់ប្រធានភូមិ ។ ក្នុងនេះគេគួរពិនិត្យពីបែបបទដែលផលប្រយោជន៍ខាងក្រៅ គោលនយោបាយ និងការប្រែប្រួលផ្សេងៗបានជះឥទ្ធិពលមកលើភូមិ (គឺមិនគ្រាន់តែចំពោះទុនវប្បធម៌របស់ប្រធានភូមិប៉ុណ្ណោះទេ ប៉ុន្តែចំពោះធនធានសំភារៈ និងការជជែកវែកញែកផ្សេងៗដែលរដ្ឋជួយឧបត្ថម្ភ) និងពីបែបបទដែលរឿងទាំងអស់នេះ បានប៉ះពាល់ដល់សមត្ថភាពរបស់សហគមន៍ក្នុងការរៀបចំសំរបសំរួលទំនាក់ទំនងរបស់ខ្លួនផ្ទាល់ ។

មិនមែនមានតែរដ្ឋមួយទេដែលជ្រៀតចូលទៅក្នុងជីវភាពភូមិ ។ ទីភ្នាក់ងារជាតិ និងអន្តរជាតិនានា ដូចជា យោធា គណបក្សនយោបាយ, NGOs ជាតិ និងអន្តរជាតិ, កម្មវិធីផ្សេងៗរបស់អង្គការសហប្រជាជាតិ វិនិយោគិនបរទេស ថៅកែនៅភ្នំពេញ... ក៏ជ្រៀតចូលទៅក្នុងភូមិដែរ ដោយជួនកាលក្នុងបំណងដ៏ជាក់លាក់ គឺជួយធ្វើឱ្យប្រែប្រួលដល់ជីវភាពក្នុងភូមិ ។ ទាក់ទិននឹងអន្តរាគមន៍របស់ទីភ្នាក់ងារទាំងនេះ ភូមិនានាប្រហែលជាមានបទពិសោធន៍ខុសគ្នាខ្លាំងណាស់ ទៅតាមទីតាំងភូមិសាស្ត្រ កត្តាប្រវត្តិសាស្ត្រ និងនយោបាយ, កំរិត និងរូបភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច, សមាសភាពខាងជនជាតិ និងប្រជាសាស្ត្រ ។

ដូចគ្នានេះដែរ កត្តាទាំងនេះជំរុញ ឬរារាំងចលនារបស់អ្នកភូមិ គឺធ្វើឱ្យមានការចាកចេញពីភូមិ (ភៀសខ្លួន ឬទៅរកការងារធ្វើ) និងការវិលត្រឡប់វិញ ហើយតាមរយៈនេះ វាបានធ្វើឱ្យប៉ះពាល់ដល់ទំហំនៃទំនាក់ទំនងរវាងភូមិ និងពិភពខាងក្រៅ ។ ការសន្មតថា ប្រធានភូមិ និងវត្ត បានជួយសំរួលដល់ទំនាក់ទំនងជាមួយពិភពខាងក្រៅ វាអាចខុសឆ្គង បើសិនភូមិមានបញ្ជូនសមាជិកយ៉ាងទៀងទាត់ទៅភ្នំពេញ បាងកក ឬកន្លែងផ្សេងទៀត ដើម្បីទៅធ្វើការ ។ ផលប៉ះពាល់នៃការជួបពាក់ព័ន្ធផ្ទាល់របស់អ្នកភូមិជាមួយពិភពខាងក្រៅទៅលើការយល់ឃើញរបស់ពួកគេអំពីសិទ្ធិអំណាចរបស់ប្រធានភូមិ គឺជាចំណុចដ៏ល្អសំរាប់ធ្វើការស្រាវជ្រាវ ។

ការសិក្សារបស់ Collins បានបង្ហាញថា នៅតាមមូលដ្ឋាន ប្រធានភូមិបានប្រើការគំរាមអំពីការជាប់ពាក់ព័ន្ធដល់អាជ្ញាធរថ្នាក់ខ្ពស់ៗ ដើម្បីជំរុញឱ្យប្រជាជនប្រណិប័តន៍តាម ជាពិសេសនៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងទំនាស់ ។ Collins បានលើកពីបំណងដ៏ខ្លាំងក្លារបស់អ្នកភូមិដែលចង់ឱ្យការងារគ្រប់គ្រងទំនាស់ វាស្ថិតនៅក្នុងក្របខណ្ឌភូមិ ។ Collins បានពន្យល់រឿងនេះដូចតទៅ:

*ភូមិកម្ពុជាបានទទួលស្គាល់ថា បើធៀបនឹងអាជ្ញាធរទីក្រុងដែលមានអ្នកចេះអក្សរជ្រៅជ្រះ ជាពិសេសប៉ូលិស និងតុលាការ អ្នកភូមិ គឺទន់ខ្សោយគួរឱ្យសង្វេក ហើយអ្នកទន់ខ្សោយតែងតែចាញ់អ្នកខ្លាំងជានិច្ច*[៤៨] ។

តាមមើលទៅ ការអះអាងខាងលើត្រូវមានការសិក្សាថែមទៀត ពីព្រោះវាបានផ្តល់គំនិតថា អ្នកភូមិមិនបាននាំអន្តរាគមន៍ពីក្រៅបែបនេះដោយចេតនា យកទៅចូលឡូកឡំក្នុងទំនាស់នៅក្នុងភូមិ ឬរចនាសម្ព័ន្ធអំណាច ដើម្បីច្នៃប្រើវា យកប្រៀបទៅលើអ្នកភូមិឯទៀតនោះទេ ។

ការសន្មតថា អ្នកភូមិមានការភ័យខ្លាចក្នុងការទាក់ទងជាមួយពិភពខាងក្រៅ គឺជាចំណុចមួយគួរសង្ស័យ ។ នេះជាការសន្មតមួយដែលបំផ្លើសពេកពីភាពឯកោរបស់ភូមិ និងវាយតំលៃទាបពេកចំពោះលទ្ធភាពរបស់អ្នកភូមិ ក្នុងការប្រើប្រាស់ធនធានដូចជា ចំណងទាក់ទងជាមួយសាច់ញាតិនៅទីក្រុងដែលអាចជួយដល់ពួកគេក្នុងការចាត់ចែងដោះស្រាយជាមួយពិភពខាងក្រៅ ។ លើសពីនេះ កំរិតការអប់រំ និងធនធានខុសគ្នានៅក្នុងភូមិ ក៏ប្រហែលជានាំឱ្យមានការខុសគ្នាគួរឱ្យកត់សំគាល់នៅក្នុងជំហរចំពោះ

---

៤៧ Tim Conway (2000), “Elections and Assassinations: Local Democracy and Rural Development in Cambodia,” paper presented at the Annual Meeting of the Association for Asian Studies, 9-12 March 2000, San Diego.

៤៨ Collins, *Op. cit.*, p. 52

រដ្ឋ និង "មន្ត្រី" ។

ការអះអាងថា កម្ពុជាបានវិវត្តក្លាយជាសង្គមមួយនៃ "អ្នកខាងក្នុង និងអ្នកខាងក្រៅ" ដែលក្នុងនេះអ្នកមាន "ខ្សែ" ជាមួយអ្នកមានអំណាច គឺអាចយកប្រៀបលើអ្នកជិតខាងបាន វាជួយទ្រទ្រង់ដល់ទស្សនៈខាងលើ ។ ទំនាក់ទំនងទាំងនេះ គឺជាទិដ្ឋភាពមួយដែលមានជាយូរមកហើយនៅក្នុងសង្គម ។ ការសិក្សារបស់លោក Martin ពីអ្នកភូមិកម្ពុជាក្នុងសម័យមុនសង្គ្រាម បានរកឃើញថា ទំនាក់ទំនងចៅហ្វាយនាយ-កូនចៅ គឺជារូបភាពគួរកត់សំគាល់មួយនៃអង្គការសង្គម គឺដូចគ្នានឹងរចនាសម្ព័ន្ធជាសាច់ញាតិ និងក្រុមមនុស្សតាមអាយុដែរ ។ នៅក្នុងសង្គមមួយដែលធ្លាប់ជួបប្រទះក្នុងរយៈ៣០ឆ្នាំចុងក្រោយនូវការកេណ្ឌប្រមូលកំលាំងជាតិដ៏ខ្លាំងក្លា អន្តរាគមន៏អន្តរជាតិ ការជ្រៀតចូលនៃមូលធននិយម និងប្រជាធិបតេយ្យភាវូបនីយកម្ម ទំនាក់ទំនងបែបនេះវាកាន់តែរីកធំហួសពីព្រំដែនភូមិទៅទៀតហើយ ។

ដូចគ្នាដែរ ការប្រែប្រួលនៅក្នុងភូមិបានធ្វើឱ្យចំណងទាក់ទងនៃការជួយឧបត្ថម្ភជាប្រពៃណី មានដំណើរការមិនបានស្មើភាពគ្នាល្អដូចកាលពីមុនទេ ។ លោក Vijghen បានលើកមតិថា ចំណុចជាគន្លឹះមួយនៅក្នុងជីវភាពនៅជនបទ គឺជាលទ្ធភាពមានកំរិតនៃចំណងទាក់ទងសាមគ្គីភាពរវាងសាច់ញាតិនៅក្នុងភូមិ ។ នៅកម្ពុជាកាលពីសម័យមុនសង្គ្រាម ភូមិនានាមានសមាសភាពភាគច្រើនជាប្រជាជនជាប់សាច់ញាតិនឹងគ្នា ប៉ុន្តែក្នុងពេលសព្វថ្ងៃ លោក Vijghen បានរាយការណ៍ថា ភូមិមានទំហំធំជាងមុន និងមានអ្នកក្រៅច្រើនជាងមុន ។ គាត់លើកមតិថា ស្ថានភាពនេះអាចកាត់បន្ថយលទ្ធភាពនៃចំណងទាក់ទង ជួយឧបត្ថម្ភជាប្រពៃណី (ដែលនៅតែផ្សារភ្ជាប់នឹងសាច់ញាតិ) ក្នុងការជួយដោះស្រាយតំរូវការរបស់គ្រប់ៗគ្នា ពីព្រោះមានអ្នកខ្លះ "បានធ្លាក់ចេញពីប្រព័ន្ធ" ។ Vijghen បានរាយការណ៍ថា លំនាំនេះបានផុសឡើងយ៉ាងច្បាស់នៅក្នុងការពិនិត្យសង្កេតពីការបែងចែកជំនួយអភិវឌ្ឍន៍ ដែលក្នុងនេះអ្នកនៅខាងក្រៅបណ្ដាញជួយឧបត្ថម្ភខាងលើ ពុំអាចទាមទារយកចំណែកនៅក្នុងធនធានដែលត្រូវបានផ្ដល់ឱ្យនោះទេ[៤៩] ។

ដូច្នេះហើយ អាចមានទំនាស់ផុសឡើងម្ដងម្កាល ឬញឹកញាប់ ដោយក្នុងនេះភាគីម្ខាង ឬទាំងសងខាងគិតឃើញថា អន្តរាគមន៏ពីអ្នកក្រៅដែលមានអំណាច និងមានសមានចិត្តចំពោះខ្លួន គឺមានប្រយោជន៏ខ្លាំងណាស់ ។ ដូច្នេះយើងអាចរំពឹងបានថា ពួកគេតែងស្វែងរកអន្តរាគមន៏បែបនេះជាទៀងទាត់ ដើម្បីមិនគ្រាន់តែយកប្រៀបនៅក្នុងទំនាស់ជាក់លាក់ណាមួយនោះទេ ប៉ុន្តែគឺដើម្បីរក្សារចនាសម្ព័ន្ធគ្របសង្កត់លើគេនៅក្នុងភូមិ ។

នៅក្នុងស្ថានភាពបែបនេះ ការចៀសវាងទំនាស់ដោយភាគីទន់ខ្សោយ អាចជារូបភាពមួយនៃការគ្រប់គ្រងទំនាស់ ហើយអ្នកស្រាវជ្រាវខ្លះបានផ្ដល់មតិថា ជាក់ស្ដែងគឺវាពិតដូច្នេះមែន[៥០] ។ លោក ប៊ិត សៀងលីម បានលើកមតិថា វិធីសាស្ត្រគ្រប់គ្រងទំនាស់មានតែពីររូបភាពទេ គឺការហៅរកអំណាចខាងក្រៅដើម្បីយកប្រៀប និងការចៀសវាងទំនាស់ ។

> *ជាទូទៅបញ្ហាផ្សេងៗនៅក្នុងសង្គម គឺអាចដោះស្រាយបាន ឬមួយដោយអ្នកទាមទារបង្ហាញពីសិទ្ធិអំណាចខ្លួន ឬមួយដោយស្វែងរកអ្នកធ្វើអន្តរាគមន៏ដែលមានអំណាចកាន់តែខ្លាំងថែមទៀត ហើយអាចដណ្ដើមយកប្រៀបបានក្នុងនាមរបស់អ្នកទាមទារ ឬមួយដោយដកខ្លួនចេញពីទំនាស់ បើសិនត្រូវបរាជ័យគ្រប់ច្រកហើយ ។ បើសិនទំនាស់នៅតែមិនទាន់ដោះស្រាយបានទៀត អារម្មណ៏មិនទុកចិត្តគ្នា និងការគុំកួនដ៏ជ្រាលជ្រៅ អាចរាំងស្ទះដល់ការប្រឹងប្រែងផ្សេងៗក្នុងពេលអនាគតដែលសំដៅធ្វើឱ្យមានការទាក់ទងចុះឡើង ឬការដោះស្រាយបញ្ហា[៥១] ។*

ដូចគ្នាដែរ Esther Watts បានលើកពីសារៈសំខាន់នៃការចៀសវាងទំនាស់ ប៉ុន្តែបានចង្អុលបង្ហាញពីចរិតកាន់តែស្មុគ

៤៩ John Vijghen (1996), Decision Making in a Cambodian Village, a Study of Decision Making Processes in a Development Project in Cambodia, Takeo, Report No. 15 (Phnom Penh: Cambodian Researchers for Development) p. 16

៥០ E.g. Sorpong Peou, personal communication, Aug. 2000

៥១ Bit, *op. cit.*, p. 68

ស្មុគស្មាញនៃយុទ្ធសាស្ត្រនេះ នៅក្នុងស្ថានភាពមួយដែលចំណងទាក់ទងជាមួយអ្នកឯទៀតកាន់តែមានលក្ខណៈចាំបាច់ខ្លាំងឡើង:

> *លំនាំនៃការចៀសវាងទំនាស់រវាងភាគីពីរ ត្រូវបានបង្កើតឡើង... ។ ប៉ុន្តែការចៀសវាងទំនាស់ក្នុងអតីតកាល វាមានលក្ខណៈប្រាកដនិយមជាងក្នុងបច្ចុប្បន្នកាល ដោយសារទីតាំងភូមិសាស្ត្រនៃលំនៅដ្ឋាននានា... ។ លំនាំ និងព្រំប្រទល់ជាក់ស្តែងបានប្រែប្រួលច្រើនណាស់ក្នុង ៣០ឆ្នាំចុងក្រោយ ហើយលើសពីនេះទៀត ស្វយភាពខាងសេដ្ឋកិច្ចមិនបានបង្ខំឱ្យប្រជាជនរក្សាទុកទេនូវបណ្តាញដ៏ស្មុគស្មាញនៃទំនាក់ទំនង[៥២] ។*

កំរិតដែលទំនាស់ធំៗ និងរចនាសម្ព័ន្ធអំណាច (ដែលផុសចេញពីសង្គ្រាមស៊ីវិល ការបាក់បែកនៃវីរជនកម្ពុជា ការប៉ះទង្គិចគ្នានៃមនោគមន៍វិជ្ជាក្នុងសម័យសង្គ្រាមត្រជាក់ យោធាភាវូបនីយកម្ម និងការកសាងលទ្ធិប្រជាធិបតេយ្យជាក្រោយមកទៀត) ត្រូវបានផ្សារផ្ជាប់ទៅនឹងទំនាស់ក្នុងភូមិ គឺជាបញ្ហាមួយដែលមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅខាងគោលនយោបាយ[៥៣] ។ យោងតាមសារៈសំខាន់នៃរឿងពុករលួយ និង "ខ្សែ" នៅក្នុងការវិភាគពីវិធានការណ៍ផ្សេងៗសំរាប់ដោះស្រាយទំនាស់ (ដូចជា ប្រព័ន្ធតុលាការ) ដែលរដ្ឋបានផ្តល់ឱ្យ, សំនួរថាតើខ្សែប្រាក់សំណូកផ្សេងៗ មានដំណើរការយ៉ាងដូចម្តេចនៅក្នុងបរិបទនៃការគ្រប់គ្រងទំនាស់ក្នុងភូមិ វាមានប្រយោជន៍យ៉ាងច្រើនសំរាប់ការស្រាវជ្រាវ ។

## *២. ឥទ្ធិពលសង្គ្រាម*

សំរាប់ភូមិខ្លះៗ សង្គ្រាមស៊ីវិលក្នុងចន្លោះពេលពីឆ្នាំ១៩៧០ ដល់ ១៩៩៨ បានបង្កការបាក់បែកខ្ចាត់ខ្ចាយខ្លាំងណាស់ ។ ការសិក្សារបស់ Veena Krishnamurthy ក្នុងភូមិពីរនៅខេត្តកំពង់ស្ពឺ បង្ហាញពីបទពិសោធន៍របស់ភូមិក្នុងពេលមានសង្គ្រាម គឺមាន គោលដៅធ្វើការវាយតំលៃពីផលប៉ះពាល់នៃទំនាស់តាមផ្លូវអាវុធ ទៅលើទុនសង្គមកិច្ចនៅក្នុងភូមិទាំងពីរ ។ ការសិក្សាផ្តោតជា ពិសេសលើការវាយតំលៃពីផលប៉ះពាល់នៃសង្គ្រាម ទៅលើសមត្ថភាពនៃទុនសង្គមកិច្ចក្នុងការជួយចូលរួមវិភាគទានដល់សេដ្ឋកិច្ច ភូមិ និងកំរិតជីវភាពរបស់អ្នកភូមិ ព្រមទាំងជួយដល់សេវាខាងសង្គមកិច្ច និងសកម្មភាពទ្រទ្រង់សុខុមាលភាពនៅកំរិតភូមិ ។

ការសិក្សាបានរកឃើញថា ភូមិដែលបាត់បង់ទំនុកចិត្តខ្លាំងបំផុត មិនមែនភូមិដែលបានឆ្លងកាត់ការប្រយុទ្ធច្រើនជាងគេនោះទេ ប៉ុន្តែគឺភូមិដែលមានរចនាសម្ព័ន្ធរុះរើធ្ងន់ធ្ងរជាងគេនៅក្រោមរបបខ្មែរក្រហម ដោយមានការធ្វើចំណាត់ថ្នាក់ខុសគ្នារវាង "ប្រជាជនថ្មី" និង "ប្រជាជនចាស់" ដែលមានផលប៉ះពាល់យ៉ាងច្រើនទៅលើរបបចាត់ចែង និងអត្រារួចរស់ជីវិត ។ រឿងនេះបង្ហាញថា ការបាក់បែកខ្ចាត់ខ្ចាយខ្លាំងបំផុត មិនមែនកើតឡើងដោយសារអំពើហិង្សាសុទ្ធសាធនោះទេ ប៉ុន្តែដោយសារការដាក់បង្ខំនូវប្រព័ន្ធតំលៃខាងសីលធម៌មួយដែលខុសពីធម្មតា និងការរើសអើងដែលកើតមានជាមួយគ្នា ។ ការសិក្សារកឃើញថា អ្នកភូមិបានត្រឡប់ទៅអនុវត្តបែបបទ-ទំលាប់ចាស់ឡើងវិញយ៉ាងឆាប់ និងទស្សនៈពីឋានៈដែលគេធ្លាប់មានកាលពីសម័យមានសន្តិភាព ។ ប៉ុន្តែទិដ្ឋភាពផ្សេងៗនៃទុនសង្គមកិច្ច ពិសេសទំនុកចិត្ត បានផុសឡើងវិញយឺតជាងនៅតាមកន្លែងនានាដែលវាត្រូវបានបំផ្លិចបំផ្លាញ ។

របកគំហើញខាងលើបញ្ជាក់នូវការគាំទ្រដល់បំណកស្រាយរបស់លោក មាស នី អំពីផលប៉ះពាល់នៃឆ្នាំមានសង្គ្រាមទៅ

---

៥២ Esther Watts, “The Meaning of Community, English Literature Review,” in *The Meaning of Community in Cambodia, op. cit.,*, p. 11

៥៣ សំនួរថាតើទំនាស់នយោបាយរាលដាលចេញពីកំរិតមូលដ្ឋានទៅកំរិតជាតិ ឬពីកំរិតជាតិទៅកំរិតមូលដ្ឋានវិញ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីសំនួរអង្កេតសំរាប់ NGOs នៃការសិក្សាឆ្នាំ១៩៩៩ អំពីទំនាស់ក្នុងការបោះឆ្នោត ។ អ្នកឆ្លើយសំភាសន៍ មានមតិខុសៗគ្នាដែលបង្ហាញថា ក្នុងចំនោម NGOs ផងដែរក៏ពុំមានការយល់ដឹងច្បាស់លាស់ ឬស្របគ្នាទេអំពីចំណងទាក់ទងរវាងទំនាស់នៅកំរិតជាតិ និងកំរិតមូលដ្ឋាន និងការគ្រប់គ្រងទំនាស់ ។ នេះជាសំនួរមួយទាក់ទិនច្រើននឹងនយោបាយនៅកំរិតជាតិ ពីព្រោះជំហររបស់ជាតិ (NGO និងគណបក្សនយោបាយ) ចំពោះ "ប្រជាជនសាមញ្ញ" ជាញឹកញាប់ច្រើនតែជាប់ពាក់ព័ន្ធនឹងរឿងឧត្តមគតិខ្លាំងណាស់ (See Hughes and Real, *op. cit.)* ។

លើភូមិនានានៅខេត្តបាត់ដំបង ។ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩ ស្ថាប័នសង្គម ដូចជា ឋានានុក្រមខាងសាសនាជាដើម ដែលជាប្រពៃណីគឺជាចំណុចស្នូលនៃជីវភាពនៅក្នុងភូមិ ឋានានុក្រមក្នុងក្រុមគ្រួសារ និងឋានានុក្រមជាទូទៅនៃការគោរពចាស់ទុំក្នុងភូមិ បានទទួលរងការបាក់បែកខូចខាត ។ លោក មាស នី បានបកស្រាយជាពិសេសពីឥទ្ធិពលធ្វើឱ្យបាក់បែកខ្ចាត់ខ្ចាយនៃការបំផ្លិចបំផ្លាញនូវមូលដ្ឋានអំណាចត្រួតត្រាក្នុងសង្គម ។

*នៅក្នុងភូមិយើង មនុស្សទាំងអស់ដែលប្រជាជនគោរពរាប់អានត្រូវបានគេវែកមុខថាក្បត់ ។ ព្រះសង្ឃត្រូវបានសំលាប់ចោល ហើយវត្ត (ក្នុងភូមិ) ត្រូវបានបំផ្លាញខ្ទេចខ្ទី ។ ក្រៅពីអាចារ្យម្នាក់ចេញ ទាំងអស់គ្នាត្រូវសំលាប់ចោលនៅឯវត្ត ។ អាចារ្យម្នាក់ដែលគេទុកជីវិតឱ្យគាត់ចូលដៃជាមួយខ្មែរក្រហម... ។ ទោះបីអាចារ្យក៏អាចជាឃាតករដែរ ដូច្នេះហើយប្រជាជនមិនដឹងទុកចិត្តអ្នកណាទេ*[៥៤] ។

មាស នី បានពិពណ៌នាថា សម័យកម្ពុជាប្រជាធិបតេយ្យបានបំផ្លិចបំផ្លាញសំបើមណាស់ ពីព្រោះវាបានបំផ្លាញចោលអស់នូវទំនុកចិត្តក្នុងភូមិតាមរយៈបណ្ដាញអ្នកយកការណ៍ដ៏ធំទូលាយមួយ ។ ការភ័យខ្លាចពីរឿងក្បត់ វាកើតមានគ្រប់ពេលទាំងអស់ ហើយអ្នកប្រឈមគ្រោះថ្នាក់ធំបំផុត គឺអ្នកដែលគេគោរពច្រើនបំផុតកាលពីសម័យមុនៗ ។

ក្នុងរបាយការណ៍ មាស នី បានលើកច្រើនដងពីការបំបាត់សិទ្ធិអំនាចរបស់ប្រជាជនក្នុងបណ្ដាទសវត្សរ៍មានសង្គ្រាម ។ ការបំបាត់សិទ្ធិ បានឡើងខ្ពស់បំផុតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ នៅពេលនោះ វិធានដ៏ចាំបាច់សំរាប់យករស់ជីវិតគឺៈ

*...កុំគិតអ្វីទាំងអស់ ។ កុំគិតអ្វី ទោះបីគេចាប់មនុស្សពីផ្លូវយកទៅសំលាប់នៅចំកន្លែងដែលខ្ញុំកំពុងឈរក៏ដោយ ។ ខ្ញុំមិនអាចជួយបាន ដូច្នេះខ្ញុំមិនត្រូវគិតអ្វីទេ ។ ដូចលង់ទឹកអ៊ីចឹង គឺគ្មានកំលាំងអ្វីទាំងអស់*[៥៥] ។

ប៉ុន្តែមិនមែនមានតែរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ដែលបំបាត់សិទ្ធិអំណាចរបស់ប្រជាជនធម្មតា ។ មាស នី បានវែកញែកថា ទំនាក់ទំនងតាមធម្មតានៃសិទ្ធិអំណាច ត្រូវបានផ្តួលរំលំដោយច្បាប់តាមចុងអាវុធ ។ គាត់បានលើកថា រឿងនេះវាមានពិតសំរាប់ "ក្រុមបក្ស" ផ្សេងៗៈ "ពួកទាហានមានកំលាំង ប្រជាជនក្នុងភូមិគ្មានអំណាចអ្វីសោះ"[៥៦] ។ បទពិសោធន៍ក្រោយមកទៀតនៃជីវិតជាជនភៀសខ្លួននៅឯព្រំដែនថៃ បានបង្ហាញប្រភេទនៃការបំបាត់សិទ្ធិអំណាចថ្មីមួយទៀតៈ

*អស់រយៈពេលយូរណាស់ដែលការក្រឡេកឃើញមន្ត្រី ជាពិសេសមន្ត្រីមកទារយកក្រដាសស្នាមខ្ញុំទៅផ្ទៀងផ្ទាត់ គឺធ្វើឱ្យខ្ញុំមានអារម្មណ៍ថាខ្លួនឯងគ្មានសិទ្ធិអំណាចអ្វីសោះ និងស្ថិតក្នុងគ្រោះថ្នាក់ទាំងស្រុង*[៥៧] ។

ចំណាប់អារម្មណ៍ថាខ្លួនឯងគ្មានសិទ្ធិអំណាច ប្រហែលផុសចេញពីការបំផ្លិចបំផ្លាញទំនាក់ទំនងក្នុងសហគមន៍ដែលបុគ្គលតែងធ្លាប់ស្គាល់ ហើយបុគ្គលនោះតែងធ្លាប់ធ្វើការនៅក្នុងនោះ ។ នៅខាងក្រៅទីជ្រកកោនក្នុងសហគមន៍ (ដែលក្នុងនេះបុគ្គលធ្វើប្រតិបត្តិការយ៉ាងនឹងនៅក្នុងចិត្ត ដើម្បីកសាងទុនដ៏ចាំបាច់ៗសំរាប់ការរួចរស់ជីវិត) និងនៅចំពោះមុខនៃកំលាំងពីក្រៅដ៏មានអំណាច (ដូចជា ការធ្វើយោធាភាវូបនីយកម្ម ឬការិយាធិបតេយ្យនៃជំរំជនភៀសខ្លួន), អ្នកភូមិកាន់តែពិបាកខ្លាំងឡើងក្នុងការធ្វើផែនការយុទ្ធសាស្ត្រដើម្បីយករស់ជីវិត ។ ឥទ្ធិពលដក់ជាប់យូរនៃបទពិសោធន៍ទាំងនេះ ទៅលើសមត្ថភាពរបស់សហគមន៍ក្នុងការកសាងទំនាក់ទំនងជួយទ្រទ្រង់ និងជួយត្រួតត្រារបស់សង្គមឡើងវិញ គឺជាបញ្ហាដ៏សំខាន់មួយសំរាប់ធ្វើការស្រាវជ្រាវ ។ លោក មាស នី បានលើកទៀតថាៈ

*ការកសាងសង្គមស៊ីវិល នៅក្រោយពេលមានទំនាស់តាមផ្លូវអាវុធ វាពិបាកដូចគ្នានឹងការបញ្ចប់សង្គ្រាមដែរ...*

---

៥៤ Meas Nee (1995), *Toward Restoring Life, Cambodian Villages,* translated and transcribed by Joan Healy, (Phnom Penh: Krom Akphiwat Phum), p. 21

៥៥ *Ibid.,* pp. 25-26

៥៦ *Ibid.,* p. 24

៥៧ *Ibid.,* p. 30

*លើសពីនេះទៅទៀត ការកកើតសង្គមស៊ីវិលរិតតែពិបាកថែមទៀត ដោយសារទំនុកចិត្តរវាងបុគ្គលត្រូវបានបំផ្លាញចោល ហើយសន្ទុះចិត្តរបស់ប្រជាជនក្នុងការកែប្រែសង្គមបានទទួលរង និងបន្តទទួលរងការបំផ្លិចបំផ្លាញជាបន្តបន្ទាប់[៥៨] ។*

ថែមពីលើការប្រែប្រួលចំពោះការយល់ដឹងពីទំនាក់ទំនងនៅក្នុងភូមិ សង្គ្រាមក៏បង្កឱ្យមានការផ្លាស់ប្តូរពិត១ នៅក្នុងសមាសភាពភូមិដែរ ។ ដោយឡែក ចលនាផ្លាស់ទីរបស់ជនភៀសខ្លួនក្នុងសម័យសង្គ្រាម បានធ្វើឱ្យប្រែប្រួលដល់សហគមន៍នៅក្នុងភូមិដែលកន្លងមកតែងតែពាក់ព័ន្ធនឹងបណ្តាញសាច់ញាតិ ។ សំខាន់ជាងនេះទៀត នៅពេលជនភៀសខ្លួន ឬទាហានរំសាយត្រឡប់មកភូមិកំណើតវិញ អ្នកដែលបានចាកចេញច្រើនឆ្នាំពេក គឺមិនអាចចូលទៅជីវភាពក្នុងភូមិវិញបានតាមសំរួល ហាក់បីដូចជាខ្លួនមិនដែលបានចាកចេញពីភូមិសោះនោះទេ ។ ជីវភាពនៅជំរំ ឬជីវិតជាទាហានក្នុងកងទ័ពផ្សេង១ជាញឹកញយបានធ្វើឱ្យបាត់បង់នូវជំនាញដាំដុះ និងធ្វើឱ្យប្រែប្រួលដល់អាកប្បកិរិយា ។ អ្នកនិពន្ធម្នាក់លើកឡើងថា ជនមាតុភូមិនិវត្តន៍ជាច្រើនបានប្រែប្រួលទស្សនៈអំពីអត្តសញ្ញាណរបស់ខ្លួន ដោយសារតែបទពិសោធន៍ជាជនភៀសខ្លួន ហើយរឿងនេះបានកាត់ផ្តាច់ពួកគេចេញពីអ្នកភូមិផងគ្នាដែលមិនបានចាកចេញពីភូមិ[៥៩] ។ ឧទាហរណ៍ NGO មួយដែលធ្វើការជាមួយទាហានរំសាយបានរកឃើញថា:

*មានតែមួយចំនួនតូចប៉ុណ្ណោះដែលមានវិន័យ និងមានសមត្ថភាពអាចឆ្លងកាត់ការបណ្តុះបណ្តាល និងអាចបើកអាជីវកម្មតូចមួយបានប្រកបដោយជោគជ័យ... ជាញឹកញយពួកគេគ្មានបុគ្គលិកលក្ខណៈសមស្របដើម្បីធ្វើជាអ្នករកស៊ីទេ ប៉ុន្តែរឿងនេះវាប្រែប្រួលខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ។ ជាទូទៅ ពួកគេខ្វះទំនុកចិត្ត មានចរិតឆេវឆាវ មានទំលាប់ទទួលបញ្ជាជាជាងសំរេចអ្វី១ដោយខ្លួនឯង និងមានទំលាប់យកអ្វី១តាមអំពើចិត្តដោយសំអាងលើចុងអាវុធ[៦០] ។*

ការលំបាកសំរបសំរួលជាមួយបុគ្គលទាំងឡាយ ដែលធ្លាប់ស៊ាំនឹងជីវភាពរស់នៅក្នុងមូលដ្ឋានតាមព្រៃភ្នំ ហើយដែលត្រូវមករស់នៅក្នុងបរិវេណភូមិតូចមួយ វាជាប្រភពនៃទំនាស់ ។ ធនធាន និងស្តង់ដាផ្សេង១ដែលបុគ្គលយកតាមខ្លួន ចូលមកក្នុងភូមិ និងការឃ្លាតឆ្ងាយរបស់ពួកគេចេញពីរចនាសម្ព័ន្ធក្រៅផ្លូវការនៃការត្រួតត្រាក្នុងភូមិ វាអាចធ្វើឱ្យទំនៀមទំលាប់គ្រប់គ្រងទំនាស់តាមបែបមូលដ្ឋាន មិនសូវមានប្រសិទ្ធិភាពក្នុងការចាត់ចែងជាមួយពួកជនដែលមានចរិត ជាអ្នកក្រៅមួយក៏រិតបែបនេះទេ ។ ចំពោះតំរូវការវិនិយោគលើទុននិមិត្តរូបដែលជាមូលដ្ឋាននៃទំនាក់ទំនងរបស់សហគមន៍ក្នុងភូមិ ជនទាំងនេះក៏មិនបានផ្តល់សារៈសំខាន់ឱ្យដែរ ពីព្រោះពួកគេ ឬមួយមានទំលាប់រស់នៅក្នុងសហគមន៍កងទ័ពដែលធ្វើប្រតិបត្តិការតាមស្តង់ដាខុសគ្នាឆ្ងាយ ឬមួយពួកគេមានធនធានផ្សេងទៀត ដូចជាអាវុធជាដើម ដែលធ្វើឱ្យការវិនិយោគក្នុងទុនអរូបីផ្សេងទៀតលែងមានការចាំបាច់ ។

## *៣. ផលប៉ះពាល់នៃផ្សារសេរី*

វាជារឿងមួយសំខាន់ដែរដែលការសិក្សារបស់ Krishnamurthy បានរកឃើញថា និន្នាការកាន់តែមានចីរភាពឡើងនៃការផ្លាស់ប្តូរក្នុងទុនសង្គមកិច្ចនៅក្នុងភូមិ វាផុសចេញពីការជ្រៀតចូលកាន់តែជ្រៅនៃរបបមូលធននិយម ទៅក្នុងសេដ្ឋកិច្ចនៅជនបទ ។ Krishnamurthy បានលើកថា:

*បណ្តាញចាស់១ដែលផ្អែកលើទស្សនៈនៃការជួយគ្នាទៅវិញទៅមក បានចុះខ្សោយនៅចំពោះមុខបណ្តាញថ្មី១ដែល*

---

៥៨ Meas Nee (1999), “The Legacy of Armed Conflict and Community Rebuilding,” *The Meaning of Community in Cambodia: Literature Reviews, Khmer, French and English Languages,* (Phnom Penh: Working Group on Social Organization in Cambodia) p. 6

៥៩ Court Robinson (1994), *Rupture and Return – Repatriation, Displacement and Reintegration in Battambang Province, Cambodia,* Occasional Paper no. 7 (Bangkok: Indochinese Refugee Information Centre, Institute of Asian Studies, Chulalongkorn University)

៦០ Prum Sam Ol et al. (1996), *Starting Over, the Reintegration Experience of Returnees, Internally Displaced, and Demobilized Soldiers in Cambodia,* Cambodian Veterans Assistance Program Executive Secretariat, Background Study, (Phnom Penh: Cambodian Veterans Assistance Program) p. 21

*ផ្អែកលើគោលការណ៍បដិការយ៉ាងតឹងរ៉ឹង* (rigid reciprocity), *និងតំរូវការរកបានចំណូលជាប្រាក់ ដូចគេអាចមើលឃើញយ៉ាងច្បាស់នៅក្នុងករណីនៃការប្រវាស់ដៃ ។ ទឹកចិត្តជួយគ្នាទៅវិញទៅមកដែលគេឃើញមាននៅក្នុងសម័យមុនសង្គ្រាម មិនមែនត្រូវបានបំផ្លាញដោយសារសង្គ្រាមនោះទេ ពីព្រោះភ្លាមៗក្រោយពេលបញ្ចប់ទំនាស់ទឹកចិត្តបែបនេះបានផុសចេញមកក្នុងរូបភាពជាច្រើនដូចជាការរស់ឡើងវិញនៃការប្រវាស់ដៃជាដើម ។ ការចុះខ្សោយនៃទស្សនៈជួយគ្នាទៅវិញទៅមកនៅក្នុងបណ្តាញក្រៅផ្លូវការ ត្រូវបានប្រជាជនក្នុងភូមិទាំងពីរគិតថា បានកើតឡើងក្នុងទសវត្សរ៍១៩៩០, ដោយសារសេដ្ឋកិច្ចប្រើប្រាក់កាស បំណងប្រាថ្នាចង់រកបានទ្រព្យធន និងសំពាធនៃការដោះស្រាយជីវភាពបានបង្ខំឱ្យប្រជាជនគិតគូរជាមុនពីបញ្ហា និងតំរូវការនានារបស់ខ្លួនផ្ទាល់*[៦១] ។

ការជ្រៀតចូលកាន់តែជ្រៅនៃមូលធននិយមក៏ជាគោលដៅដែលរដ្ឋាភិបាលបានប្រកាសឡើងដែរ ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៦-២000 បានលើកថា:

ស្របគ្នានឹងការកាត់បន្ថយភាពក្រីក្រ ការបង្កើនប្រាក់ចំណូលខាងកសិកម្មអាចបង្កើតបាននូវ អំណាចទិញ (purchasing power) ដែលត្រូវមានជាចាំបាច់សំរាប់ការពង្រីកប្រាក់ចំណូលក្រៅពីកសិកម្ម ឱកាសមានការងារធ្វើ និងសំរាប់ការអភិវឌ្ឍន៍ទីផ្សារផ្ទៃក្នុង ។ ការរីកចំរើនក្នុងទិសដៅទាំងនេះ ក៏ត្រូវមានជាចាំបាច់ដើម្បីធានាឱ្យមានការធ្វើសមាហរណកម្មនៃសេដ្ឋកិច្ចជាតិ ការចងបាច់គ្នានៃសង្គមក្នុងទូទាំងប្រទេស និងការកែលំអសន្តិសុខក្នុងតំបន់ឆ្ងាយដាច់ស្រយាលនានា[៦២] ។

ផែនការបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការចូលរួម និងការផ្តល់សិទ្ធិអំណាច នៅក្នុងការងារអភិវឌ្ឍន៍ជនបទ ហើយក្នុងនេះគេមានគោលដៅច្បាស់លាស់ពីរ ។ ទី១ បំណងប្រាថ្នាជំរុញការជ្រៀតចូលនៃទំនាក់ទំនងផលិតកម្ម តាមបែបមូលធននិយម និងសេដ្ឋកិច្ចប្រើប្រាក់កាស ទៅក្នុងអតីតភូមិដែលធ្វើកសិកម្មជីវព្រឹត្តនានា ត្រូវបានបញ្ជាក់យ៉ាងច្បាស់ ។ ទី២ សមាហរណកម្មតាមរយៈទំនាក់ទំនងផលិតកម្ម និងតាមរយៈសកម្មភាពអភិវឌ្ឍន៍ភូមិនានារបស់រដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដែលកាលពីមុននៅឯកោតែឯង ក៏ជាគោលដៅគន្លឹះមួយដែរ ។ គោលដៅទាំងនេះ ត្រូវជួបបញ្ហាប្រឈមនឹងការលើកកំពស់សារៈសំខាន់នៃការវិនិយោគលើទុនសង្គមកិច្ចនៅក្នុងភូមិ (ក្នុងពេលដែលទុនជាសំភារៈបានក្លាយជាសំខាន់កាន់តែខ្លាំងឡើងៗ) ព្រមទាំងសារៈសំខាន់នៃធនធានខាងសិទ្ធិអំនាច ដែល Collins បានយល់ថា វាចាំបាច់បំផុតដើម្បីឱ្យប្រធានភូមិ អាចគ្រប់គ្រងទំនាស់បានដោយសក្តិសិទ្ធិ ។ ដោយបង្កើនទំនាក់ទំនងជាមួយពិភពលោកខាងក្រៅ (ដែលធ្វើឱ្យទំនាក់ទំនងក្នុងសហគមន៍ចុះខ្សោយ) ដំនើរការអភិវឌ្ឍន៍សេដ្ឋកិច្ចបាន ធ្វើឱ្យចុះខ្សោយគួរឱ្យកត់សំគាល់ដល់មូលដ្ឋាន ជាទុននិមិត្តរូបនៃអំណាចរបស់ប្រធានភូមិ (ដូចដែល Collins បានពិពណ៌នា) ។

ផ្អែកតាមរបៀបវារៈរបស់រដ្ឋាភិបាលនេះ ការស្រាវជ្រាវពីការប្រើប្រាស់ជំនាញគ្រប់គ្រងទំនាស់ក្នុងពេលបច្ចុប្បន្ន ត្រូវតែអនុវត្តជាចាំបាច់នៅក្នុងក្របខ័ណ្ឌមួយដែលគិតគូរពីការប្រែប្រួលក្នុងរយៈពេលវែងនៃទំនាក់ទំនង រវាងភូមិ និងពិភពខាងក្រៅ ។ ការឆ្លើយតបរបស់មូលដ្ឋាន ទៅនឹងដំនើរការបែបនេះ គឺជាប្រធានបទគន្លឹះមួយនៅក្នុងឯកសារនានាដែលសិក្សាពីប្រជាកសិករ ។

Eric Wolf បានផ្តល់មតិដ៏មានប្រយោជន៍មួយ អំពីឥទ្ធិពលនៃទំនាក់ទំនងបែបមូលធននិយមទៅលើភូមិនៅជនបទ:

*មូលធននិយមវាមានលក្ខណៈខុសពីធម្មតា ទាំងចំពោះល្បឿន និងកំលាំងនៃប្រតិបត្តិការរបស់វា ពីព្រោះវាបង្កើតចេញនូវធនធានដែល "អណ្តែតសេរី" ហើយកាលពីមុនត្រូវចងជាប់ស្មៀម ដោយសារបណ្តាញខ្សែខាងសង្គមកិច្ច និងនយោបាយ ។ មូលធននិយមកេណ្ឌប្រមូលធនធានសេដ្ឋកិច្ចនានា ហើយធ្វើឱ្យធនធានទាំងនេះ អាចរ៉ាប់រងការបែងចែកនិងការប្រើប្រាស់តាមរូបភាពថ្មីៗទៀតបាន ។ ប៉ុន្តែនៅក្នុងការងារនេះវាក៏កាត់ផ្តាច់ចំណងទាក់ទង*

---

៦១ Veena Krishnamurthy, *op. cit.*, p. 62
៦២ Royal Government of Cambodia (1995), *First Socioeconomic Development Plan, 1996-2000* (Phnom Penh: RGC) Ch.4

> *ផងដែររវាងធនធាន និងខ្សែទំនាក់ទំនងដែលធនធានទាំងនេះធ្លាប់មានពីមុន ជាមួយនឹងបុព្វសិទ្ធិជាប្រពៃណីខាងសង្គមកិច្ច និងនយោបាយ ។ មូលធននិយមគឺជាទឹកសំរាប់រំលាយគ្រឿងការពារសិទ្ធិអំណាចយ៉ាងខ្លាំងក្លា ហើយវាបង្កើនភាពតានតឹង មិនត្រឹមតែតាមរយៈសកម្មភាពរបស់វាផ្ទាល់បុណ្ណោះទេ ប៉ុន្តែតាមរយៈការរំដោះភាពតានតឹង និងទំនាស់ផ្សេងៗ ដែលកាលពីមុនត្រូវចងជាប់អស់ដោយសារប្រព័ន្ធអំនាចជាប្រពៃណី... ។ សកម្មភាពឱ្យ-និង-យក នៅក្នុងសង្គមដែលកំនត់ចេញពីទស្សនៈជាប្រពៃណីនៃកាតព្វកិច្ច និងបំនងល្អ គឺត្រូវបានជំនួសវិញដោយកំរងច្បាប់ដ៏រឹងកំព្រឹសដែលទ្រទ្រង់ដោយកំលាំងអបុគ្គលមួយ*[៦៣] ។

លក្ខណៈអបុគ្គលនៃទំនាក់ទំនងមូលធននិយម វាផ្ទុយគ្នាពីចរិតផ្សារភ្ជាប់ខ្លាំងនឹងបុគ្គលនៃការត្រួតត្រារបស់សង្គមតាមរយៈការឱ្យតំលៃខ្ពស់ដល់ទស្សនៈនៃ "កេរ្តិ៍ឈ្មោះល្អ" ។ ក្នុងសេដ្ឋកិច្ចប្រើប្រាក់កាស ទុននិមិត្តរូបបានបាត់បង់អំនាចរបស់ខ្លួនដូច្នេះ ហើយការអត់ធ្មត់ប្រយ័ត្នប្រយែងផ្សេងៗក្នុងអាកប្បកិរិយា ដោយសារតំរូវការធ្វើវិនិយោគក្នុងទុននិមិត្តរូបក៏ចុះខ្សោយដែរ ។ នៅក្នុងទសវត្សរ៏១៩៦០ អ្នកស្រាវជ្រាវពីទ្រឹស្តីទំនើបភាវូបនីយកម្ម បានយកនិន្នាការនេះធ្វើជាមូលដ្ឋានសំរាប់ជំរុញ "ការកសាង ជាតិ" ដែលជាយុទ្ធសាស្រ្តមួយសំរាប់ធ្វើការអភិវឌ្ឍន៍ ។ ឧទាហរណ៏ៈ

> *ច្បាប់រដ្ឋ... បានក្លាយជាមធ្យោបាយសំរាប់ឱ្យសង្គមនានាលើកស្ទួយខ្លួនឯងឱ្យបានខ្ពស់ហួសពីរឿងយុត្តិធម៌ឯកជនសហគមន៏តូចៗ និងទំនាក់ទំនងខាងឋានៈ ។ នីតិរដ្ឋមានទិសដៅជំនះឱ្យបាននូវបញ្ហាវត្ថុមានសីលធម៌ច្រើនបែបយ៉ាងនៅក្នុងសង្គមទាន់សម័យដែលមានលក្ខណៈខុសៗគ្នាយ៉ាងខ្លាំង តាមការកសាងឡើងនូវវេទិកាសាធារណៈអព្យាក្រិត្យមួយដែលដាក់អនុវត្តវិធានទូទៅនានាដោយស្មើៗគ្នាទៅលើបុគ្គលទាំងអស់ ។ ស្វយភាពលក្ខណៈវិជ្ជាជីវៈ និងលក្ខណៈប្រមូលផ្តុំនៃរបបនេះ នឹងផ្តល់នូវវប្បធម៌គោរពច្បាប់មួយមានតក្កវិជ្ជា* (logic) *របស់វាផ្ទាល់ដែលខុសប្លែកពីស្តង់ដា និងផលប្រយោជន៏ខាងសេដ្ឋកិច្ច នយោបាយ សាសនា ឬវិទ្យាសាស្ត្រ*[៦៤] ។

ការឆ្លើយតបរបស់កសិករទៅនឹងការប្រែប្រួលខាងសេដ្ឋកិច្ចនៅកម្ពុជា មានអធិប្បាយនៅក្នុងសំណេរនានា របស់ពួកអ្នកសិក្សាខាងទ្រឹស្តីនៃ CPK (គណបក្សកុម្មុយនីស្តកម្ពុជា) ក្នុងទសវត្សរ៏១៩៦០[៦៥] ។ អ្នកនិពន្ធទាំងនេះ បានផ្តល់ការវិភាគផ្អែកលើវណ្ណៈនៃទំនាក់ទំនងធ្វើអាជីវកម្មកេញប្រវ័ញ្ច និងពោរពេញដោយទំនាស់ រវាងកសិករ-ផលិតករ និងតួអង្គសេដ្ឋកិច្ចផ្សេងទៀត ជាពិសេសអ្នកចងការប្រាក់ ម្ចាស់ដី និងអ្នកជំនួញ ។ ប៉ុន្តែការសិក្សាទាំងនេះត្រូវតែយកមកប្រើប្រាស់ដោយប្រុងប្រយ័ត្នពីព្រោះវាទទួលឥទ្ធិពលយ៉ាងច្បាស់ពីចំណុចព្រួយបារម្ភខាងមនោគមន៏វិជ្ជាដូចមានបញ្ជាក់ក្នុងពាក្យទំនឹមទំនៀមថា "ទស្សនវិទូគ្រាន់តែបាន *បកស្រាយ* ពិភពលោកតាមច្រើនបែបប៉ុណ្ណោះ ប៉ុន្តែរឿងសំខាន់គឺត្រូវផ្លាស់ប្តូរវាចេញ"[៦៦] ។ ប៉ុន្តែ Ben Kiernan បានប្រើប្រាស់ឯកសាររបស់ ហ៊ូ-យន់ ហ៊ូ-នឹម ដើម្បីអះអាងថា គេឃើញមានការអាក់អន់ចិត្តជាទូទៅក្នុងសហគមន៏កសិករកម្ពុជានៅចុងទសវត្សរ៏១៩៦០[៦៧] ។

ការសិក្សាជ្រៅថែមទៀតរបស់ Kiernan ពីមូលហេតុនៃការបះបោរនៅសំឡូតក្នុងឆ្នាំ១៩៦៧-៦៨ បានបង្ហាញថា

---

៦៣ Eric R. Wolf, *op. cit.,* p. 283

៦៤ A.V. Horwitz (1990), *The Logic of Social Control* (London: Plenum), quoted in Colin Sumner (1997), “Social Control: the History and Politics of a Central Concept in Anglo-American Sociology,” in Roberto Bergalli and Colin Sumner (eds.), *Social Control and Political Order, European Perspectives at the End of the Century* (London: Sage) p. 19

៦៥ Hou Yuon (1955), “The Peasantry of Kampuchea: Colonialism and Modernisation,” extracts from *La Paysannerie du Cambodge et ses Projets de Modernisation*, Doctoral thesis (University of Paris), translated by Ben Kiernan, in Kiernan and Boua (eds.) (1982), *Peasants and Politics in Kampuchea, 1941-1981* (London: Zed Press), pp.31-68; Hu Nim (1965), “Land Tenure and Social Structure in Kampuchea,” extracts from *Les Services Publics Economiques du Cambodge,* Doctoral thesis (University of Phnom Penh), translated by Ben Kiernan, in Kiernan and Boua, *op.cit.,* pp.69-86; Khieu Samphan (1959), “Cambodia’s Economy and Industrial Development”, Doctoral thesis (Paris), translated by Laura Summers (1979), in Cornell University Southeast Asia Program Data Paper No. 111 (Ithaca: Cornell University Southeast Asia Program)

៦៦ Karl Marx and Frederick Engels, “Theses on Feuerbach,,” in C.J. Arthur (ed.) (1974), *The German Ideology,* student edn. (London: Lawrence and Wishart) p. 123

៦៧ Kiernan, “Introduction” in Kiernan and Boua, *op. cit.,* p. 13

អ្នកសិក្សាទ្រឹស្តីរបស់ CPK បានរកឃើញ (យ៉ាងហោចណាស់ក៏សំរាប់តំបន់ខ្លះនៅកម្ពុជាដែរ) ផលប៉ះពាល់ដែលបានធ្វើឱ្យបែកបាក់នៃការលូតលាស់មូលធននិយមក្នុងទសវត្សរ៍១៩៦០ យ៉ាងត្រឹមត្រូវ ។ Kiernan បានជជែកវែកញែកថា ការបះបោរនៅសំឡូត វាផុសចេញពីការជ្រៀតចូលរបបផលិតកម្មបែបមូលធននិយមទៅក្នុងសេដ្ឋកិច្ចសំរាប់ដោះស្រាយមួយរស់ នូវដំណាំសំរាប់លក់យកប្រាក់ និងការប្រើកំលាំងយោធា ដើម្បីដាក់អនុវត្តគោលនយោបាយទិញស្រូវអង្ករបស់រដ្ឋ នៅក្នុងតំបន់នានាដែលជាតំបន់ដាច់ស្រយាលកាលពីមុន[៦៨] ។ Frieson បានឯកភាពចំពោះការពន្យល់នេះ និងបានកត់សំគាល់ថែមថា ដំណើរការគ្រប់គ្រងទំនាស់ដែលផុស ចេញពីការវិវត្តន៍បែកបាក់គ្នានេះ វាមិនមែនស្រួលមើលឃើញនោះទេ ។ គាត់រាយការណ៍ថា:

> *កសិករក្រីក្រគ្មានលំនឹងអ្វីសោះនៅចំពោះមុខ ពួកវិនិយោគិនដែលបង់ប្រាក់ឱ្យមន្ត្រីសុរិយោដី ដើម្បីបានប័ណ្ណកម្មសិទ្ធិដី ។ នៅពេលដែលគ្រឿងចក្រប៊ុលដូស៊័រមកដល់ដើម្បីរុញពួកអតីតម្ចាស់ដីចេញឱ្យអស់ និងរៀបចំដីសំរាប់ធ្វើចំការ ទើបកសិករក្នុងតំបន់មានកំហឹងពុះកញ្ជ្រោល ហើយបានសំលាប់អ្នកបើកបរប៊ុលដូស៊័រនោះទៅ*[៦៩] ។

ការសិក្សាទាំងនេះ បានបញ្ជាក់គាំទ្រដល់ផលប៉ះពាល់ដែលធ្វើឱ្យបែកបាក់ដំណើរការជ្រៀតចូលនៃមូលធននិយម ការកសាងជាតិ និងសារៈសំខាន់របស់វាក្នុងការបង្កទំនាស់ ។

របបកម្ពុជាប្រជាធិបតេយ្យ និងភាពឯកោនៃសេដ្ឋកិច្ចកម្ពុជាក្នុងទសវត្សរ៍១៩៨០ បានធ្វើឱ្យគាំងដល់ដំណើរការធ្វើរូបិយវត្ថុនីយកម្មនៃសេដ្ឋកិច្ចនៅក្នុងជនបទកម្ពុជា ។ ការវិភាគខាងសេដ្ឋកិច្ចនៃមាតិកាអភិវឌ្ឍន៍កម្ពុជាក្នុងទសវត្សរ៍១៩៩០ បានបង្ហាញពីភាពមិនស្មើគ្នាកាន់តែខ្លាំងខាងធនធាន និងការជ្រៀតចូលកាន់ជ្រៅនៃរបបផ្សារសេរី ទៅក្នុងជីវភាពនៅតាមជនបទក្រោមរូបភាពជាការធ្វើឯកជនភាវូនីយកម្មនូវធនធាននានាដែលពីមុនប្រជាជនអាចប្រើបានដោយសេរី ដូចជាបឹងបួរ និងព្រៃឈើជាដើម ព្រមទាំងការជួញដីធ្លី ។ ការវិវត្តន៍ទាំងនេះប្រហែលញ៉ាំងឱ្យមានការកែតំរូវរចនាសម្ព័ន្ធខាងសង្គមកិច្ចថែមទៀត និងជានិមិត្តរូបនៃភូមិនៅតាមជនបទ ។ ការវាយតំលៃពីបែបបទ ដែលភូមិបានស្រូបយកនូវការផ្លាស់ប្តូរទាំងនេះ វាអាចជាកត្តាគន្លឹះសំរាប់ពន្យល់ពីមូលហេតុនៃទំនាស់ក្នុងពេលសព្វថ្ងៃ និងពីជោគជ័យ ឬបរាជ័យនៃការងារគ្រប់គ្រងទំនាស់ដែលគេកំពុងអនុវត្តនៅតាមូលដ្ឋាន ។

## *៤. ផលប៉ះពាល់នៃកំណែទំរង់ខាងនយោបាយ*

របៀបរបបអភិវឌ្ឍន៍បែបនេះ គឺជាដើមភ្លើងទំនាស់មួយចំនួន ហើយទំនាស់ខ្លះបានបង្កឡើងនូវបាតុកម្មនៃគូភាគីមានទំនាស់នៅឯខាងមុខអគាររដ្ឋសភា ឬព្រះបរមរាជវាំង ។ ការណ៍ដែលភាគីមានទំនាស់បានសំរេចពាំនាំការកើតទុក្ខមិនសុខចិត្តរបស់ខ្លួនមកភ្នំពេញ វាឆ្លុះបញ្ចាំងនូវការពិពណ៌នារបស់ Ebihara អំពីផ្លូវដើរដែលគូភាគីក្នុងទំនាស់ធ្ងន់ធ្ងរនាសម័យមុនសង្គ្រាមបានប្រកាន់យក ។ Ebihara បានសរសេររឿងនេះតាំងពីសម័យសម្តេចសីហនុ ធ្វើជានាយករដ្ឋមន្ត្រីក្នុងរបបសង្គមរាស្ត្រនិយមនោះម្លេះ ហើយគាត់បានកត់សំគាល់ថា សម្តេចត្រូវបានកសិករមើលឃើញថានៅជិតខ្លួន និងអាចទាក់ទងបាន ទោះបីការជួបប្រាស្រ័យនានារបស់សម្តេចជាមួយប្រជាជន គឺមានរូបភាពជាការរៀបចំឆាកកិត្តិយសក៏ដោយ ។

ក្នុងទសវត្សរ៍១៩៩០ ផ្លូវដើររបស់អ្នកដែលចង់ពាំនាំការកើតទុកមិនសុខចិត្តទៅភ្នំពេញ ជាញឹកញាប់តែងតែតំរង់ទៅកាន់ព្រះបរមរាជវាំង ដែលនៅទីនោះគេប្តឹងព្រះមហាក្សត្រឱ្យជួយអន្តរាគមន៍ ។ ប៉ុន្តែនៅក្នុងដំណើរការថ្មីៗខាងនយោបាយដែលត្រូវបានកសាងឡើងជាចំណែកមួយនៃការខំប្រឹងប្រែងធ្វើប្រជាធិបតេយ្យភាវូបនីយកម្មរបស់កម្ពុជា គេឃើញមានផ្លូវបីផ្សេងទៀតដែលអាចប្រើបានសំរាប់ដោះស្រាយជាមួយអ្នកមានអំណាច គឺតាមរយៈគណបក្សនយោបាយ តាមអង្គការសិទ្ធិមនុស្ស ឬតាមតំណាងនៅក្នុងរដ្ឋសភា ។

---

៦៨ Kiernan, Ben (1975), The Samlaut Rebellion and its Aftermath, the Origins of Cambodia's Liberation Movement Parts I and II, Working Paper No. 4 (Melbourne: Monash)

៦៩ Frieson, *op. cit.*, p. 37

អង្គការសិទ្ធិមនុស្សជាពិសេស និងគណបក្សនយោបាយ ព្រមទាំងតំណាងនៅរដ្ឋសភាមួយចំនួន បានផ្តល់ចំណងទាក់ទងស្ថាប័នរវាងភូមិ និងទីក្រុង ហើយចំណងទាក់ទងនេះត្រូវបានរៀបចំជាពិសេសដើម្បីជួយសំរួលដល់ការប្តឹងតវ៉ា និងការស្នើសុំជំនួយពីក្រៅដើម្បីដោះស្រាយបញ្ហាក្នុងភូមិ ។ បញ្ហាថាតើអ្នកភូមិមើលឃើញផ្លូវថ្មីៗសំរាប់ដោះស្រាយទំនាស់វាស្របនឹងចំណូលចិត្តរបស់អង្គការ/ងាយប្រើប្រាស់ល្អប៉ុណ្ណា ឬថាតើអង្គការទាំងនេះត្រូវបាន អូសទាញចូលទៅក្នុងការងារគ្រប់គ្រងទំនាស់ក្នុងលក្ខណៈជាប្រភពធនធាន ឬជាអ្នកផ្តល់ស្តង់ដាផ្សេងៗក្នុងកិរិតណាដែរ គឺសុទ្ធតែជាប្រធានបទដែលត្រូវស្រាវជ្រាវបន្ថែម ។

### *៥. ផលប៉ះពាល់នៃប្រព័ន្ធផ្សព្វផ្សាយ*

ឥទ្ធិពលពីក្រៅមួយទៀតទៅលើភូមិកម្ពុជា គឺវត្តមានកាន់តែច្រើនឡើងនូវពតិមាន និងគំនិតផ្សេងៗ ក្នុងរូបភាពជាពតិមានផ្សព្វផ្សាយ និងរឿងលំហែកំសាន្តនានានៅក្នុងប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស និងតាមការបោះពុម្ពផ្សាយ ។

ការសិក្សារបស់ Benedict Anderson អំពីឫសគល់នៃគំនិតជាតិនិយម បានបង្ហាញថា ការលូតលាស់នៃប្រព័ន្ធបោះពុម្ពផ្សាយរបស់ជាតិ គឺជាកាតាលីករ (catalyst) ដែលជំរុញការផុសឡើងនូវជាតិ ក្នុងលក្ខណៈជា "សហគមន៍ធំទូលាយនៅក្នុងចិត្តគំនិត" ដែលទាមទារភក្តីភាព និងការស្មោះត្រង់ពីសំណាក់ប្រជាពលរដ្ឋ[៧០] ។ រឿងនេះទាមទារការផ្លាស់ប្តូរចំនុចផ្តោតនៃភក្តីភាពរបស់ប្រជាពលរដ្ឋអំពីសហគមន៍ដែលនៅជិតជាប់ និងធ្លាប់មានទំនាក់ទំនងទល់មុខគ្នា ហើយត្រូវបានសំរបសំរួលដោយការដាក់ទណ្ឌកម្មលើបុគ្គលផ្ទាល់ដូចបានពិពណ៌នាខាងលើ ទៅជា "សហគមន៍ក្នុងចិត្តគំនិត" នៃទំនាក់ទំនងអបុគ្គលដែលបានទទួលការជួយសំរួលពីទីផ្សារ និងរដ្ឋ ។ ការផ្លាស់ប្តូរបែបនេះ មានផលប៉ះពាល់ចំបងទៅលើគោលគំនិត និងរបៀបរបបអនុវត្តការត្រួតត្រារបស់សង្គមជាក់ស្តែង ។

ផលប៉ះពាល់នៃការរីកដុះដាលប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា វាកាន់តែស្មុគស្មាញឡើងទៀតដោយសារកត្តាពីរ ។ ទី១ គឺការមាននយោបាយចូលលាយឡំ ជាពិសេសសារពតិមានដែលតែងប្រកាន់បក្សពួកខាងនយោបាយខ្លាំងណាស់ ។ ដោយហេតុថាសារពតិមានបែបនេះចុះផ្សាយរបាយការណ៍ និងការយល់ដឹងខុសគ្នាជាខ្លាំង ដូច្នេះវាបានផ្តល់នូវក្របខ័ណ្ឌស្តង់ដាផ្សេងៗដែលចំរូងចំរាស់គ្នា ហើយខុសប្លែកពីទំនៀមទំលាប់របស់ភូមិ ។ ទី២ ខ្លឹមសារនៃការផ្សព្វផ្សាយតាមរលកធាតុអាកាសនៅកម្ពុជា វាពុំសូវមានលក្ខណៈជាតិទេ តែមានលក្ខណៈអន្តរជាតិ ដូចជារឿងភាគថៃ វិទ្យុសំលេងសហរដ្ឋអាមេរិកជាដើម ។ ដូច្នេះក្របខ័ណ្ឌស្តង់ដាដែលប្រព័ន្ធទាំងនេះផ្តល់ឱ្យ វាតំនាងឱ្យការកាត់ផ្តាច់យ៉ាងគំហុកពីរបៀបអនុវត្តជាក់ស្តែង និងពីការយល់ដឹងកាលពីមុន ។

គេពិបាកធ្វើការវាយតំលៃឱ្យបានជាក់លាក់ពីផលប៉ះពាល់នៃកត្តាទាំងនេះ ប៉ុន្តែជារួមការរីកដុះដាលនៃប្រព័ន្ធផ្សព្វផ្សាយបានផ្តល់នូវលទ្ធភាពមួយទៀតដែលអាចគំរាមកំហែងដល់លក្ខណៈឯកភាពគ្នានៃស្តង់ដា រចនាសម្ព័ន្ធនៃការយល់ដឹង និងការត្រួតត្រាដែលធ្លាប់មានដំណើរការនៅតាមភូមិកម្ពុជាក្នុងអតីតកាល ។

## ឃ. សេចក្តីសន្និដ្ឋាន

ក្នុងការងារពិនិត្យមើលឯកសារនេះឡើងវិញ យើងបានខិតខំកសាងក្របខ័ណ្ឌទស្សនៈមួយដោយផ្អែកតាមការសិក្សាពីដំណើរការដោះស្រាយវិវាទរបស់ Collins, និងបានខិតខំដាក់បញ្ចូលការគ្រប់គ្រងទំនាស់ក្នុងភូមិកម្ពុជា ទៅក្នុងក្របខ័ណ្ឌមួយដែលគេបានលើកមតិឱ្យហៅថា "វប្បធម៌សន្តិភាព" ។

ក្នុងការខិតខំនេះ ចំណុចជាគន្លឹះមួយចំនួនត្រូវបានលើកឡើងៈ

១. ភូមិនានាគឺជាកន្លែងដ៏សំខាន់ដែលក្នុងនោះ ទំនាក់ទំនងទល់មុខគ្នាត្រូវបានធ្វើឡើង នៅក្រោមការពិនិត្យតាមដាន

[៧០] Benedict Anderson (1993), Imagined Communities, Reflections on the Origin and Spread of Nationalism, revised edn. (London:Verso)

ពីរដ្ឋពីតំណាងខាងសាសនា និងដោយផ្អែកតាមក្របខ័ណ្ឌទស្សនៈមួយស្តីពីអាកប្បកិរិយាសមស្រប ។

២. ក្នុងពេលជាមួយគ្នា ភូមិកម្ពុជាជាច្រើនកំពុងឆ្លងកាត់រយៈពេលមួយនៃការផ្លាស់ប្តូរ ដែលជាការឆ្លើយតបទៅនឹងផលប៉ះពាល់នៃចលនាជាតិផ្សេងៗ ដូចជា សង្គ្រាម ការកសាងជាតិ ការជ្រៀតចូលនៃមូលធននិយម ការធ្វើប្រជាធិបតេយ្យភាវូបនីយកម្ម និងការរីកដុះដាលកាន់តែខ្លាំងនៃប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ ។

៣. ការសិក្សាពីទំនាស់ និងការគ្រប់គ្រងទំនាស់ក្នុងភូមិកម្ពុជា នៅក្នុងក្របខ័ណ្ឌនៃគោលគំនិតខាង "វប្បធមិសន្តិភាព" វាទាមទារការពិនិត្យបញ្ហាទាំងឡាយទាំងខាងរចនាសម្ព័ន្ធ និងខាងទីភ្នាក់ងារនៅក្នុងការឆ្លើយតបនឹងទំនាស់ ។ ទំនាក់ទំនងរវាងអ្នកភូមិគេអាចស្វែងយល់បាននៅក្នុងក្របខ័ណ្ឌខាងរចនាសម្ព័ន្ធនៃវណ្ណៈ និងទំនាក់ទំនងតួនាទីបុរស-ស្ត្រី ដោយក្នុងនេះបុគ្គលនានាអនុវត្តយុទ្ធសាស្ត្រផ្សេងៗដើម្បីធានាដល់សុខុមាលភាពរបស់ខ្លួន ។ យុទ្ធសាស្ត្រទាំងនេះអាចជា វិនិយោគមួយខ្សែៗលើទុនខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងលើទុននិមិត្តរូប ។ ចរិត និងការបែងចែកក្នុងរឿងទាំងអស់នេះ ត្រូវបានកំណត់ឡើងដោយបណ្តាកត្តាខាងស្តង់ដា ក្នុងនេះមានរួមបញ្ចូលទាំងទស្សនៈពីអ្វីដែលត្រឹមត្រូវ និងពីអំណាចពេញសិទ្ធិផង ។

៤. ក្នុងករណីដែលអ្នកភូមិយល់ថា វិនិយោគបែបនេះមានសារៈសំខាន់ ពួកគេអាចទទួលយកការត្រួតត្រាក្រៅផ្លូវការ ដែលគ្រប់គ្រងជាពិសេសលើទុននិមិត្តរូប និងលទ្ធភាពប្រើប្រាស់ទុនសង្គមកិច្ច (ដែលគេអាចប្រែក្លាយទៅជាទុនសេដ្ឋកិច្ចបាន) ។

៥. បុគ្គលដែលមានទុននិមិត្តរូបច្រើន គឺអាចទទួលបាននូវសិទ្ធិអំណាចដើម្បីធ្វើអន្តរាគមន៍ក្នុងទំនាស់ ។

៦. ល្បឿននៃការផ្លាស់ប្តូរ, វត្តមានមនុស្សចំលែកដែលចូលមករស់នៅក្នុងភូមិ, និងការហូរចូលមកក្នុងភូមិនូវធនធានមកពីខាងក្រៅ បានបង្កើនឱកាសសំរាប់អ្នកភូមិដើម្បីស្វែងរកទុនសេដ្ឋកិច្ចយ៉ាងច្រើន ដោយមិនចាំបាច់ពឹងផ្អែកលើទុននិមិត្តរូបដែលតែងតែត្រូវការជាចាំបាច់នៅក្នុងសហគមន៍ឆ្ងាយដាច់ស្រយាល ។ ការបើកចំហកាន់តែធំទៅកាន់ពិភពលោកខាងក្រៅធ្វើឱ្យពួកអ្នកភូមិកាន់តែមិនសូវចុះញ៉មនឹងការដាក់ទណ្ឌកម្មក្រៅផ្លូវការពីសំណាក់អ្នកជិតខាង ហើយរឿងនេះមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំនៅមូលដ្ឋាន និងចំពោះយន្តការនានានៃការត្រួតត្រារបស់សហគមន៍ ។ នៅក្នុងលក្ខខណ្ឌនេះ វិនិយោគរួមគ្នាក្នុងទុនសង្គមកិច្ច ក៏ប្រហែលជាត្រូវថយចុះដែរ ។

៧. ផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនេះប្រហែលមានកំរិតខុសៗគ្នាសំរាប់វណ្ណៈ និងភេទផ្សេងៗគ្នា ។

៨. ការកើនឡើងនូវប្រភពនៃស្តង់ដា និងតំលៃនានា ដែលជាលទ្ធផលនៃការបើកចំហកាន់តែធំឡើង វាជាឧបសគ្គមួយចំពោះការយល់ដឹងរបស់សហគមន៍ (ការយល់ដឹងនេះហើយដែលត្រូវជួយផ្តល់ពត៌មាន ដើម្បីឱ្យទណ្ឌកម្ម និងការត្រួតត្រារបស់សង្គមអាចអនុវត្តបានដោយសក្តិសិទ្ធិ) ហើយវាធ្វើឱ្យចុះខ្សោយដល់សិទ្ធិអំណាចរបស់ថ្នាក់ដឹកនាំនៅមូលដ្ឋានផងដែរ ។ ម្យ៉ាងវិញទៀត វាអាចធ្វើឱ្យខូចខាតដល់ក្របខ័ណ្ឌនៃការយល់ដឹងដែលកំណត់ចេញនូវទំនាក់ទំនងគ្របសង្កត់ដ៏ជាប់លាប់ក្នុងអតីតកាល ហើយរឿងនេះវានាំឱ្យមានទំនាស់កាន់តែចំហឡើង ។ ដូចគ្នានេះដែរ នៅកម្ពុជាក្នុងពេលសព្វថ្ងៃមានការខំប្រឹងប្រែងប្រកបដោយស្មារតីច្បាស់លាស់ ដើម្បីកំណត់ទស្សនៈស្តីពីភាពត្រឹមត្រូវឡើងវិញ ហើយក្នុងនេះមានឥទ្ធិពលមួយចំនួននៃឱវាទរបស់ព្រះពុទ្ធ និងតំលៃនានានៃរបបសេរីរបស់បស្ចឹមប្រទេស ដូចជាសិទ្ធិមនុស្សជាដើម ។ ទាំងអស់នេះគឺជាចំណែកមួយនៃចលនាដើម្បីកសាងមូលដ្ឋានខាងស្មារតីនៃសង្គមកម្ពុជាឡើងវិញ (ដែលមជ្ឈដ្ឋានជាច្រើនគិតថា បានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរក្នុងសម័យសង្គ្រាម) ។

៩. ផលប៉ះពាល់ចំពោះលទ្ធភាពរបស់ភូមិ នៅក្នុងការដើរតួជាកន្លែងគន្លឹះ សំរាប់ការគ្រប់គ្រងទំនាស់ មានលក្ខណៈធំទូលាយ ។ នៅពេលដែលទំនាក់ទំនងកាន់តែមានលក្ខណៈអបុគ្គល រូបភាពនានានៃទុនអបុគ្គល ដូចជា លទ្ធភាពខាងប្រាក់កាស

ឬមធ្យោបាយប្រើអាវុធ  វាអាចមានសារៈសំខាន់កាន់តែខ្លាំងឡើងក្នុងការកំណត់ចេញនូវរចនាសម្ព័ន្ធទំនាក់ទំនងនៅក្នុងភូមិ ។ ក្នុងពេលជាមួយគ្នាដែរ វិធីនានានៃការត្រួតត្រារបស់សង្គម ដែលមានលក្ខណៈអបុគ្គល និងមានប្រភពពីខាងក្រៅភូមិ ដូចជា របបនីតិរដ្ឋជាដើម វានៅអន់ថយនៅឡើយនៅក្នុងសង្គមកម្ពុជា ។ ការខិតខំកសាងវប្បធម៌សន្តិភាពនៅក្នុងបរិបទនៃភូមិកម្ពុជា វាទាមទារឱ្យមានដំណោះស្រាយតាមបែបមូលដ្ឋានមួយ សំរាប់ទំនាក់ទំនងដែលកាន់តែស្មុគស្មាញ និងអបុគ្គលឡើង រវាងអ្នកភូមិ និងអ្នកភូមិ, និងរវាងអ្នកភូមិ និងពិភពលោកខាងក្រៅ ។ នេះហើយជាបញ្ហាប្រឈមសំរាប់អ្នកគ្រប់គ្រងទំនាស់នៅក្នុងភូមិកម្ពុជា ។

# ឯកសារយោង


Bagalli, Roberto & Colin Sumner (eds.) (1997*), Social Control and Political Order: European Perspectives at the End of the Century* (London: Sage).

Bennett, Tony, Colin Mercer & Janet Woollacott (eds.) (1986), *Popular Culture and Social Relations* (Milton Keynes: Open University Press)

Bit Seanglim (1991), *The Warrior Heritage, A Psychological Perspective on Cambodian Trauma* (El Cerrito: Bit Seanglim)

Bock, Philip K. (1969*), Peasants in the Modern World* (New Mexico: University of New Mexico Press)

Bourdieu, Pierre (1994), "Structures, Habitus, Power: Basis for a Theory of Symbolic Power," in Nicholas B. Dirks, Geoff Eley & Sherry B. Ortner (eds.), *Culture/Power/History, A Reader in Contemporary Social History* (Princeton: Princeton University Press) pp. 155-199

Cambodian Field Office of the United Nations Centre for Human Rights (undated)., *Mediating Public Issue Disputes: Managing Land Disputes in Cambodia, Resource Notes in English and Khmer* (Phnom Penh: UNCHR)

Chandler, David (1993), *A History of Cambodia*, 2nd ed. (Chiang Mai: Silkworm)

Chhay Yiheang (1999), *The Necessity of Utilizing a Concept of "Tolerance" in Cambodia* (Phnom Penh: Cambodian Institute for Co-operation and Peace)

--- (2000), *The Decline of Human Values in Cambodian Society Today* (Phnom Penh: Cambodian Institute for Co-operation and Peace)

Cheng Phon (1996), "Conflict and Conflict Resolution in Buddhist Teaching," unpublished manuscript, 2000.

--- (1996), *Master and Follower* (Phnom Penh: Centre for Vipassana)

--- (1996), *40 Questions and 40 Answers* (Phnom Penh: Centre for Vipassana)

--- (1996), *The Umbrella of Virtue* (Phnom Penh: Centre for Vipassana)

Collins, William A. (undated*), Dynamics of Dispute Resolution and Administration of Justice for Cambodian Villagers* (Phnom Penh: USAID)

Conway, Tim (2000), "Elections and Assassinations: Local Democracy and Rural Development in Cambodia," paper presented at the Annual Meeting of the Association for Asian Studies, held in San Diego in March 2000

Davenport, Paul, Joan Healy & Kevin Malone (1995), *Vulnerable in the Village: a Study of Returnees in Battambang Province, Cambodia, with a Focus on Strategies for the Landless* (Phnom Penh: Lutheran World Service, UNHCR & Japan Sotoshu Relief Committee)

Ebihara, May (1968), "Svay, a Khmer Village in Cambodia," PhD dissertation (Columbia University)

--- (1971), "Intervillage, Intertown and Village-City Relations in Cambodia," *Annals of the New York Academy of Sciences*

--- (1994), "Societal Organization in 16th and 17th Century Cambodia," *Journal of South East Asian Studies* 15, pp.280-295

Fisher-Nguyen, Karen (1994), "Khmer Proverbs: Images and Rules in Cambodian Culture Since 1975," in May Ebihara, Carole Mortland & Judy Ledgerwood (eds.), *Cambodian Culture Since 1975: Homeland and Exile* (London: Cornell UP)

Frieson, Kate (1994), "The Impact of Revolution on Cambodian Peasants: 1970-1975," PhD dissertation (Monash University, Ann Arbor: UMI Dissertation Services)

Girling, John (1971), *Cambodia and the Sihanouk Myths*, Occasional Paper No. 7 (Singapore: ISEAS)

Grzybowski, Alex et al. (eds.) (1998), *Building Democratic Institutions and Practices in Cambodia, Proceedings from the Cambodian Commission on Human Rights Capacity Building Project* (Phnom Penh: Pacific Resolutions and University of Victoria Institute for Dispute Resolution)

Gyallay-Pap, Peter (1996), "Buddhism as a Factor of Culture and Development in Cambodia," in *Cambodia Report* 2.2, pp. 8-13

--- (1999), "From Conflict to Reconciliation in Cambodia? Towards an Indigenous Approach" (Battambang: unpublished.)

Harker, Richard, Cheleen Mahar, & Chris Wilkes (eds.) (1990), *An Introduction to the Work of Pierre Bourdieu: The Practice of Theory* (Basingstoke: Macmillan)

Hazard, Barbara P. (1981), *Peasant Organization and Peasant Individualism: Land Reform, Co-operation and the Chinese Communist Party* (Saarbrucken: Breitenbach)

Heder, Steve & Judy Ledgerwood (eds.) (1996), *Propaganda, Politics and Violence in Cambodia: Democratic Transition under United Nations Peace-keeping* (London: M.E. Sharpe)

--- "The Politics of Violence: an Introduction," in Heder and Ledgerwood, pp. 3-49

Hou Yuon (1955), "The Peasantry of Kampuchea: Colonialism and Modernisation," extracts from La Paysannerie du Cambodge et ses Projets de Modernisation, Doctoral thesis (University of Paris), translated by Ben Kiernan, in Kiernan and Boua, pp.31-68

Hu Nim (1965), "Land Tenure and Social Structure in Kampuchea," extracts from Les Services Publics Economiques du Cambodge, Doctoral thesis (University of Phnom Penh), translated by Ben Kiernan, in Kiernan and Boua, pp.69-86

Hughes, Caroline (1998), "Human Rights in Cambodia: International Intervention and the National Response", Doctoral thesis (University of Hull)

--- (with Real Sopheap) (1999), *The Nature and Causes of Conflict Escalation in the 1998 Election* (Phnom Penh: CDRI)

Jenkins, Richard (1992), *Pierre Bourdieu* (London: Routledge)

Jenks, Chris (1993), *Culture* (London: Routledge)

Kao Kim Hourn (with Samraing Kamsang) (1999), *Grassroots Democracy in Cambodia, Opportunities, Challenges and Prospects* (Phnom Penh: Cambodian Institute for Co-operation and Peace and Forum Syd)

--- (1999), *Shared Leadership and Trust Building in Cambodia: Learning from the Past, Sharing Experiences, Views and Visions, and Drawing Lessons for the Future* (Phnom Penh: Cambodian Institute of Co-operation and Peace)

Khieu Samphan (1959), "Cambodia's Economy and Industrial Development", Doctoral thesis (Paris), translated by Laura Summers (1979), in *Cornell University Southeast Asia Program Data Paper,* No. 111

Kiernan, Ben (1975), *The Samlaut Rebellion and its Aftermath, the Origins of Cambodia's Liberation Movement Parts I and II* (Melbourne: Monash) Working Paper No. 4

Kiernan, Ben & Chantou Boua (eds.) (1982), *Peasants and Politics in Kampuchea, 1941-1981* (London: Zed Press)

Krishnamurthy, Veena (1999), *The Impact of Armed Conflict on Social Capital, a Study of Two Villages in Cambodia* (Phnom Penh: Social Services of Cambodia)

Ledgerwood, Judy (1990), "Portrait of a Conflict: Exploring Changing Khmer-American Social and Political Relationships" *Journal of Refugee Studies* 3.2, pp. 135-154

Lizée, Pierre (1993), "The Challenge of Conflict Resolution in Cambodia" *Canadian Defence Quarterly*, September, pp. 35-42

Lopez Vasquez, Carmen-Maria. (1996), *Pre-Trial Dispute Resolution Processes* (Phnom Penh: Court Training Project)

Lukes, Steven (1974), *Power, A Radical View* (London: Macmillan)

Mahaghosananda, Most Ven. Samdech Preah (1994), "Peace, Reconciliation and Reconstruction of Cambodia," in Mathews George Chunakara (ed.), *Indochina Today, A Consultation on Emerging Trends* (Hongkong: CCA-WCC Indochina Project) pp. 67-72

Martel, Gabrielle (1975), *Lovea, Village des Environs d'Angkor, Aspets Demographiques, Economiques et Sociologiques du Monde Rurale dans la Province de Siem Reap* (Phnom Penh: École Francaise d'Extreme Orient)

McGrew, Laura and Heang Path (2000*), Discussion Guide, Truth, Justice, Reconciliation and Peace in Cambodia, 20 Years After the Khmer Rouge* (Phnom Penh: Canadian Embassy)

Working Group on Social Organization in Cambodia (1999),*The Meaning of Community in Cambodia: Literature Reviews, Khmer, French and English Languages* (Phnom Penh, Working Group on Social Organization in Cambodia, May 1999)

Meas Nee (1995*), Toward Restoring Life, Cambodian Villages, translated and transcribed by Joan Healy* (Phnom Penh: Krom Akphiwat Phum)

UN Centre for Human Rights (undated) *Mediating Public Issue Disputes, Managing Land Disputes in Cambodia, Resource Notes in English and Khmer* (Phnom Penh: Cambodian Field Office of the UN Centre for Human Rights)

Mehrotra, Lakhan Lal et al. (1993), *Public Administration and Civil Service Reforms* (Phnom Penh: UNDP)

Moser-Puangsuwan, Yeshua (undated), *One Million Kilometres for Peace, Five years of Walking for Peace and Reconciliation in Cambodia, An Analysis of the Dhammayietra Movement* (Bangkok: Nonviolence International Southeast Asia Office)

Mysliwiec, Eva & Catherine Morris (1995*), Dispute Resolution in Cambodia: a Road to Peace and Reconciliation*, proceedings of a conference held in Phnom Penh, 28-30 Nov. 1995

National Democratic Institute for International Affairs (1996*), Public Attitudes Toward Democracy in Cambodia: A Focus Group Study* (Phnom Penh: National Democratic Institute for International Affairs)

Neb Sinthay & Janet Ashby (1998), *Possibilities to Reduce the Number of Weapons and the Practice of Using Weapons to Solve Problems in Cambodia* (Phnom Penh: Peace Partnership)

O'Brien, Kevin J. (1996), "Rightful Resistance" *World Politics* 49, pp. 31-55

Ovesen, Jan, Ing-Britt Trankell & Jaokim Ojendal (1996), *When Every Household is an Island* (Uppsala: University of Uppsala and SIDA)

Osborne, Milton (1973), *Politics and Power in Cambodia, The Sihanouk Years* (Camberwell: Longman)

Pearse, Andrew (1971), "Metropolis and Peasant: The Expansion of the Urban-Industrial Complex and the Changing Rural Structure," in Shanin (ed.), pp. 69-80

Preis, Ann-Belinda (1996), "Human Rights as Cultural Practice: An Anthropological Critique," *Human Rights Quarterly*, 18, pp. 286-315

Popkin, Samuel L. (1979), *The Rational Peasant, The Political Economy of Rural Society in Vietnam* (Berkeley: University of California Press)

Prum Sam Ol, Peng Chiew Meng & Elizabeth Uphoff Cato (1996), *Starting Over: The Reintegration Experience of Returnees, Internally Displaced and Demobilized Soldiers in Cambodia*, Cambodian Veterans Assistance Program Executive Secretariat Background Report (Phnom Penh: Cambodian Veterans Assistance Program)

Pye, Lucien W. (1985), *Asian Power and Politics, the Cultural Dimensions of Authority* (London: Harvard UP)

Radford, Robert (1960), *The Little Community: Peasant, Society and Culture* (Chicago: University of Chicago Press)

Rex, John (1981), *Social Conflict: A Conceptual and Theoretical Analysis* (London: Longman)

Scherer, Jacqueline (1972), *Contemporary Community: Sociological Illusion or Reality* (London: Tavistock)

Scott, James (1976), *The Moral Economy of the Peasant* (London: Yale UP)

--- (1985), *Weapons of the Weak, the Everyday Forms of Peasant Resistance* (New Haven: Yale UP)

Shanin, Teodor (1971), *Peasants and Peasant Societies, Selected Readings* (Harmondsworth: Penguin)

Somchai Phatharathananunth (2000), "Civil Society, Radical Democracy and Democratization in Thailand: An Isan Perspective," paper presented at the Conference on Globalization and Democracy in the Asia-Pacific held at the University of Lund, Sweden, in May 2000

Stirling, Paul (1971), "A Turkish Village," in Shanin (ed.), pp. 37-48

Suksamran, Somboon (undated). "The Buddhist Conception of Political Authority and Society as Basis to Rebuild the Khmer Society and Nation," in *Buddhism and the Future of Cambodia* **(**Rithisen: Khmer Buddhist Research Centre) pp. 106-129

Swift, Peter (1999), "Violence in Cambodian Villages," unpublished paper (Phnom Penh: Local Capacities for Non-Violence Project, American Friends Service Committee)

Thion, Serge (1987), "The Pattern of Cambodian Politics," in David A. Ablin & Marlowe Hood (eds.) *The Cambodian Agony*. (London: M.E. Sharpe) pp.149-164

--- (1983), *Watching Cambodia* (Bangkok: White Lotus)

Tilly, Charles (1986), *The Contentious French* (London: Belknap)

Trocki, Carl A. (ed.) (1998), *Gangsters, Democracy and the State in Southeast Asia* (Ithaca: Cornell University Southeast Asia Programme)

UNESCO. (1997) *A Culture of Peace: Promoting a Global Movement.* UNESCO Cultures of Peace Series. (Paris: UNESCO)

Van der Wijke, Dieneke (1997), *The Human Side of Conflict: Coping Strategies of Women Heads of Households in Four Villages in Sri Lanka and Cambodia* (Oxfam UK and Ireland)

Vickery, Michael (1984*), Cambodia 1975-82* (Boston: Southend Press)

Vijghen, John (1996), *Decision-Making in a Cambodian Village: A Study of Decision-Making Process in a Development Project in Takeo*, (Phnom Penh: Cambodian Researchers for Development) Paper no. 15

Wolf, Eric R. (1971), *Peasant Wars of the Twentieth Century* (London: Faber)

--- (1956), "Aspects of Group Relations in a Complex Society: Mexico" *American Anthropologist* 58.6, pp. 1065-78

Zimmerman, Cathy (1995), *Plates in a Basket will Rattle* (Phnom Penh: Project Against Domestic Violence)

៥.០០០ រៀល

ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ៍ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣,៨៨០-៧៣៤,៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤
អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh